**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ECONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្នុងការប្តឹងទាស់ នឹងមជ្ឈត្តវិនិច្ឆ័យនៅព្រះរាជាណាចក្រកម្ពុជា

*ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១*

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ដូលីន ផានីរាជ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# អំណះអំណាង

ខ្ញុំបាទ **ដួលីន ផានីរាជ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ ជំនាញនីតិសាស្ត្រ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាបានជ្រើសរើស ប្រធានបទសិក្សាស្រាវជ្រាវស្តីពី «*នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្នុងការប្តឹងទាស់នឹងមជ្ឈត្តវិនិច្ឆ័យនៅព្រះរាជាណាចក្រកម្ពុជា*» ប្រាកដមែន។

ខ្ញុំបាទសូមធានាអះអាងថា ស្នាដៃនេះ ពិតជាត្រូវបានរៀបចំចងក្រង និងបានសិក្សាស្រាវជ្រាវដោយរូបខ្ញុំបាទផ្ទាល់ ដោយបានទទួលនូវពុទ្ធិនានា តាមរយៈការសិក្សា ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ នៅឯសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងអនុសាសន៍ និងមតិយោបល់ណែនាំតម្រង់ទិសរបស់ លោក លោកស្រី សាស្ត្រាចារ្យកន្លងមក។

បន្ថែមពីលើនេះ ខ្ញុំបាទ សូមអះអាងផងដែរថា ស្នាដៃសិក្សាស្រាវជ្រាវនេះ មិនមានការចម្លង និងមិនមានការដកស្រង់ចេញពីអត្ថបទរបស់អ្នកស្រាវជ្រាវដទៃ ដោយមិនបានកំណត់ច្បាស់លាស់ ឬមិនបានយោងនូវប្រភពឯកសារនោះទេ។ រាល់ការដកស្រង់ចេញពីប្រភពឯកសារនានាទាំងឡាយ គឺត្រូវបានចង្អុលបង្ហាញក្នុងអត្ថបទត្រង់ចំណុចនីមួយៗយ៉ាងពិតប្រាកដ រួមទាំងមានការបង្ហាញបន្ថែមក្នុង បញ្ជីឯកសារយោង និងលេខសម្គាល់ក្រោមអក្សរ (footnote) ថែមទៀតផងដែរ៕

ថ្ងៃចន្ទ ១ កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១

ហត្ថលេខា

**ដួលីន ផានីរាជ**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ជួលីន ផានីរាជ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពប្រតិបត្តិ និងសូមសម្តែងនូវកតាញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុកអ្នកម្តាយ ព្រមទាំង លោកតានិងលោកយាយ ជាទីគោរពដ៏ខ្ពង់ខ្ពស់** ដែល បានផ្តល់កំណើតដល់ កូនចៅ និងបានខិតខំលះបង់អស់នូវកម្លាំងកាយកម្លាំងចិត្ត ដោយពុំខ្លាចនឿយហត់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ កូនចៅ ឱ្យខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវពុទ្ធិចំណេះដឹងសព្វសារពើ តាំងពីកម្រិតមូលដ្ឋាន រហូតមកដល់ពេលបច្ចុប្បន្ននេះ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកបានផ្តល់ឱកាសជូនដល់រូបខ្ញុំបាទ ក្នុងការពង្រីកនូវចំណេះដឹងផ្នែកនីតិសាស្ត្រ និងបន្តលើកស្ទួយថ្នាលបណ្តុះបណ្តាលនូវជំនាញនីតិសាស្ត្រជូនដល់និស្សិតគ្រប់រូបផងដែរ។

ជាពិសេស **លោកសាស្ត្រាចារ្យបណ្ឌិត ហ៊ុំ រិទ្ធី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងត្រួតពិនិត្យ ដោយមិនខ្លាចនឿយហត់សម្រាប់ការចង្អុលបង្ហាញផ្លូវ ណែនាំ និងកែប្រែរាល់កំហុសឆ្គងរបស់ខ្ញុំបាទ ដើម្បីធានាបានសមិទ្ធផលនៃស្នាដៃមួយដែលប្រកបដោយគុណភាពនេះ។

**លោក និងលោកស្រី សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំតាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់ពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

**សិស្សច្បង មិត្តនិស្សិត និងរៀមច្បងរួមការងារ** ដែលបានជួយណែនាំ និងផ្តល់នូវប្រភពឯកសារដល់ខ្ញុំបាទ ព្រមទាំងកែសម្រួលនូវកំហុសឆ្គងទាំងឡាយ រួមទាំងផ្តល់នូវកម្លាំងចិត្តជម្រុញឱ្យខ្ញុំបាទខិតខំបន្តការសិក្សាស្រាវជ្រាវនេះរហូតដល់បានជោគជ័យ។

ជាចុងក្រោយ ខ្ញុំបាទ សូមគោរពជូនពរ និងសូមលើកហត្ថាទាំងទ្វេបួងសួងដល់ទេវតា សូមជួយថែរក្សាលោកអ្នកមានគុណគ្រប់រូប ឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកដែលបានជួយទំនុកបម្រុងក្នុងកិច្ចការសារណានេះ សូមឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមឱ្យជួបប្រទះតែពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

មជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺជាយន្តការនៃដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមួយ ដែលមានសារៈសំខាន់ និងមានតម្រូវការចាំបាច់ក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មជាលក្ខណៈឯកជនរបស់ពាណិជ្ជករ អាជីវករ វិនិយោគិន និងធុរជនទាំងឡាយ ដែលមានបំណងធ្វើមជ្ឈត្តកម្មតាមការព្រមព្រៀងរវាងគូភាគីនៃវិវាទ។ យ៉ាងណាមិញ ក្រោយការធ្វើមជ្ឈត្តកម្ម ភាគីនៃវិវាទនឹងទទួលបាននូវមជ្ឈត្តវិនិច្ឆ័យមួយ ដែលជាសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តការមានលក្ខណៈចាប់បង្ខំ និងបិទផ្លូវតវ៉ា។ ប៉ុន្តែដោយសារតែ យន្តការនៃការដោះស្រាយនេះ ទាមទារឱ្យស្ថាប័នតុលាការជាអង្គក្នុងការអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនោះ ដូចនេះតុលាការ ដោយទទួលបានអំណាចពីច្បាប់ជាធរមាន បានបើកសិទ្ធិឱ្យគូភាគីនៃវិវាទក្នុងការធ្វើបណ្ដឹងទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ តាមលក្ខខណ្ឌដែលច្បាប់ជាធរមានបានផ្ដល់ឱ្យ។ បន្ថែមពីលើនេះ បទដ្ឋានគតិយុត្តស្ដីពីអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺមានលក្ខណៈបច្ចេកទេស និងមានវាក្យស័ព្ទគតិយុត្តច្រើន ដូចនេះ ជាការចាំបាច់ត្រូវមានការលើកយកមកបង្ហាញ និងពន្យល់រៀបរាប់ឱ្យបានក្បោះក្បាយផងដែរ។ ដោយយល់ឃើញអំពីធាតុសំខាន់នៃការពន្យល់ជាលក្ខណៈពិស្ដារទៅលើ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹង មជ្ឈត្តការផ្នែកពាណិជ្ជកម្ម រួមទាំងការធ្វើបណ្ដឹងទាស់របស់ភាគីវិវាទទៅតុលាការ ដើម្បីជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះ និងដោយមានការជួយជ្រោមជ្រែងពី **លោកសាស្ត្រាចារ្យបណ្ឌិត ថ្រាំ រិទ្ធី** ទើបនាំឲ្យមានគំនិតក្នុងការជ្រើសរើសយកប្រធានបទស្រាវជ្រាវស្ដីពី *«នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្នុងការប្ដឹងទាស់នឹងមជ្ឈត្តវិនិច្ឆ័យនៅព្រះរាជាណាចក្រកម្ពុជា»* នេះ យកមកធ្វើជាប្រធានបទសម្រាប់រៀបចំជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ។

អត្ថបទសារណានេះ ធ្វើការប្រមូលផ្ដុំនូវទ្រឹស្ដីសំខាន់ៗ ព្រមទាំងកម្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តិដែលទាក់ទងនឹងប្រធានបទនេះ ដើម្បីផ្ដល់ជាឧត្តមប្រយោជន៍ចំពោះអ្នកសិក្សាស្រាវជ្រាវ និង និស្សិតដែលមានបំណងចង់ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅចំពោះវិស័យនេះនាថ្ងៃអនាគត។ ទោះបីជាការស្រាវជ្រាវនេះ នៅមានកម្រិត និងមិនទាន់បានល្អឥតខ្ចោះក៏ដោយ ខ្ញុំបាទមានសង្ឃឹមថា ការរៀបចំជាសារណានេះ នឹងអាចចូលរួមចំណែក បង្ហាញ និងបង្កើតជាគំនិតស្រាវជ្រាវបន្តទៀត និងដើម្បី ការពារដល់ផលប្រយោជន៍នានា ដែលប្រជាពលរដ្ឋអាចនឹងទទួលបានពីការជ្រើសរើសនូវយន្តការនៃការដោះស្រាយនេះ។

ជាចុងក្រោយ ខ្ញុំបាទសូមអភ័យទោសទុកជាមុន ចំពោះរាល់កំហុសខុសឆ្គងដោយប្រការណាមួយ ដែលអាចនាំឲ្យមានការភ័ន្តច្រឡំអំពីគំនិតដើម ឬ ជាការប្រើប្រាស់ ឬ ជ្រើសរើសពាក្យពេចន៍មកធ្វើការអធិប្បាយក្នុងអត្ថបទនេះពុំសមស្របជាដើម ។

ខ្ញុំបាទ សូមរងចាំទទួលដោយក្ដីរីករាយនូវរាល់ការរិះគន់ដើម្បីស្ថាបនាពីគ្រប់មជ្ឈដ្ឋាន៕

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ **១**

## ជំពូកទី១
## របបគតិយុត្តក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**១.១. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ** ........ **៣**

១.១.១. អនុសញ្ញាទីក្រុងញូវយក ........ ៣

១.១.២. ច្បាប់គម្រូនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........ ៥

**១.២. លិខិតបទដ្ឋានគតិយុត្តជាតិ** ........ **៧**

១.២.១. ក្រមនីតិវិធីរដ្ឋប្បវេណី ........ ៨

១.២.២. ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........ ៩

១.២.៣. ច្បាប់ស្តីពីការយល់ព្រម និងអនុវត្តអនុសញ្ញាទីក្រុងញូវយក ........ ១០

១.២.៤. អនុក្រឹត្យ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម........ ១២

១.២.៥. វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........ ១៤

## ជំពូកទី២
## ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

**២.១. មូលដ្ឋាននៃការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ** ........ **១៧**

២.១.១. ភាគីនៃវេទិកាមជ្ឈត្តការ ........ **១៧**

២.១.១.១. រដ្ឋ ........ ១៧

២.១.១.២. បុគ្គល ........ ២០

២.១.២. កិច្ចព្រមព្រៀងមជ្ឈត្តកម្ម ........ **២១**

២.១.២.១. សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ........ ២២

២.១.២.២. មូលដ្ឋានសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តការ ........ ២២

២.១.៣. ការតែងតាំងមជ្ឈត្តករ ........ **២៤**

២.១.៣.១. សមាសភាពនៃមជ្ឈត្តករ ........ ២៥
២.១.៣.២. នីតិវិធីនៃការតែងតាំងមជ្ឈត្តករ ........ ២៧
២.១.៣.៣. ការប្ដឹងជំទាស់នឹងសមាសភាពមជ្ឈត្តករ ........ ២៨
**២.២. នីតិវិធីនៃការប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ........ ៣២**
២.២.១. យុត្តិកម្មក្នុងការធ្វើបណ្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដោយភាគីវិវាទ ........ **៣២**
២.២.២. តួនាទីរបស់តុលាការក្នុងនីតិវិធីនៃការប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ........ **៣៤**
២.២.២.១. កម្មវត្ថុនៃវិវាទ ........ ៣៦
២.២.២.២. នយោបាយសាធារណៈ ........ ៣៧
**សេចក្ដីសន្និដ្ឋាន ........ ៤០**
**អនុសាសន៍ ........ ៤២**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

មជ្ឈត្តការ គឺជាយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលគូភាគីនៃវិវាទបានព្រមព្រៀងគ្នាក្នុងការស្វែងរកភាគីអព្យាក្រឹត្យទីបី ដើម្បីមកដោះស្រាយវិវាទជូនខ្លួន តាមរយៈការធ្វើមជ្ឈត្តកម្ម ដោយវេទិកាមជ្ឈត្តកម្ម។ បន្ទាប់ពីបានពិចារណា និងធ្វើការវិនិច្ឆ័យលើវិវាទ ដែលភាគីបានដាក់ជូនរួចហើយនោះ វេទិកាមជ្ឈត្តកម្ម ត្រូវចេញនូវសេចក្ដីសម្រេចមួយដែលហៅថា មជ្ឈត្តវិនិច្ឆ័យ ដើម្បីចាប់បង្ខំ ឬទាមទារឱ្យភាគីនៃវិវាទបំពេញកាតព្វកិច្ចស្របតាមការសម្រេចរបស់វេទិកាមជ្ឈត្តការ និងការទាមទាររបស់គូភាគី ដោយ ដាក់ជូនទៅ តុលាការមានសមត្ថកិច្ច ដើម្បីចេញសេចក្ដីសម្រេចអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនោះ។ ក្នុងដំណាក់កាលមុនឈានដល់ការអនុវត្ត ពោលគឺទទួលស្គាល់ ឬបដិសេធនូវមជ្ឈត្តវិនិច្ឆ័យនោះ គូភាគីនៃវិវាទអាចធ្វើការប្ដឹងជំទាស់លុបចោលនូវមជ្ឈត្តវិនិច្ឆ័យនេះបាន។ ប៉ុន្តែការប្ដឹងជំទាស់នេះ គឺមិនអាចប្ដឹងជំទាស់បានដោយទូលំទូលាយ ឬដោយគ្មានមូលដ្ឋានត្រឹមត្រូវនោះទេ តួយ៉ាង ច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា បានរឹតត្បិតក្នុងការប្ដឹងជំទាស់នេះយ៉ាងខ្លាំង ដើម្បីឆ្លើយតបទៅនឹង ឯករាជ្យភាពរបស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈបន្ថយការប្រលូកចូលជាមួយនឹងតុលាការមកត្រឹមកម្រិតអប្បបរិមាជាដាច់ខាត។ ហើយការប្ដឹងជំទាស់នេះទៀតសោត ច្បាប់បានកម្រិតនូវមូលហេតុក្នុងការធ្វើបណ្ដឹងបាន ក្នុងបរិមាណតិចតួចបំផុត។ ការកំណត់បែបនេះ គឺមិនមែនដើម្បីជាការកំណត់ថាតុលាការ ត្រូវតែប្រានចោល ឬលុបចោលនូវមជ្ឈត្តវិនិច្ឆ័យដែលត្រូវបានប្ដឹងទាស់នោះទេ ប៉ុន្តែវាអាចត្រូវបានចាត់ទុកជាមូលដ្ឋានមួយក្នុងការអនុវត្តជាក់ស្ដែង ដើម្បីឱ្យគូភាគីនៃវិវាទ និងវេទិកាមជ្ឈត្តកម្មមានការប្រុងប្រយ័ត្នយ៉ាងខ្លាំងចំពោះចំណុចទាំងប៉ុន្មានដែលបានកំណត់នោះ។

នៅក្នុងអត្ថបទសារណានេះ នឹងធ្វើការពិនិត្យមើលលម្អិតទៅលើមូលដ្ឋាននៃការប្ដឹងជំទាស់ ដោយសិក្សាជាលក្ខណៈពិស្ដាទៅលើចំណុចនីមួយៗ។ បុព្វហេតុចម្បងនៃការសិក្សាទៅលើរបបនៃការប្ដឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យនេះ គឺដោយសារតែច្បាប់ជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា បានចែងនូវបញ្ញត្តិពាក់ព័ន្ធទៅនឹងការប្ដឹងជំទាស់នេះ ប៉ុន្តែការចែងនេះ គឺពុំត្រូវបានបរិយាយរៀបរាប់ ពន្យល់ ឬបកស្រាយឱ្យក្បោះក្បាយទៅលើមូលដ្ឋាននីមួយៗនោះទេ។ យ៉ាងណាមិញ នៅក្នុងវិធាននៃមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា ដែលជាបទដ្ឋានទម្រង់នៃវេទិកាមជ្ឈត្តការ ក្នុងការប្រតិបត្តិតាមនោះ គឺមានចែងនៅដោយផ្ទេកៗ ដោយដុំៗ ពោលគឺពុំមានចែងជាបណ្ដុំនៃបញ្ញត្តិជាក់លាក់ពាក់ព័ន្ធទៅនឹងការប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ តបតាមការចែងក្នុងច្បាប់ជាធរមាននោះទេ។ ហេតុដូចនេះហើយ នៅក្នុងសារណានេះ នឹងពិនិត្យមើលថា តើមូលដ្ឋាននៃការប្ដឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យដែលបានចេញដោយវេទិកាមជ្ឈត្តការរួចនោះមានអ្វីខ្លះ? ហើយថា តើមូលដ្ឋាននីមួយៗមានការកំណត់ឬមានធាតុសំខាន់ៗអ្វីខ្លះ ដើម្បីផ្ដល់ជាបទដ្ឋានក្នុងការចងក្រងជាសេចក្ដីថ្លែងទាមទារ

ទៅកាន់តុលាការ។ បន្ថែមពីលើការពិនិត្យមើលទៅលើរបបនៃការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ អត្ថបទសារណានេះ នឹងលើកយកមកបង្ហាញជាលក្ខណៈពិស្តាផងដែរ នូវលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ មូលហេតុចម្បងក្នុងការលើកយកនូវលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនេះមកបង្ហាញគឺដោយសារតែ របបគតិយុត្តនៃវិស័យនេះគឺមានការធ្វើបច្ចុប្បន្នភាពច្រើន ដោយទាមទារឱ្យអ្នកសិក្សាស្រាវជ្រាវ និងអ្នកប្រកបវិជ្ជាជីវៈ មានការស្រាវជ្រាវឱ្យបានទាន់និន្នាការ និងបច្ចុប្បន្នភាពនៃបទដ្ឋានទាំងឡាយនេះ។ តួយ៉ាង វិធាននៃមជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា បានធ្វើវិសោធនកម្មលើកដំបូងនាដើមឆ្នាំ២០២១ ដែលនឹងត្រូវដាក់ឱ្យអនុវត្តនៅខែកក្កដា ឆ្នាំ២០២១ នេះ។ ដូចនេះជាចំណោទបញ្ហាសំខាន់ៗនោះថា តើបច្ចុប្បន្នភាពនៃវិធានថ្មីនេះ នឹងនាំឱ្យមានការផ្លាស់ប្តូរអ្វីខ្លះទៅលើនីតិវិធីនានានៃមជ្ឈត្តការ ហើយថាតើវិធានថ្មីនេះ នឹងបង្កឱ្យការប្រែប្រួលអ្វីខ្លះក្នុងការអនុវត្តជាក់ស្តែងទៅលើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យផងដែរ។ យ៉ាងណាមិញ ក៏នឹងធ្វើការពិនិត្យទៅលើបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធផ្សេងៗផងដែរ ក៏ទោះបីជាបទដ្ឋានទាំងនោះពុំទាន់បានធ្វើបច្ចុប្បន្នភាពនៅឡើយ ប៉ុន្តែការសិក្សានេះនឹងផ្តល់ជាផលប្រយោជន៍ជាច្រើនដល់អ្នកសិក្សាស្រាវជ្រាវ ក្នុងការទទួលបាននូវចំណេះដឹងទូលំទូលាយ ក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មថែមទៀតផង។

ក្នុងការស្រាវជ្រាវទៅលើប្រធានបទនេះ ការសិក្សានឹងផ្អែកទៅលើលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានក្នុងឆាកអន្តរជាតិ និងក្នុងព្រះរាជាណាចក្រកម្ពុជាបន្ថែមទៀត។ លើសពីនេះទៅទៀត ក៏មានលើកឡើងនូវ យុត្តិសាស្ត្រនៃតុលាការ សេចក្តីពន្យល់ អត្ថបទស្រាវជ្រាវ និងមតិយោបល់របស់បញ្ញវន្តជាតិ និងអន្តរជាតិទៅលើបញ្ហាជុំវិញមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាពិសេសនោះគឺការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យតែម្តង។

ដូចនេះ មុនបន្តធ្វើការបកស្រាយ និងដើម្បីជាការសម្របសម្រួលដល់អ្នកសិក្សាស្រាវជ្រាវ និងអ្នកអានអត្ថបទសារណានេះ នឹងធ្វើការបែងចែកប្លង់មាតិកា ជាពីរជំពូកធំៗ ដោយផ្តើមចេញពីការបង្ហាញអំពី របបគតិយុត្តនៃវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ជំពូកទី ១) និងបន្តបកស្រាយលំអិតទៅលើ ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ (ជំពូកទី ២)។ គួរបញ្ជាក់ផងដែរថា ក្នុងជំពូកទី ១ ដែលជាជំពូកបឋមនៃអត្ថបទស្រាវជ្រាវ គឺត្រូវបានបែងចែកចេញជា ពីរផ្នែកបន្ថែមទៀត ដែលក្នុងនោះរួមមាន ការលើកយកមកបង្ហាញនូវ លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ (១.១) និងលិខិតបទដ្ឋានគតិយុត្តជាតិ (១.២)។ ចំណែកឯ ជំពូកទី ២ ដែលជាជំពូកស្នូល និងសំខាន់ នឹងបន្តសិក្សាទៅលើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ រួមមាន ការពិនិត្យមើលទៅលើ មូលដ្ឋាននៃការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ (២.១) ដែលនឹងធ្វើការលម្អិតទៅលើមូលដ្ឋានជំទាស់នីមួយៗយ៉ាងក្បោះក្បាយ ហើយក្នុងចំណុចបន្ទាប់ នឹងបន្តសិក្សាទៅលើនីតិវិធីនៃការប្តឹងជំទាស់ (២.២) ដែលក្នុងនោះនឹងស្រាវជ្រាវទៅលើយុត្តិកម្មនៃកាធ្វើបណ្តឹងជំទាស់ និងតួនាទីរបស់តុលាការនៅក្នុងនីតិវិធីនៃការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដែរ។

# ជំពូកទី១

## របបគតិយុត្តក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

# ជំពូកទី១

# របបគតិយុត្តក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## ១. របបគតិយុត្តក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ការពិនិត្យមើលទៅលើ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវធ្វើការបែងចែកនូវការសិក្សាតាមប្រភពនៃបទដ្ឋាននោះ។ ដោយនៅក្នុងផ្នែកនេះនឹងផ្តើមដោយ ប្រភព លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ (១.១.) និងបន្តទៅ លិខិតបទដ្ឋានគតិយុត្តជាតិ (១.២.)។

### ១.១. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

តាមរយៈការសិក្សាទៅលើស្មារតីនៃ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម[1] (ដែលនឹងបន្តលំអិតនៅក្នុង *ចំណុច ១.២* ខាងក្រោម) បានបង្ហាញឱ្យឃើញថា ច្បាប់នេះដែលជាច្បាប់គោលក្នុងរបបមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា ហើយការតាក់តែងនូវបញ្ញត្តិនៃមាត្រានីមួយៗ បានយកគម្រូស្តង់ដាតាម ច្បាប់គម្រូនៃគណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកនីតិអន្តរជាតិពាណិជ្ជកម្មស្តីអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម[2] ក៏ដូចជាបង្កើតឡើងស្របតាមគោលការណ៍នៃ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ[3] ផងដែរ។[4]

#### ១.១.១. អនុសញ្ញាទីក្រុងញូវយក

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស ដែលហៅកាត់ថា «អនុសញ្ញាទីក្រុងញូវយក» ត្រូវបានចាប់បដិសន្ធិឡើងនៅឆ្នាំ ១៩៥៨ និងចូលជាធរមាន

[1] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/រកម/០៥០៦/០១០ ប្រកាសនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ (តទៅនេះហៅថា «ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម»)។

[2] ច្បាប់គម្រូនៃគណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកនីតិអន្តរជាតិពាណិជ្ជកម្មស្តីអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម «ច្បាប់គម្រូនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម» (តទៅនេះហៅថា «ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម») ប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៨៥ ដោយគណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកនីតិអន្តរជាតិពាណិជ្ជកម្ម ឯកសារលេខ A/៤០/១៧។

[3] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ឆ្នាំ២០១៥ (តទៅនេះហៅថា «អនុសញ្ញាទីក្រុងញូវយក»)។ ជាកំណត់សម្គាល់សំខាន់គឺ ការយោងនូវអនុសញ្ញានេះ នៅក្នុងសារណា នឹងផ្អែកទៅលើ អត្ថបទនៃអនុសញ្ញាទីក្រុងញូវយក ឆ្នាំ២០១៥ ដែលជាអត្ថបទត្រូវបានពិនិត្យពិច័យឡើងវិញជាលើកទី៣ដោយអង្គការសហប្រជាជាតិ ហើយក្នុងនោះផងដែរ ជាលទ្ធផលនៃការពិនិត្យឡើងវិញ គឺផ្នែកទី៣នៃអត្ថបទដើម ឆ្នាំ២០០៩ ត្រូវបានដកចេញ។

[4] *សូមមើល* មេធាវី ខៀវ មាលី, ទិដ្ឋភាពគតិយុត្ត ផ្នែកពាណិជ្ជកម្ម និងការវិនិយោគ នៅកម្ពុជា (តទៅនេះហៅថា «សៀវភៅ មេធាវី ខៀវ មាលី»), ការិយាល័យមេធាវី សុក ស៊ីថាន់ណា និងសហការី, ឆ្នាំ ២០១៨, ទំព័រទី ១៤៥។

នៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ១៩៥៩។[5] អនុសញ្ញានេះត្រូវបានប្រើប្រាស់ជាបទដ្ឋានគតិយុត្តដ៏សំខាន់មួយ ក្នុងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ តួយ៉ាងទាំងមជ្ឈត្តវិនិច្ឆ័យដែលចេញដោយ មជ្ឈត្តករតែងតាំងដោយភាគី និងទាំងមជ្ឈត្តវិនិច្ឆ័យ ចេញដោយអង្គមជ្ឈត្តការអចិន្ត្រៃយ៍ ដែលភាគីបានដាក់សំណើទៅ។[6] ជាកាតព្វកិច្ចចងដោយអនុសញ្ញានេះ រដ្ឋជាហត្ថលេខី ត្រូវចាំបាច់គោរពតាមបញ្ញត្តិទាំងឡាយ ដោយអនុវត្តទៅលើមជ្ឈត្តវិនិច្ឆ័យដែលបានចេញនៅរដ្ឋដទៃ រួមទាំងធ្វើការអនុវត្តតែទៅលើទំនាក់ទំនងគតិយុត្ត ដែលទទួលស្គាល់ជាលក្ខណៈពាណិជ្ជកម្មក្រោមច្បាប់ជាតិរបស់ខ្លួន។ បន្ថែមពីលើនេះគឺ បញ្ហាទាក់ទងទៅនឹងកិច្ចព្រមព្រៀងមជ្ឈត្តការ ដែលជាគោលការណ៍ត្រូវគោរពតាមគោលការណ៍ណែនាំរួមជាអប្បបរមារបស់ ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុង មាត្រា ២ នៃអនុសញ្ញានេះ ពោលគឺកិច្ចព្រមព្រៀង ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីអនុញ្ញាតឱ្យភាគីនៃកិច្ចព្រមព្រៀង បានដឹង និងឃើញនូវសិទ្ធិទាំងឡាយដែលខ្លួនមាន ព្រមទាំងផ្តល់ជាសក្ខីកម្មទៅលើសុពលភាពនៃកិច្ចព្រមព្រៀង ក្រោមច្បាប់ ឬអនុសញ្ញានានាដែលប្រទេសត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះផ្តល់ឱ្យ។[7] មាត្រា ៣៥ និង មាត្រា ៣៦ នៃច្បាប់គម្រូមជ្ឈត្តការពាណិជ្ជកម្ម ចែងអំពីបទដ្ឋាននានាក្នុងការទទួលស្គាល់ ឬជំទាស់ការអនុវត្តមជ្ឈត្តវិនិច្ឆ័យនៅលើទឹកដីនៃប្រទេសដទៃ។ យ៉ាងណាមិញ អនុសញ្ញាទីក្រុងញូវយកក៏បានលើកឡើងអំពីចំណុចនេះតាំងពីមុនមកម្ល៉េះ ដោយកំណត់យកនូវ បទដ្ឋាន ចំនួនប្រាំពីរ ក្នុងការជំទាស់ការទទួលស្គាល់ និងអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនោះ។ ចំណុចទាំងប្រាំពីរនោះរួមមាន (១) អសមត្ថភាពរបស់គូភាគី (២) អសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការ (៣) ការអនុលោមតាមបទដ្ឋានគតិយុត្តនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (៤) វិសាលភាពនៃកិច្ចព្រមព្រៀង និងដែនយុត្តាធិការនៃវេទិកាមជ្ឈត្តការ (៥) ការលើកចោល ឬប្រានចោលមជ្ឈត្តវិនិច្ឆ័យ (៦) សមត្ថភាពនៃមជ្ឈត្តកម្ម និង (៧)គោលនយោបាយសាធារណៈរបស់រដ្ឋដែលចេញ និងអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនោះ។[8]

---

[5] *អនុសញ្ញាទីក្រុងញូវយក,* មាត្រា ១២។

[6] *អនុសញ្ញាទីក្រុងញូវយក,* មាត្រា ១(១) និងមាត្រា ១(២)។

[7] *អនុសញ្ញាទីក្រុងញូវយក,* មាត្រា ២។ មាត្រា ២ នៃអនុសញ្ញានេះ ចែងជាភាសាអង់គ្លេស ដូចតទៅ៖

> "1. Each Contracting State shall recognize an agreement in writing under which the parties undertake to submit to arbitration all or any differences which have arisen or which may arise between them in respect of a defined legal relationship, whether contractual or not, concerning a subject matter capable of settlement by arbitration.
> 2. The term "agreement in writing" shall include an arbitral clause in a contract or an arbitration agreement, signed by the parties or contained in an exchange of letters or telegrams.
> 3. The court of a Contracting State, when seized of an action in a matter in respect of which the parties have made an agreement within the meaning of this article, shall, at the request of one of the parties, refer the parties to arbitration, unless it finds that the said agreement is null and void, inoperative or incapable of being performed."

[8] *អនុសញ្ញាទីក្រុងញូវយក,* មាត្រា ៤ និង មាត្រា ៥។

អនុសញ្ញានេះបានជម្រុញក្នុងការអនុវត្តសេចក្ដីសម្រេចមជ្ឈត្តការបរទេសឱ្យបានកាន់តែច្រើន តាមរយៈបញ្ញត្តដូចដែលមានចែងក្នុងមាត្រា ៧ នៃអនុសញ្ញានេះ គឺត្រូវលុបបំបាត់ចោលនូវបញ្ញត្តិទាំងឡាយនៃច្បាប់ជាតិរបស់រដ្ឋដែលផ្ដល់នូវគុណប្រយោជន៍ដល់ភាគីតិចជាអនុសញ្ញានេះ ហើយបន្តលើកទឹកចិត្តដល់ការអនុវត្តបន្ថែមទៀតចំពោះច្បាប់ជាតិទាំងឡាយដែល បានផ្ដល់អត្ថប្រយោជន៍ជាអប្បបរមាស្មើនឹងអនុសញ្ញានេះ ឬលើសពីអនុសញ្ញានេះ។[9]

### ១.១.២. ច្បាប់គម្រូនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ច្បាប់គម្រូនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងដោយ គណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកនីតិអន្តរជាតិពាណិជ្ជកម្ម នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៨៥ ដោយមានសរុបទាំងអស់ សាមសិបប្រាំមួយ (៣៦) មាត្រា បែងចែកជា ប្រាំបី (៨) ជំពូក។ ក្នុងច្បាប់នេះ ជំពូកទីមួយ គឺមានប្រាំមួយ (៦) មាត្រាស្ដីពី បញ្ញត្តិទូទៅ ដោយ មាត្រា ១ នៃច្បាប់នេះ បានបញ្ជាក់ថានឹងមានវិសាលភាពអនុវត្តទៅលើ មជ្ឈត្តការផ្នែកពាណិជ្ជកម្មជាលក្ខណៈអន្តជាតិ អាស្រ័យទៅនឹងកិច្ចព្រមព្រៀងជាធរមានរវាងរដ្ឋ និងរដ្ឋដទៃ។[10] ម៉្យាងទៀតចំណុចដែលសំខាន់ក្នុងមាត្រានេះ គឺបច្ចេកសព្ទនៃពាក្យថា អន្តរជាតិ។ ក្នុងមាត្រាដដែលនេះ ពាក្យថា «អន្តរជាតិ» គឺសម្ដៅដល់ ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការ ដែលក្នុងពេលអនុវត្តនូវកិច្ចព្រមព្រៀងនេះ មានទីតាំងអាជីវកម្មក្នុងរដ្ឋផ្សេងពីគ្នា ឬទីតាំងជាគោលមួយចំនួនទៀតស្ថិតនៅក្រៅរដ្ឋដែលភាគីមានទីតាំងនៃអាជីវកម្មរបស់ខ្លួន ពោលគឺ ទីតាំងនៃវេទិកាមជ្ឈត្តការ ទីតាំងដែលផ្នែកនៃកាតព្វកិច្ចសំខាន់ក្នុងទំនាក់ទំនងពាណិជ្ជកម្មរវាងភាគីទាំងពីរមាន ឬទីតាំងនៃកម្មវត្ថុនៃជម្លោះនោះស្ថិតនៅជិតបំផុត ឬភាគីបានបញ្ជាក់ថាកម្មវត្ថុនៃកិច្ចព្រមព្រៀងមជ្ឈត្តការមានទំនាក់ទំនងជាមួយ ប្រទេសច្រើន។[11] យ៉ាងណាមិញ ប្រសិនបើភាគីមានទីតាំងអាជីវកម្មច្រើន នោះគឺកំណត់យកទីតាំងអាជីវកម្ម ដែលមានទំនាក់ទំនងយ៉ាងជិតស្និតបំផុត ជាមួយនឹងកិច្ចព្រមព្រៀងមជ្ឈត្តការ ហើយប្រសិនបើក្នុងករណីដែលភាគីពុំមានទីតាំងអាជីវកម្មនោះទេ គឺចាំបាច់ត្រូវកំណត់យកទីតាំងនៃទីស្នាក់អាស្រ័យរបស់ភាគីនោះជាទីតាំងអាជីវកម្ម។[12] ជាគោលការណ៍ក្នុងការតាក់តែងនូវ ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា គឺបានបន្តផ្នែកទៅលើទិដ្ឋភាពមជ្ឈត្តកម្មមួយចំនួនទៀតរួមមាន រូបមន្តនៃកិច្ចព្រមព្រៀងមជ្ឈត្តការ ដែនយុត្តាធិការនៃវេទិកាមជ្ឈត្តការ និងការអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ។[13] នៅក្នុងជំពូកទីប្រាំបីនៃ

---

[9] *អនុសញ្ញាទីក្រុងញូវយក*, មាត្រា ៧។

[10] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១(១)។

[11] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១(៣)។

[12] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១(៤)។

[13] សូមមើល *សៀវភៅ មេធាវី ខៀវ មាលី*, ទំព័រទី ១៥៥។

ច្បាប់គម្រូនេះគឺបានលើកឡើងនូវ ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ដែលមានចំនួនពីរមាត្រា កំណត់ទៅលើ ការទទួលស្គាល់ និងការអនុវត្ត (មាត្រា ៣៥) និងបទដ្ឋានក្នុងការជំទាស់ការទទួលស្គាល់ ឬការអនុវត្ត (មាត្រា ៣៦)។ មាត្រា ៣៥ នៃច្បាប់នេះ បានកំណត់នូវគោលការណ៍ណែនាំរួមជាអប្បបរមាក្នុងការទទួលស្គាល់ និងអនុវត្ត ពោលគឺ មជ្ឈត្តវិនិច្ឆ័យដែលបានសម្រេច ត្រូវតែទទួលស្គាល់នូវអានុភាពចាប់បង្ខំ និងតាមរយៈការស្នើសុំជាលាយលក្ខណ៍អក្សរ ទៅកាន់តុលាការមានសមត្ថកិច្ច ដែលនាំឱ្យ មជ្ឈត្តវិនិច្ឆ័យនោះមានអានុភាពអនុវត្តតាមមាត្រា៣៦ នៃច្បាប់នេះ។[14] ហើយភាគីដែលពឹងផ្អែកទៅលើមជ្ឈត្តវិនិច្ឆ័យនោះ ឬស្នើសុំការអនុវត្ត ចាំបាច់ត្រូវតែដាក់ជូនតុលាការមានសមត្ថកិច្ចនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យច្បាប់ដើម ឬច្បាប់ចតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវមានអាជ្ញាធរមានសមត្ថកិច្ច។[15] ចំណែកឯ កិច្ចព្រមព្រៀងមជ្ឈត្តការវិញ គឺត្រូវដាក់ជូននូវច្បាប់ដើម ឬច្បាប់ចតចម្លងមានការបញ្ជាក់ ដូចមានចែងក្នុងមាត្រា ៧[16] នៃច្បាប់នេះ។ ក្នុងករណីដែល មជ្ឈត្តវិនិច្ឆ័យ ឬកិច្ចព្រមព្រៀង មិនត្រូវបានធ្វើឡើងជាភាសាផ្លូវការនៃរដ្ឋអនុវត្តមជ្ឈត្តវិនិច្ឆ័យទេនោះ ចាំបាច់ត្រូវដាក់ជូននូវមជ្ឈត្តវិនិច្ឆ័យ ឬកិច្ចព្រមព្រៀងនោះ ដែលបានបកប្រែជាភាសាផ្លូវការនៃរដ្ឋអនុវត្ត ដោយមានការបញ្ជាក់យ៉ាងត្រឹមត្រូវផងដែរ។[17] ចំពោះ មាត្រា ៣៦ នៃច្បាប់គម្រូនេះ បានបន្តចែងអំពី បទដ្ឋានក្នុងការជំទាស់ការទទួលស្គាល់ ឬអនុវត្តមជ្ឈត្តវិនិច្ឆ័យ ចំនួនពីរករណី។[18] ករណីទីមួយ គឺផ្អែកសំខាន់ទៅលើការស្នើសុំរបស់ភាគីទៅកាន់តុលាការមានសមត្ថកិច្ច ដោយមានបញ្ជាក់នូវទឡ្ហីករណ៍ចំនួនប្រាំដូចជា៖ (១) ប្រសិនបើ ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនោះ ពុំបានបំពេញនូវសមត្ថភាពក្នុងការចុះកិច្ចព្រមព្រៀងដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់គម្រូនេះ ឬកិច្ចព្រមព្រៀងនេះពុំបានអានុភាពគតិយុត្តក្រោមច្បាប់នៃរដ្ឋរបស់ភាគីដែលបានចុះកិច្ចព្រមព្រៀងនោះ ឬច្បាប់នៃរដ្ឋអនុវត្តមជ្ឈត្តវិនិច្ឆ័យ (២) ភាគីពុំបានទទួលនូវការជូនដំណឹងត្រឹមត្រូវអំពីការតែងតាំង

---

[14] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៣៥។

[15] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៣៥។

[16] មាត្រា ៧ នៃ *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* មានចែងជា ភាសាអង់គ្លេស ដូចតទៅ៖

> “1. "Arbitration agreement" is an agreement by the parties to submit to arbitration all or certain disputes which have arisen or which may arise between them in respect of a defined legal relationship, whether contractual or not. An arbitration agreement may be in the form of an arbitration clause in a contract or in the form of a separate agreement.
> 2. The arbitration agreement shall be in writing. An agreement is in writing if it is contained in a document signed by the parties or in an exchange of letters, telex, telegrams or other means of telecommunication which provide a record of the agreement, or in an exchange of statements of claim and defence in which the existence of an agreement is alleged by one party and not denied by another. The reference in a contract to a document containing an arbitration clause constitutes an arbitration agreement provided that the contract is in writing and the reference is such as to make that clause part of the contract.”

[17] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៣៥(២)។

[18] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៣៦។

មជ្ឈត្តករ ឬដំណើរការនៃនីតិវិធីមជ្ឈត្តការ (៣) មជ្ឈត្តវិនិច្ឆ័យមិនស្ថិតនៅក្រោមវិវាទដែលដាក់ជូនវេទិកាមជ្ឈត្តការ ឬការសម្រេចសេចក្តីនោះមានវិសាលភាពលើសពីការដាក់ជូន ប៉ុន្តែបើមជ្ឈត្តវិនិច្ឆ័យនោះមានផ្នែកដែលត្រូវយកមកអនុវត្តបាន គឺត្រូវមានអានុភាពអនុវត្តជាធម្មតា (៤) ប្រសិនបើសមាសភាពនៃវេទិកាមជ្ឈត្តការ ឬនីតិវិធីមជ្ឈត្តកម្ម មិនអនុលោមទៅតាមកិច្ចព្រមព្រៀងមជ្ឈត្តការ ឬច្បាប់របស់ប្រទេសដែលធ្វើមជ្ឈត្តកម្មនោះ ឬ (៥) មជ្ឈត្តវិនិច្ឆ័យពុំទាន់មានអានុភាពចាប់បង្ខំទៅលើភាគី ឬត្រូវបានលើកចោលដោយតុលាការមានសមត្ថកិច្ចនៃប្រទេសដែលចេញមជ្ឈត្តវិនិច្ឆ័យនោះ។[19] រីឯករណីទីពីរវិញ គឺផ្អែកសំខាន់ទៅលើតុលាការ ពោលគឺ ប្រសិនបើតុលាការយល់ឃើញថា (១) កម្មវត្ថុនៃវិវាទមិនអាចចរចាបានតាមរយៈមជ្ឈត្តកម្ម ឬ (២) ការទទួលស្គាល់ ឬការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះនឹងនាំឱ្យប្រាសចាកនឹងគោលនយោបាយសាធារណៈនៃប្រទេសត្រូវអនុវត្តនោះ។[20]

ដូចនេះ ស្របទៅតាមកម្មវត្ថុនៃការស្រាវជ្រាវរបស់សារណានេះ គឺជំពូកទីប្រាំបីនៃច្បាប់គម្រូនេះ គឺជាថ្នាលពុទ្ធិសំខាន់ជុំវិញបញ្ហាដែលទាក់ទងទៅនឹងការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ លើសពីនេះទៅទៀត បញ្ញត្តិទាំងឡាយក្នុងច្បាប់នេះ ត្រូវបានឆ្លុះបញ្ចាំងនូវការសម្រេចជារួមដ៏ល្អប្រពៃ ដែលទាមទារឱ្យមានការប្រកាន់ខ្ជាប់ជាគោល ក្នុងការប្រើប្រាស់នូវដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមបែបមជ្ឈត្តកម្មនេះ។ ហើយការអនុវត្តផងដែរនោះ ត្រូវតែអនុលោមឱ្យបានត្រឹមត្រូវ និងជិតស្និតបំផុត នឹងអនុសញ្ញាទីក្រុងញូវយក ចំពោះកិច្ចនីតិវិធីនៃការអនុវត្តមជ្ឈត្តវិនិច្ឆ័យផ្នែកពាណិជ្ជកម្មទាំងឡាយ។

## ១.២. លិខិតបទដ្ឋានគតិយុត្តជាតិ

របបគតិយុត្តមនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា គឺមានលិខិតបទដ្ឋានគតិយុត្តជាគោលចំនួនប្រាំ ដែលនឹងត្រូវលើកយកមកបកស្រាយនៅខាងក្រោម។ ការលើកយកនូវលិខិតបទដ្ឋានគតិយុត្តទាំងប្រាំមកបកស្រាយ គឺជាការយោងទៅ តាមការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា និងតាមរយៈការពន្លិចចេញជាបញ្ញត្តិក្នុងច្បាប់ និងលិខិតបទដ្ឋាននានាដែលមានជាធរមាន នៅកម្ពុជាផងដែរ។ លិខិតបទដ្ឋានគតិយុត្តជាតិទាំងប្រាំនោះរួមមាន៖ ក្រមនីតិវិធីរដ្ឋប្បវេណី[21] និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី (២.១.) ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (២.២.) ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាទីក្រុងញូវយក (២.៣.) អនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (២.៤.) និង វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (២.៥.)។

[19] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៣៦(១)(ក)។

[20] *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៣៦(១)(ខ)។

[21] សៀវភៅ មេធាវី ខៀវ មាលី, ទំព័រទី ១៤៥។

### ១.២.១. ក្រមនីតិវិធីរដ្ឋប្បវេណី

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចូលជាធរមាននៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៦ និងមានអានុភាពអនុវត្តមួយឆ្នាំក្រោយការចូលជាធរមាននៃច្បាប់នេះ។[22] ក្រមនេះ ជាច្បាប់នីតិវិធីគោលមួយ ដែលគ្រប់គ្រងទៅលើទំនាក់ទំនងផ្នែករដ្ឋប្បវេណីនៅក្នុងព្រះរាជាណាចក្រកម្ពុជា តួយ៉ាងមាន បណ្ដឹងរដ្ឋប្បវេណី ដែលអនុលោមទៅតាមច្បាប់នេះ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា[23] ផងដែរ។[24] ក្រមនីតិវិធីរដ្ឋប្បវេណី មានចំនួន ៥៨៨ មាត្រា ដែលក្នុងនោះបែងចែកជាប្រាំបួន (៩) គន្ថី រួមមាន គន្ថីទី១ ស្ដីពីបទបញ្ញត្តិទូទៅ គន្ថីទី២ ស្ដីពីនីតិវិធីនៃការជម្រះក្ដីលើកទី១ គន្ថីទី៣ ស្ដីពីបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គន្ថីទី៤ ស្ដីពីការជំនុំជម្រះសាជាថ្មី គន្ថីទី៥ ស្ដីពីនីតិវិធីដាស់តឿន គន្ថីទី៦ ស្ដីពីការអនុវត្តដោយបង្ខំ គន្ថីទី៧ ស្ដីពីការចាត់ចែងរក្សាការពារ គន្ថីទី៨ ស្ដីពីអន្តរបញ្ញត្តិ និងគន្ថីទី៩ ស្ដីពីអវសានបញ្ញត្តិ។ ក្នុងចំណោមគន្ថីទាំងប្រាំបួន មាននូវបញ្ញត្តិទាក់ទងទៅនឹង សេចក្ដីសម្រេចមជ្ឈត្តការ មានចំនួនពីរ មាត្រា នៅក្នុងគន្ថីទី៦ ស្ដីពីការអនុវត្តដោយបង្ខំ។ មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានលើកឡើងអំពី លិខិតអនុវត្ត ដែលច្បាប់ក្នុងប្រទេសកម្ពុជាទទួលស្គាល់នូវ សេចក្ដីសម្រេចមជ្ឈត្តការ ជាលិខិតអនុវត្ត តាមរយៈដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរតាមបញ្ញត្តិនៃ មាត្រា ៣៥៣។[25] បើធ្វើការគ្រលេកទៅមើល មាត្រា ៣៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីវិញ គឺមានចែងជារូបមន្តនៃការអនុវត្តសេចក្ដីសម្រេចមជ្ឈត្តការ តាមដីកាសម្រេចអនុវត្តសេចក្ដីសម្រេចមជ្ឈត្តការ។[26] មាត្រា ៣៥៣ បានចែងនូវបញ្ញត្តិសំខាន់ៗ ចំនួន ៨ប់ កថាខណ្ឌ ទៅលើបញ្ហាជុំវិញការអនុវត្តដីកានេះ។ កថាខណ្ឌទីមួយនៃមាត្រា ៣៥៣ ចែងថា ក្នុងការអនុវត្តដោយបង្ខំដោយផ្អែកលើសេចក្ដីសម្រេចមជ្ឈត្តការ ឬមជ្ឈត្តវិនិច្ឆ័យ ដោយពុំគិតទៅលើការដាក់ចេញដោយមជ្ឈត្តការក្នុងស្រុក ឬបរទេស គឺចាំបាច់ទាមទារឱ្យមាន ការសម្រេចឱ្យអនុវត្ត តាមរយៈដីកានេះ ដោយតុលាការនៅព្រះរាជាណាចក្រកម្ពុជា។[27] កថាខណ្ឌទីពីរនៃមាត្រាដដែល បន្តបញ្ជាក់នូវបែបបទនៃ ការដាក់ពាក្យសុំ ឱ្យចេញដីកាសម្រេចអនុវត្ត

---

22 ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៧០៦/០២១, ប្រកាសឱ្យប្រើនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ (តទៅនេះហៅថា «ក្រមនីតិវិធីរដ្ឋប្បវេណី»), មាត្រា ៥៨៧។

23 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/១២០៧/០៣០, ប្រកាសឱ្យប្រើនៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ (តទៅនេះហៅថា «ក្រមរដ្ឋប្បវេណី»)។

24 *ក្រមនីតិវិធីរដ្ឋប្បវេណី*, មាត្រា ១។

25 *ក្រមនីតិវិធីរដ្ឋប្បវេណី*, មាត្រា ៣៥០។

26 *ក្រមនីតិវិធិរដ្ឋប្បវេណី*, មាត្រា ៣៥៣។

27 *ក្រមនីតិវិធិរដ្ឋប្បវេណី*, មាត្រា ៣៥៣(១)។

មជ្ឈត្តវិនិច្ឆ័យ ដែលតម្រូវឱ្យដាក់ជូននូវ (១) ច្បាប់ដើមនៃសេចក្តីសម្រេចមជ្ឈត្តការ ឬច្បាប់ចម្លងដោយមានសេចក្តីបញ្ជាក់ត្រឹមត្រូវ និង (២) ច្បាប់ដើមនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ឬច្បាប់ចម្លងដោយមានសេចក្តីបញ្ជាក់ត្រឹមត្រូវ។[28] ចំពោះចំណុចនេះ ជាពិសេសនោះបញ្ញត្តិនេះគឺមានភាពបន្សុីគ្នាជាមួយ នឹង*ច្បាប់គម្រូស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* ដូចដែលបានជម្រាបជូននៅចំណុចខាងដើម។ យ៉ាងណាមិញ ចំពោះកថាខណ្ឌទីបី និងទីបួននៃមាត្រា ៣៥៣ បានបន្តចែងនូវបទដ្ឋានក្នុងការបដិសេធការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ដែលក្នុងនោះ មានការបដិសេធចំពោះការអនុវត្ត តាមសំអាងបញ្ជាក់របស់ភាគី និងតាមការយល់ឃើញរបស់តុលាការ។[29] គួរបញ្ជាក់ផងដែរថា កថាខណ្ឌទីប្រាំពីរបានកំណត់បន្តថា ប្រសិនបើការអនុវត្តនោះត្រូវបានអាក់ខានដោយមានអត្ថិភាពនៃការអនុវត្តកថាខណ្ឌទីបី ឬកថាខណ្ឌទីបួន នោះនាំឱ្យមានការស្រាវជ្រាវអំពីភាពត្រឹមត្រូវ មុនធ្វើការចេញដីកាសម្រេចអនុវត្ត។ ចំពោះកថាខណ្ឌទីប្រាំ គឺផ្តោតសំខាន់ទៅលើការអនុវត្តមជ្ឈត្តវិនិច្ឆ័យក្នុងប្រទេស ដែលទាមទារឱ្យការអនុវត្តស្ថិតនៅក្រោមសមត្ថកិច្ចសាលាដំបូងនៃទីលំនៅរបស់កូនបំណុល ឬទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬទ្រព្យរបស់កូនបំណុលដែលអាចរឹបអូសបាន ស្ថិតនៅ។[30] ចំណែកឯ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសវិញ គឺត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដូចមានចែងនៅកថាខណ្ឌទី៦ នៃមាត្រា ៣៥៣។[31] បន្ថែមពីលើនេះ កថាខណ្ឌទីប្រាំបី កំណត់ឱ្យតុលាការ ត្រូវតែប្រកាសអនុញ្ញាតឱ្យអនុវត្តនូវដីកាសម្រេចអនុវត្តនោះ ដោយបង្ខំ ដោយបើកសិទ្ធិឱ្យមានការធ្វើបណ្តឹងជំទាស់ទៅលើដីកាសម្រេចនេះ បើយោងតាមកថាខណ្ឌទីប្រាំបួន នៃមាត្រាដដែល។[32] ជាចុងក្រោយបង្អស់គឺ កថាខណ្ឌទីដប់ ដែលកំណត់អំពីអានុភាពអនុវត្តដីកាសម្រេច ដោយទាមទារឱ្យមានការចូលជាស្ថាពរនូវដីកាសម្រេចអនុវត្តនោះសិន ទើបមានអានុភាពអនុវត្តដោយបង្ខំ។[33]

### ១.២.២. ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃ០៥ ខែឧសភា ឆ្នាំ២០០៦ ដែលមានគោលបំណង ក្នុងការសម្របសម្រួលដល់ការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលការណ៍ស្ម័គ្រចិត្តរបស់ភាគីវិវាទ ដើម្បីការពារសិទ្ធិ និង

---

[28] *ក្រមនីតិវិធីរដ្ឋប្បវេណី,* មាត្រា ៣៥៣(២)។

[29] *សូមមើល* ផ្នែកទី១ កថាភាគីទី ១ ចំណុច ១.១. *ច្បាប់គម្រូនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*។

[30] *ក្រមនីតិវិធីរដ្ឋប្បវេណី,* មាត្រា ៣៥៣(៥)។

[31] *ក្រមនីតិវិធីរដ្ឋប្បវេណី,* មាត្រា ៣៥៣(៦)។

[32] *ក្រមនីតិវិធីរដ្ឋប្បវេណី,* មាត្រា ៣៥៣(៨) និងមាត្រា ៣៥៣(៩)។

[33] *ក្រមនីតិវិធីរដ្ឋប្បវេណី,* មាត្រា ៣៥៣(១០)។

ផលប្រយោជន៍របស់ភាគីវិវាទក្នុងវិស័យពាណិជ្ជកម្ម។[34] នៅក្នុងច្បាប់នេះ គឺមានចំនួន ៤៧ មាត្រា បែងចែកជាប្រាំបួន (៩) ជំពូក តួយ៉ាងមានដូចជា៖ ជំពូកទី១ ស្តីពីបញ្ញត្តិទូទៅ ជំពូកទី២ ស្តីពីកិច្ចព្រមព្រៀងផ្សះផ្សា ជំពូកទី៣ ស្តីមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំពូកទី៤ ស្តីពីសមាសភាពនៃវេទិកាមជ្ឈត្តការ ជំពូកទី៥ ស្តីពីសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តការ ជំពូកទី៦ ស្តីពីដំណើរការនៃនីតិវិធីមជ្ឈត្តការ ជំពូកទី៧ ស្តីពីការធ្វើមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តការនិងការបញ្ចប់ដំណើរការមជ្ឈត្តការ ជំពូកទី៨ ស្តីពីការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ និងជំពូកទី៩ ស្តីពីអវសានបញ្ញត្តិ។ ក្នុងច្បាប់នេះបានកំណត់នូវនិយមន័យនៃបច្ចេកសព្ទពាក់ព័ន្ធទៅនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក៏ដូចជាវិធាននានាដែលចាំបាច់ក្នុងកិច្ចនីតិវិធីមជ្ឈកម្មផងដែរ។ ក្នុងនោះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មានចែងនូវបញ្ញត្តិនានា ដោយឈរលើគោលការណ៍សំខាន់ៗរួមមាន[35]៖ (១) ការមិនមានភាពលំអៀង មិនមានភាពយឺតយ៉ាវ និងមិនមានចំណាយដែលចាំបាច់ (២) សិទ្ធិសេរីភាពពេញលេញរបស់គូភាគី (៣) ប្រកាន់ខ្ជាប់នូវគោលការណ៍ទូទៅជុំវិញពិភពលោក[36] និង (៤) ឯករាជ្យភាពក្នុងការដោះស្រាយវិវាទ ដោយមិនមានការជ្រៀតជ្រែកក្នុងការសម្រេចក្តីដោយតុលាការ ឬរាជរដ្ឋាភិបាល។[37] ជាពិសេសនោះ ច្បាប់នេះ គឺជាមូលដ្ឋានគតិយុត្ត ដែលនាំមកនូវការបង្កើតឱ្យមានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម តាមរយៈជំពូកទី៣ នៃច្បាប់ផងដែរ។[38]

ចំពោះ ការបកស្រាយនូវបញ្ញត្តិនៃច្បាប់នេះ នឹងបន្តបកស្រាយនូវក្នុងជំពូកបន្តបន្ទាប់ទៀតនៃអត្ថបទសារណានេះ ដើម្បីបង្ហាញជារួម ដោយភ្ជាប់ជាមួយគ្នានឹងនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មតែម្តង។ យ៉ាងណាមិញ ក្នុងផ្នែកទី២នេះ ការសិក្សានឹងបន្តមើលបន្ថែមនូវលិខិតបទដ្ឋានគតិយុត្តជាតិដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.២.៣. ច្បាប់ស្តីពីការយល់ព្រម និងអនុវត្តអនុសញ្ញាទីក្រុងញូវយក

ជាគោលការណ៍ និងយន្តការច្បាប់នៃការបង្កើតច្បាប់នៅព្រះរាជាណាចក្រកម្ពុជាគឺ មានចំនួនពីរ តួយ៉ាង តាមការអនុម័តដោយសភាតាមរយៈការស្នើច្បាប់ដោយរាជរដ្ឋាភិបាល និងការអនុម័តដោយសភា

[34] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១។

[35] *សូមមើល សៀវភៅ មេធាវី ខៀវ មាលី*, ទំព័រ ១៤៥។

[36] គួរបញ្ជាក់ផងដែរថា ចំពោះគោលការណ៍ទូទៅជុំវិញពិភពលោកនេះ គឺសម្តៅដល់ធាតុសំខាន់ៗដែលមានក្នុងប្រព័ន្ធមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ។ ក្នុងនោះរួមមាន ការអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ ដំណើរការនៃការគ្រប់គ្រងរបស់ភាគីវិវាទ អព្យាក្រឹត្យភាព ឯកជនភាព ការរក្សាសម្ងាត់ ចំណាយថវិកាតិច និងចំណាយពេលវេលាតិច។

[37] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១ និង មាត្រា ២។ *សូមមើលបន្ថែម សៀវភៅ មេធាវី ខៀវ មាលី*, ទំព័រ ១៤៥។

[38] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, ជំពូកទី៣, មាត្រា ១០ រហូតដល់ មាត្រា ១៧។

តាមរយៈការប្រើប្រាស់នូវសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិមកប្រើប្រាស់ជាច្បាប់ជាតិតែម្តង។ យ៉ាងណាមិញ ក្នុងករណីនៃការបង្កើតច្បាប់ស្តីពីការយល់ព្រម និងអនុវត្តអនុសញ្ញាទីក្រុងញូវយកនេះ គឺត្រូវបានអនុម័តឡើងក្រោយការចូលជាសមាជិកនៃអនុសញ្ញានេះនាឆ្នាំ២០០១។ ច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើជាប្រញ្ញាប់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១។[39] សវតានៃច្បាប់នេះ ប្រសិនបើយោងទៅលើប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាវិញ គឺប្រទេសកម្ពុជាបានទទួលស្គាល់ និងចូលជាសមាជិកនៃអនុសញ្ញានេះតាំងតែពី ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៦០ ក្រោយអនុសញ្ញាទីក្រុងញូវយក ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី១០ ខែ មិថុនា ឆ្នាំ១៩៥៨ បានអនុម័តឡើងមកម្ល៉េះ។[40] ប៉ុន្តែ ដោយសារតែភ្លើងសង្គ្រាមក្នុងស្រុក ក៏ដូចជាអស្ថេរភាពនៃស្ថានភាពក្នុងប្រទេស រាល់ដំណោះស្រាយវិវាទតាមមជ្ឈត្តការក៏បានប្រែជាស្ងៀមស្ងាត់។ រហូតដល់ដើមសតវត្សទី២១ នៅពេលដែលព្រះរាជាណាចក្រកម្ពុជា មានសន្តិភាព និងស្ថេរភាពសង្គមឡើងវិញ ក្រោមការដឹកនាំដ៏វៃឆ្លាតរបស់រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងជម្រុញ ឱ្យមានការលើកស្ទួយលើគ្រប់វិស័យក្នុងប្រទេស ក្នុងនោះក៏មានវិស័យពាណិជ្ជកម្មផងដែរ។ តាមរយៈការងើបឈរឡើងវិញពីខិនភាពនៃសង្គមកម្ពុជា កាលពីចុងសតវត្សទី២០ នោះបានធ្វើឱ្យកម្ពុជាសម្រេចចិត្តធ្វើការបញ្ជាក់សារជាថ្មីជាមួយនឹង អនុសញ្ញាដែលកម្ពុជាធ្លាប់ជារដ្ឋហត្ថលេខីនោះដើម្បីបង្ហាញអំពីការទទួលស្គាល់នូវអនុសញ្ញាទាំងនោះ ហើយក្នុងនោះផងដែរ នៅឆ្នាំ២០០១ ព្រះរាជាណាចក្រកម្ពុជា ក៏បានធ្វើការបញ្ជាក់ឡើងវិញផងដែរចំពោះ ការទទួលស្គាល់អនុសញ្ញាទីក្រុងញូវយក ដូចធ្លាប់បានទទួលស្គាល់កាលពីឆ្នាំ១៩៦០។[41]

ច្បាប់ស្តីពីការយល់ព្រមនិងអនុវត្តអនុសញ្ញាទីក្រុងញូវយក មានមាត្រាសរុប ចំនួន ២៧ មាត្រា ដែលមានបែងចែកជាប្រាំបី (៨) ជំពូក រួមមានជាអាទ៍៖ ជំពូកទី១ ស្តីពីបទបញ្ញត្តិទូទៅ ជំពូកទី២ ស្តីពីនិយមន័យ ជំពូកទី៣ ស្តីពីសមត្ថកិច្ចនិងដែនអនុវត្ត ជំពូកទី៤ ស្តីពីនីតិវិធី ជំពូកទី៥ ស្តីពីមូលដ្ឋានដើម្បីបដិសេធការទទួលស្គាល់ឬ/និងការប្រតិបត្តិ ជំពូកទី៦ ស្តីពីសិទ្ធិអំណាចនិងសមាសភាពសាលាឧទ្ធរណ៍ ជំពូកទី៧ ស្តីពីសិទ្ធិអំណាចនិងសមាសភាពតុលាការកំពូល និងជំពូកទី៨ ស្តីពីអវសានបញ្ញត្តិ។ ជាគោលគំនិតសំខាន់នៃច្បាប់នេះគឺជាការបញ្ជាក់បន្ថែមថា បទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ គឺមានអានុភាពអនុវត្តតែទៅលើករណីនៃមជ្ឈត្តករបរទេសតែប៉ុណ្ណោះនោះទេ ពោលគឺ ប្រសិនបើការអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា

---

[39] ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់នឹងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តការបរទេស, នស/រកម/០៧០១/១០, ប្រកាសឱ្យប្រើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ (តទៅនេះហៅថា «*ច្បាប់ស្តីពីការយល់ព្រមនិងអនុវត្តអនុសញ្ញាទីក្រុងញូវយក*»)។

[40] *ច្បាប់ស្តីពីការយល់ព្រមនិងអនុវត្តអនុសញ្ញាទីក្រុងញូវយក*, មាត្រា ១។

[41] *ច្បាប់ស្តីពីការយល់ព្រមនិងអនុវត្តអនុសញ្ញាទីក្រុងញូវយក*, មាត្រា ១។

មានតែច្បាប់នេះទេដែលមានប្រសិទ្ធភាពក្នុងការអនុវត្ត លើកលែងការអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យក្នុងស្រុក ដែលជាដោយមជ្ឈត្តករក្នុងព្រះរាជាណាចក្រកម្ពុជា។[42]

### ១.២.៤. អនុក្រឹត្យ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

យោងតាម ជំពូកទី៣នៃច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា បានជម្រុញឱ្យមានការបង្កើតនូវមជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្ម តាមរយៈ អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។[43]

អនុក្រឹត្យនេះជាច្បាប់អង្គិនរបស់ មជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (តទៅនេះហៅកាត់ថា «*ម.ជ.ម.*») ដែលមជ្ឈមណ្ឌលជាតិនេះជាអង្គភាពមានកម្មវត្ថុមិនស្វែងរកប្រាក់ចំណេញ និងជាវេទិកាសម្រាប់ដោះស្រាយនូវវិវាទក្រៅផ្លូវតុលាការទាក់ទងទៅនឹងវិស័យពាណិជ្ជកម្ម។[44] អនុក្រឹត្យនេះ បានតាក់តែងឡើងដោយមានចំនួនសរុប ៥៦ មាត្រា បែងចែកជាប្រាំពីរ (៧) ជំពូក រួមមាន៖ ជំពូកទី១ ស្តីពីបទបញ្ញត្តិទូទៅ ជំពូកទី២ ស្តីពីតួនាទី និងភារកិច្ច ជំពូកទី៣ ស្តីពីរចនាសម្ព័ន្ធ ជំពូកទី៤ ស្តីពីប្រភពធនធាន ជំពូកទី៥ ស្តីពីការជ្រើសរើសមជ្ឈត្តករដំបូង ជំពូកទី៦ ស្តីពីអន្តរបញ្ញត្តិ និងជំពូកទី៧ ស្តីពីអវសានបញ្ញត្តិ។ យោងតាមអនុក្រឹត្យនេះ មាត្រា ២ បានកំណត់នូវតួនាទីនិងភារកិច្ចរបស់ *ម.ជ.ម.* តួយ៉ាង ជាមជ្ឈមណ្ឌលជាតិដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ តាមបែបមជ្ឈត្តការ ជាមជ្ឈមណ្ឌលជាតិក្នុងការបណ្តុះបណ្តាលមជ្ឈត្តករ ជាអ្នករៀបចំសន្និសីទថ្នាក់ជាតិនិងអន្តរជាតិជុំវិញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម រួមទាំងជាតួអង្គដ៏សំខាន់ក្នុងការប្រមូល បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធ សៀវភៅ និងឯកសារពាក់ព័ន្ធនានា ដែលទាក់ទងទៅនឹងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ។[45] *ម.ជ.ម.* ត្រូវបានកំណត់នូវរចនាសម្ព័ន្ធដោយមាន មហាសន្និបាតជាសិទ្ធិអំណាចកំពូល និងក្រុមប្រឹក្សាប្រតិបត្តិជាអ្នកគ្រប់គ្រង និងសម្រេចកិច្ចការងារប្រចាំថ្ងៃ។[46] សមាសភាពនៃក្រុមប្រឹក្សាប្រតិបត្តិ គឺត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតរៀងរាល់ ៣ឆ្នាំ ម្តង ក្នុងចំណោមសមាជិកនៃ

[42] *ច្បាប់ស្តីពីការយល់ព្រមនិងអនុវត្តអនុសញ្ញាទីក្រុងញូវយក*, មាត្រា ២៦។

[43] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, ជំពូកទី៣, មាត្រា ១០ រហូតដល់ មាត្រា ១៧។ *សូមមើលបន្ថែម* អនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (តទៅនេះហៅថា «*អនុក្រឹត្យបង្កើត ម.ជ.ម.*») លេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។

[44] *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ១។

[45] *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ២។

[46] *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ៣ និង មាត្រា ៨ ។

ម.ជ.ម. ដោយមហាសន្និបាត ដោយសម្រេចយក ប្រធាននៃក្រុមប្រឹក្សាប្រតិបត្តិ ជាប្រធាននៃ *ម.ជ.ម.*។[47] គួរបញ្ជាក់ផងដែរថា សមាជិកនៃ *ម.ជ.ម.* គឺសម្តៅដល់មជ្ឈត្តករទាំងឡាយដែលបានចុះបញ្ជីជាមជ្ឈត្តករនៅ *ម.ជ.ម.* ដោយបានបំពេញលក្ខខណ្ឌនានាដូចមានចែងក្នុងជំពូកទី៣ ផ្នែកទី៤ នៃអនុក្រឹត្យនេះ។[48] លើសពីនេះទៅទៀត ដើម្បីឆ្លើយតបទៅនឹងកម្មវត្ថុចំបងនៃ*ម.ជ.ម.* ក្នុងការមិនស្វែងរកប្រាក់ចំណេញនោះ ប្រភពធនធានរបស់ *ម.ជ.ម.* គឺបានមកពីភាគទានរបស់សមាជិក អំណោយនិងវិភាគទានផ្សេងៗ រួមទាំងកម្រៃសេវារដ្ឋបាលរបស់ *ម.ជ.ម.* ដែលបានមកតាមរយៈការបង់កម្រៃសេវាដោយអ្នកប្រើប្រាស់សេវាមជ្ឈត្តកម្មនេះ។[49]

ចំពោះប្រភពធនធាន *ម.ជ.ម.* ទទួលបានពីការចូលភាគទានប្រចាំឆ្នាំដោយសមាជិក ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ពោលគឺ សមាជិកត្រូវបង់តាមចំនួនទឹកប្រាក់ដែលបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ នៅមហាសន្និបាត ដោយបង់ជាមុន ក្នុងអំឡុងខែទីមួយរៀងរាល់ឆ្នាំ និងមិនឱ្យមានភាពយឺតយ៉ាវក្នុងការបង់លើសពីបីខែ ដែលវាអាចធ្វើឱ្យសមាជិកដែលបង់យឺតយ៉ាវនោះ បាតបង់នូវសមាជិកភាព ជាមជ្ឈត្តករនៅ *ម.ជ.ម.*។[50] គួរបញ្ជាក់បន្ថែមទៀតផងដែរថា ក្រោយអនុក្រឹត្យនេះ បានចូលជាធរមាន គ្រប់បញ្ញត្តិដែលចែងក្នុងអនុក្រឹត្យត្រូវបានយកទៅអនុវត្ត តាមការទទួលបន្ទុករៀងៗខ្លួននៃបុគ្គលដែលត្រូវបានផ្តល់នូវនីតិសម្បទាតាមរយៈអនុក្រឹត្យនេះ។[51] យ៉ាងណាមិញ លុះដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ អនុក្រឹត្យលេខ១២៤ អនក្រ.បក នេះត្រូវធ្វើវិសោធនកម្មទៅលើ មាត្រា ៥២ នៃ*អនុក្រឹត្យបង្កើតម.ជ.ម.* ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃការជ្រើសរើសមជ្ឈត្តករ រួមទាំងអនុលោមភាពទៅតាមលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធផងដែរ។ អនុក្រឹត្យកែសម្រួលមាត្រា៥២ នៃ*អនុក្រឹត្យបង្កើតម.ជ.ម.*[52] បានធ្វើការកែសម្រួលមាត្រា ៥២ដើម ដែលបានបញ្ញត្តិថា «បុគ្គលដែលត្រូវបានជ្រើសរើសដំបូង មិនតិចជាង៥០ (ហាសិប) រូប ត្រូវដាក់ពាក្យសុំធ្វើជាមជ្ឈត្តករនៅ *ម.ជ.ម.* ក្រោយពីបានបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម»[53] ទៅជា «បុគ្គលដែលត្រូវបានជ្រើសរើសដំបូងមិនតិចជាង ៥០ (ហាសិប) រូប *ក្រោយពីបានឆ្លងកាត់វគ្គបណ្តុះបណ្តាល» និងទទួលជោគជ័យពីការ*

---

47 *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ៨, មាត្រា ៩, មាត្រា ១២, និង មាត្រា ១៤។

48 *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ២៨ រហូតដល់ មាត្រា ៣៨។ *សូមមើលបន្ថែម* ឧបសម្ព័ន្ធទី១ ស្តីពីសមាជិកភាពនៃម.ជ.ម.។

49 *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ៤២។

50 *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ៤៣។

51 *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ៥៤ និង មាត្រា ៥៦។

52 អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៥២ នៃអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម លេខ ១៨២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០។ (តទៅនេះហៅថា «*អនុក្រឹត្យកែសម្រួល មាត្រា៥២នៃអនុក្រឹត្យបង្កើតម.ជ.ម.*»)។

53 *អនុក្រឹត្យបង្កើត ម.ជ.ម.*, មាត្រា ៥២។

*ប្រឡង ទើបអាចដាក់ពាក្យសុំធ្វើជាមជ្ឈត្តករនៅ ម.ជ.ម. បាន»*[54]។ ការកែសម្រួលនេះ គឺដើម្បីធ្វើការចម្រាញ់យកនូវមជ្ឈត្តករដែលបានទទួលការបណ្ដុះបណ្ដាលមូលដ្ឋាន និងហ្វឹកហ្វឺនបានល្អិតល្អន់ដោយ ក្រសួងពាណិជ្ជកម្ម មុនដាក់ពាក្យស្នើសុំធ្វើជាមជ្ឈត្តករនៅ *ម.ជ.ម.*។ ការណ៍ដែលធ្វើបែបនេះ ក៏ដើម្បីពង្រឹងសមត្ថភាព និងចំណេះដឹងនៃមជ្ឈត្តករឱ្យបានទូលំទូលាយ និងជាក់លាក់ទៅលើវិស័យពាណិជ្ជកម្ម ក៏ដូចជាវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មផងដែរ។

ជារួមមក *អនុក្រឹត្យបង្កើត ម.ជ.ម.* គឺជាលិខិតបទដ្ឋានគតិយុត្តគោលមួយក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលមានជាបញ្ញត្តិមូលដ្ឋានក្នុងកិច្ចដំណើរការប្រព្រឹត្តទៅរបស់ *ម.ជ.ម.* ក៏ដូចជាបុគ្គលដែលមានបំណង ឬជាមជ្ឈត្តករស្រាប់នោះ ក្នុងការពង្រឹង និងពង្រីកវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មឱ្យមានសង្គតិភាព និងមានតម្លាភាពតរៀងទៅ។

### ១.២.៥. វិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

វិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានរៀបចំឡើង និងប្រកាសឱ្យប្រើដំបូងបំផុតនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤។[55] *វិធានម.ជ.ម. ចាស់* នេះមានសរុបចំនួន ៥៧ វិធាន ដែលក្នុងនោះត្រូវបានបែងចែកជាប្រាំបី (៨) ជំពូក រួមមាន ជំពូកទី១ ស្ដីពីវិធានទូទៅ ជំពូកទី២ ស្ដីពីការចាប់ផ្ដើមមជ្ឈត្តកម្ម ជំពូកទី៣ ស្ដីពីការបង្កើតវេទិកាមជ្ឈត្តការ ជំពូកទី៤ ស្ដីពីដំណើរការមជ្ឈត្តការ ជំពូកទី៥ ស្ដីពីការសម្រេច និងមជ្ឈត្តវិនិច្ឆ័យ ជំពូកទី៦ ស្ដីពីកម្រៃសេវា ជំពូកទី៧ ស្ដីពីបទបញ្ញត្តិផ្សេងៗ និងជំពូកទី៨ ស្ដីពីអវសានបញ្ញត្តិ។ យ៉ាងណាមិញ ដោយសារតែវិធានចាស់នេះ ត្រូវបានជំនួសដោយវិធានថ្មី ហេតុដូចនេះ ចាំបាច់នឹងធ្វើការពិនិត្យមើលទៅលើវិធានថ្មីតែម្ដង។ វិធានស្ដីពីមជ្ឈត្តការថ្មី ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ និងត្រូវបានកំណត់ឱ្យចូលជាធរមានចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ តទៅ។[56] *វិធាន ម.ជ.ម. ថ្មី* នេះ បានធ្វើវិសោធនកម្មទៅលើ *វិធាន ម.ជ.ម. ចាស់* ដោយអនុញ្ញាតឱ្យ *ម.ជ.ម.* អាចចាត់ចែងសំណុំរឿងមជ្ឈត្តការ និងផ្ដល់សេវាកម្មផ្សេងៗ ដោយឆ្លើយតបទៅនឹងបច្ចុប្បន្នភាពនៃតម្រូវការរបស់អ្នកប្រើប្រាស់សេវាមជ្ឈត្តការនេះ។[57] មូលហេតុនៃការធ្វើវិសោធនកម្មនេះគឺ (១) ដើម្បីឱ្យអ្នកប្រើប្រាស់មានភាពសមស្របក្នុង

---

[54] *អនុក្រឹត្យកែសម្រួល មាត្រា៥២នៃអនុក្រឹត្យបង្កើតម.ជ.ម*, មាត្រា ៥២ថ្មី។

[55] វិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ (តទៅនេះហៅថា *«វិធាន ម.ជ.ម. ចាស់»*)។

[56] វិធានស្ដីពីមជ្ឈត្តការ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ (តទៅនេះហៅថា *«វិធាន ម.ជ.ម. ថ្មី»*)។

[57] *វិធាន ម.ជ.ម. ថ្មី*, បុព្វកថា, ទំព័រទី២។

ការទទួលយកវិធានដែលមានលក្ខណៈអន្តរជាតិ (២) ដើម្បីផ្តល់នូវប្រសិទ្ធភាពនិងភាពបត់បែនល្អជាងមុន ចំពោះនីតិវិធីមជ្ឈត្តកម្មនៃ*ម.ជ.ម.* (៣) ដើម្បីធ្វើបច្ចុប្បន្នភាពនៃវិធានតាមកំណែទម្រង់ថ្មីរបស់ប្រព័ន្ធមជ្ឈត្តការអន្តរជាតិ និង (៤) ដើម្បីបន្ថែមនូវយន្តការថ្មីៗក្នុងការដោះស្រាយវិវាទដោយ*ម.ជ.ម.* ផងដែរ។[58]

*វិធានម.ជ.ម. ថ្មី* មានសរុបចំនួន ៧៤ ប្រការ បែងចែកជាប្រាំបួន (៩) ជំពូក រួមមាន៖ ជំពូកទី១ ស្តីពីវិធានទូទៅ ជំពូកទី២ ស្តីពីការចាប់ផ្តើមមជ្ឈត្តកម្ម ជំពូកទី៣ ស្តីពីមជ្ឈត្តករបន្ទាន់ ជំពូកទី៤ ស្តីពីការបង្កើតវេទិកាមជ្ឈត្តការ ជំពូកទី៥ ស្តីពីដំណើរការមជ្ឈត្តការ ជំពូកទី៦ ស្តីពីការសម្រេច និងមជ្ឈត្តវិនិច្ឆ័យ ជំពូកទី៧ ស្តីពីកម្រៃសេវា ជំពូកទី៨ ស្តីពីបទបញ្ញត្តិផ្សេងៗ និងជំពូកទី៩ ស្តីពីអវសានបញ្ញត្តិ។ ក្នុងការធ្វើវិសោធនកម្មនេះមាន ចំនួន ដប់ ចំណុច ដែលត្រូវបានធ្វើវិសោធនកម្ម។ ក្នុងនោះរួមមាន (១) ប្រការ២.១ ស្តីពីការអនុវត្តវិធាននេះ ការអនុវត្តវិធានដទៃ និងសេវាផ្សេងៗ (២) ប្រការ៣ ការតំណាង (៣) ប្រការ៤.៣ ស្តីពីការបញ្ជូន និងការទទួល (៤) ប្រការ៥.១ ស្តីពីការគណនាអំឡុងពេល (៥) ប្រការ៥.២ ការកែប្រែពេលវេលាកំណត់ (៦) ប្រការ៧.៨ ស្តីពីការចាប់ផ្តើមដំណើរការមជ្ឈត្តការ (៧) ប្រការ៣៤.១ ស្តីពីយុត្តាធិការរបស់ម.ជ.ម. (៨) ប្រការ៣៧.២ ស្តីពីសេចក្តីថ្លែងទាមទារ រួមទាំង ប្រការ៣៧.៣ សេចក្តីថ្លែងដោះសារ និងបណ្តឹងតប (៩) ប្រការ៣៩.១ ស្តីពីសវនាការ និង (១០) ប្រការ៤៤ ស្តីពីការបញ្ចប់ និងការបើកដំណើរការមជ្ឈត្តការជាថ្មី។[59] លើសពីនេះទៅទៀត *វិធាន ម.ជ.ម. ថ្មី* មិនត្រឹមតែបានធ្វើវិសោធនកម្មទៅលើវិធានចាស់នោះទេ ក៏ប៉ុន្តែក៏បានបន្ថែមនូវយន្តការថ្មីដូចជា នីតិវិធីពន្លឿន និងមជ្ឈត្តករបន្ទាន់ផងដែរ។[60] នីតិវិធីពន្លឿន គឺជានីតិវិធីមជ្ឈត្តការថ្មីក្នុង*វិធានម.ជ.ម.ថ្មី* ដែលជួយសម្រួលដល់គូភាគីវិវាទឱ្យចំណាយពេលវេលា និងប្រាក់កាសតិចជាងនីតិវិធីធម្មតា។ នីតិវិធីពន្លឿន គឺមានរយៈពេលកំណត់លឿនជាងនីតិវិធីធម្មតា ដោយមានមជ្ឈត្តករចំនួនមួយរូប ឬបីរូប ដើម្បីដោះស្រាយវិវាទ។[61] ចំពោះការអនុវត្តយកនូវនីតិវិធីពន្លឿននេះ គឺទាមទារឱ្យកម្មវត្ថុវិវាទមានតម្លៃមិនលើសពីបីលាន (៣.០០០.០០០) ដុល្លាសហរដ្ឋអាមេរិច និងទាមទារឱ្យមជ្ឈត្តករចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ ក្នុងរយៈពេល

---

[58] សិក្ខាសិលាតាមប្រព័ន្ធអនឡាញ ស្តីពីទិដ្ឋភាពទូទៅនៃវិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ឆ្នាំ ២០២១ រៀបចំដោយ ម.ជ.ម. នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២១ ដែលមាន លោកមជ្ឈត្តការ ប៊ុន យូឌី ប្រធាននៃ ម.ជ.ម. ធ្វើបទឧទ្ទេសនាមនៅក្នុងសិក្ខាសិលាអនឡាញនេះ។

[59] សិក្ខាសិលាតាមប្រព័ន្ធអនឡាញ ស្តីពីទិដ្ឋភាពទូទៅនៃវិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ឆ្នាំ ២០២១ រៀបចំដោយ ម.ជ.ម. នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២១ ដែលមាន លោកមជ្ឈត្តការ ប៊ុន យូឌី ប្រធាននៃ ម.ជ.ម. ធ្វើបទឧទ្ទេសនាមនៅក្នុងសិក្ខាសិលាអនឡាញនេះ។ *សូមមើលបន្ថែម វិធានម.ជ.ម.ថ្មី* , ប្រការ ២.១, ប្រការ ៣, ប្រការ ៤.៣, ប្រការ ៥.១, ប្រការ ៥.២, ប្រការ ៧.៨, ប្រការ ៣៤.១, ប្រការ ៣៧.២, ប្រការ ៣៧.៣, ប្រការ ៣៩.១, និង ប្រការ ៤៤។

[60] *វិធានម.ជ.ម.ថ្មី* , ប្រការ ៩ រហូតដល់ ប្រការ២៣។

[61] *វិធានម.ជ.ម.ថ្មី* , ប្រការ ៩។

២៧០ ថ្ងៃប្រតិទិន បន្ទាប់ពីការចាប់ផ្តើមមជ្ឈត្តការ។[62] បើគ្រលេកមកមើល មជ្ឈត្តករបន្ទាន់វិញ គឺជាវិធានថ្មីមួយក្នុង *វិធាន ម.ជ.ម. ថ្មី* ផងដែរ ដែលមានកម្មវត្ថុក្នុងការដោះស្រាយបញ្ហាជុំវិញវិវាទដែលអាចរងការប៉ះពាល់ ប្រសិនបើរងចាំដល់ការបង្កើតនូវវេទិកាមជ្ឈត្តការរួច។ មជ្ឈត្តករបន្ទាន់ មានសិទ្ធិអំណាចក្នុងការចេញវិធានការបណ្តោះអាសន្ន មុនពេលវេទិកាមជ្ឈតការបង្កើត។ ដើម្បីឆ្លើយតបទៅនឹងភាពបន្ទាន់នេះ *វិធាន ម.ជ.ម. ថ្មី* បានសម្រេចពង្រួញពេលវេលាក្នុងការតែងតាំងមជ្ឈត្តករបន្ទាន់ ដោយគណៈកម្មាធិការតែងតាំងនិងនីតិវិធី មកត្រឹមរយៈពេលយ៉ាងយូរ ៣ ថ្ងៃប្រតិទិន អំឡុងពេលទទួលយកការតែងតាំងដោយមជ្ឈត្តករបន្ទាន់ត្រឹម ២ថ្ងៃប្រតិទិន ដោយគិត អំឡុងពេល ២ថ្ងៃប្រតិទិនក្រោយការតែងតាំងសម្រាប់ការធ្វើកាលវិភាគ និង ១៥ថ្ងៃប្រតិទិន សម្រេប់អំឡុងពេលសម្រាប់ធ្វើការសម្រេចសេចក្តីរបស់មជ្ឈត្តករបន្ទាន់។[63] គួរបញ្ជាក់ផងដែរថា ចំពោះអានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយមជ្ឈត្តករបន្ទាន់នេះ គឺត្រូវមានអានុភាពអនុវត្តចំពោះគូភាគីវិវាទដែលយល់ព្រមប្រើប្រាស់នូវនីតិវិធីនេះ ដោយត្រូវគោរពតាមមជ្ឈត្តវិនិច្ឆ័យដោយមិនពន្យាពេល ព្រមទាំងមិនមានសិទ្ធិក្នុងការតវ៉ា ឬជំទាស់ទម្រង់ណាមួយនៃមជ្ឈត្តវិនិច្ឆ័យទៅកាន់តុលាការដែលមានសមត្ថកិច្ចនោះឡើយ។[64]

បន្ថែមពីលើនេះទៅទៀត តាមរយៈ *វិធាន ម.ជ.ម. ថ្មី* ក៏បានធ្វើកំណែសម្រួលទៅលើពាក្យពេចន៍ និងទម្រង់ខ្លះៗនៃគម្រូខចែងរបស់ *ម.ជ.ម*ដែលគូភាគីត្រូវចែងក្នុងកិច្ចសន្យាពាណិជ្ជកម្មរបស់ខ្លួនផងដែរ។[65] ចំពោះទម្រង់ខចែងរបស់*ម.ជ.ម.*ចាស់ និងទម្រង់ខចែងរបស់*ម.ជ.ម.*ថ្មី សូមធ្វើការពិនិត្យមើលបាននៅ ឧបសម្ព័ន្ធ ២ នៃអត្ថបទសារណានេះ។

[62] *វិធានម.ជ.ម.ថ្មី*, ប្រការ ៩.១(ក) និងប្រការ ៩.២(ឃ)។

[63] *វិធានម.ជ.ម.ថ្មី*, ប្រការ ១០, ប្រការ ១២, ប្រការ ១៤, ប្រការ ១៦, និងប្រការ ១៨។

[64] *វិធានម.ជ.ម.ថ្មី*, ប្រការ ២១។

[65] *វិធានម.ជ.ម.ថ្មី*, ឧបសម្ព័ន្ធ ២។

# ជំពូកទី២

## ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

# ជំពូកទី២
# ការប្តឹងទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

## ២.១. មូលដ្ឋាននៃការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

ជាគោលការណ៍ ក្នុងការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដែលបានសម្រេចដោយវេទិកាមជ្ឈត្តការ រួចនោះ គឺត្រូវធ្វើការពិនិត្យមើលទៅលើចំណុចសំខាន់មួយចំនួន ដើម្បីបំពេញនូវតម្រូវការ និងលក្ខខណ្ឌនៃមជ្ឈត្តករផ្នែកពាណិជ្ជកម្ម។[66] គួរបញ្ជាក់ផងដែរថា ក្នុងផ្នែកនេះទាំងមូលនេះនឹងធ្វើការពិភាក្សាយ៉ាងលម្អិតទៅលើមូលដ្ឋាននីមួយៗ ដើម្បីយល់ជ្រាបច្បាស់លាស់នូវនីតិវិធី និងបែបបទនានា ដែលពាក់ព័ន្ធទៅនឹងការប្តឹងជំទាស់នេះ។ ការពិភាក្សាដេញដោលជាលក្ខណៈពិស្តាលើមូលដ្ឋាននីមួយៗ គឺដើម្បីផ្តល់ជាពុទ្ធិក្បោះក្បាយ ដោយមានរួមបញ្ចូលទាំងដំណាលដើមទងនៃមូលដ្ឋានទាំងឡាយ ពោលគឺក្នុងករណីដែលពាក់ព័ន្ធទៅនឹងភាគី ថាតើដើមចមនៃបញ្ហានោះស្ថិតនៅត្រង់ណា ដូចគ្នាដែរចំពោះមូលដ្ឋានផ្សេងទៀត ដូចជាកិច្ចព្រមព្រៀងមជ្ឈត្តការ និងការតែងតាំងមជ្ឈត្តករជាដើមនោះ គឺមានការចាំបាច់ត្រូវដឹង និងយល់អំពីតម្រូវការតាមផ្លូវច្បាប់ ដើម្បីឱ្យកិច្ចព្រមព្រៀងនោះមានសុពលភាព ហើយមានការអនុវត្តនូវនីតិវិធីតែងតាំងមជ្ឈត្តករឱ្យបានត្រឹមត្រូវ ទើបអាចធ្វើឱ្យសេចក្តីសម្រេចមជ្ឈត្តការ ឬមជ្ឈត្តវិនិច្ឆ័យនោះ ពុំត្រូវបានប្តឹងជំទាស់ ឬអាចផ្តល់លទ្ធភាពតាមផ្លូវច្បាប់ដល់ភាគីអនុវត្តដើម្បីប្តឹងជំទាស់ជាដើម។ ដូច្នេះ ការពិភាក្សានេះនឹងពិនិត្យមើលទៅលើមូលដ្ឋានជំទាស់ដូចជា ភាគីនៃវេទិកាមជ្ឈត្តការ (២.១.១.) កិច្ចព្រមព្រៀងមជ្ឈត្តកម្ម (២.២.២.) និងការតែងតាំងមជ្ឈត្តករ (២.៣.៣.)។

### ២.១.១. ភាគីនៃវេទិកាមជ្ឈត្តការ

ក្នុងការសិក្សាទៅលើភាគីនៃវេទិកាមជ្ឈត្តការ គឺត្រូវពិនិត្យមើលទៅលើ សមាសភាព ព្រមទាំងស្ថានភាពនៃបុគ្គលដែលជាភាគីនៃវិវាទ ថាតើស្ថានភាពនៃបុគ្គលនោះ អាចបំពេញលក្ខខណ្ឌក្នុងការធ្វើជាភាគីក្នុងមជ្ឈត្តការបានដែរឬទេ។

#### ២.១.១.១. រដ្ឋ

ការប្រព្រឹត្តទៅនៃនីតិវិធីមជ្ឈត្តការ តែងតែចាំបាច់ត្រូវការរដ្ឋដែលពាក់ព័ន្ធ ដើម្បីធានាបាននូវការអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យដោយត្រឹមត្រូវ និងសមប្រកប តាមរយៈស្ថាប័នតុលាការនៃរដ្ឋដែលត្រូវអនុវត្តនោះ។ ពាក្យថា រដ្ឋពាក់ព័ន្ធ គឺសម្តៅដល់ប្រទេស ដែលមានវិសាលភាពគ្រប់គ្រងទៅលើទ្រព្យនៃគូភាគីវិវាទ ក្នុងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ពោលគឺទ្រព្យរបស់ភាគីនៃវិវាទដែលត្រូវអនុវត្តស្របតាមមជ្ឈត្តវិនិច្ឆ័យនោះ គឺស្ថិតនៅរដ្ឋមួយដែលត្រូវអនុវត្តសេចក្តីសម្រេចមជ្ឈត្តការនោះ។ គួរបញ្ជាក់ផងដែរថា ក្នុងការអនុវត្តជាក់ស្តែង ទីតាំងនៃទ្រព្យរបស់

---

[66] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៤៤។

គូភាគី អាចមិនស្ថិតនៅក្នុងរដ្ឋដែលជាសញ្ជាតិរបស់ខ្លួន ដោយសារតែក្នុងករណីមួយចំនួន ភាគីនៃវិវាទមានទ្រព្យទុកនៅឯបរទេស។ យ៉ាងណាមិញ ដោយហេតុថា សេចក្ដីសម្រេចមជ្ឈត្តការ គឺជាសេចក្ដីសម្រេចដែលមានអានុភាពចាប់បង្ខំ ហើយដែលទាមទារឱ្យរដ្ឋដែលមានតុលាការជាស្ថាប័នអនុវត្តនោះ ត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើមិនបានបំពេញកាតព្វកិច្ចត្រឹមត្រូវ តាមរយៈការអនុវត្តសេចក្ដីសម្រេចនោះ។ មិនតែប៉ុណ្ណោះ ក្នុងករណីសេចក្ដីសម្រេចនោះជា មជ្ឈត្តវិនិច្ឆ័យបរទេស គឺវាអាចនាំឱ្យរដ្ឋដែលមិនបានបំពេញកាតព្វកិច្ចអនុវត្តត្រឹមត្រូវនោះ ត្រូវទទួលខុសត្រូវចំពោះមុខស្ថាប័នអន្តរជាតិទៀតផង។ រដ្ឋ ស្ថិតនៅក្រោមកាតព្វកិច្ចជាលក្ខណៈអន្តរជាតិក្នុងការអនុលោមតាម ឬអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ ហើយដែលអាចបង្កើតជាបន្ទុកដល់រដ្ឋក្នុងការទទួលខុសត្រូវ ប្រសិនបើតុលាការនៃរដ្ឋនោះជំទាស់ដោយគ្មានយុត្តិកម្មត្រឹមត្រូវ ឬអាក់ខានក្នុងការអនុវត្ត។[67] នៅក្នុងអត្ថបទរបស់ លោកចៅក្រម Sepúlveda-Amor[68] លោកបានធ្វើចំណាប់អារម្មណ៍ទៅលើតួនាទីដ៏សំខាន់របស់រដ្ឋក្នុងដំណើរការនៃនីតិវិធីមជ្ឈត្តការ ដោយលោកបានបង្ហាញនូវចំណុចជាច្រើនមកបកស្រាយរួមមាន ការពឹងផ្អែករបស់តុលាការវិនិយោគអន្តរជាតិទៅលើទំនៀមទម្លាប់អន្តរជាតិស្ដីពីការទទួលខុសត្រូវរបស់រដ្ឋ ការទទួលខុសត្រូវរបស់រដ្ឋក្រោមសន្ធិសញ្ញាពាក់ព័ន្ធនឹងវិស័យវិនិយោគ ក្នុងការមិនអនុវត្តមជ្ឈត្តការ កាតព្វកិច្ចក្នុងការអនុលោមនិងអនុវត្តមជ្ឈត្តវិនិច្ឆ័យ និងតួនាទីរបស់តុលាការយុត្តិធម៌អន្តរជាតិក្នុងការអនុវត្តមជ្ឈត្តវិនិច្ឆ័យរវាងរដ្ឋនិងរដ្ឋ។ នៅក្នុងចំណុចទាំងនេះ គេអាចដកស្រង់បាននូវចំណុចពិសេសដែលបញ្ជាក់អំពីតួនាទីសំខាន់របស់រដ្ឋក្នុងការធានាឱ្យបាននូវការអនុវត្តមជ្ឈត្តវិនិច្ឆ័យតាមការទាមទារដោយគូវិវាទ និងសម្រេចដោយវេទិកាមជ្ឈត្តការ។

គួរបញ្ជាក់ផងដែរថា ចំពោះរឿងរ៉ាវដែលពាក់ព័ន្ធទៅនឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យនេះ គឺមិនមែនជាបញ្ហាមួយដែលមិនមានការយកទុកដាក់នោះទេ ដោយសារតែ ការជំនុំជម្រះវិវាទតាមយន្តការផ្សេងៗក្រៅប្រព័ន្ធតុលាការ គឺជាសិទ្ធិផ្ដាច់មុខរបស់គូភាគី ឬជាពិសេសនោះក្នុងបរិបទនៃសារណានេះ គឺពាណិជ្ជករ អ្នកធុរកិច្ច ឬអ្នកវិនិយោគទាំងឡាយផងដែរ។ មិនតែប៉ុណ្ណោះ សេចក្ដីសម្រេចមជ្ឈត្តការ ឬមជ្ឈត្តវិនិច្ឆ័យនីមួយៗ គឺជាសេចក្ដីសម្រេចចុងក្រោយ និងបិទផ្លូវតវ៉ា លើកលែងការតវ៉ាទៅលើបញ្ហានីតិវិធីដែលកើតមានក្នុងកំឡុងពេលនៃមជ្ឈត្តការនោះ។ ជាឧទាហរណ៍មួយក្នុងបរិបទទូទៅជុំវិញបញ្ហាមជ្ឈត្តការអន្តរជាតិ គឺជម្លោះរវាងប្រទេស

[67] *សូមមើល* អត្ថបទ លោកចៅក្រម Sepúlveda-Amor និងលោកស្រី Lawry-White ស្ដីអំពី ទំនួលខុសត្រូវរបស់រដ្ឋ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ (*State repsonsibility and the enforcement of arbitral award*), Oxford University Press (២០១៦), ទំព័រទី២។ (តទៅនេះហៅថា «អត្ថបទលោកចៅក្រម Sepúlveda-Amor»)

[68] លោក Bernado Sepúlveda-Amor គឺជាអតីតចៅក្រមនៃតុលាការយុត្តិធម៌អន្តរជាតិពីឆ្នាំ ២០០៦ រហូតដល់ ឆ្នាំ ២០១៥ និងជាអតីតអនុប្រធាននៃតុលាការយុត្តិធម៌អន្តរជាតិក្នុងចន្លោះឆ្នាំ ២០១២ និងឆ្នាំ ២០១៥។ សព្វថ្ងៃលោក គឺជា មជ្ឈត្តករឯករាជ្យមួយរូបដែរ។

ហុងឌូរ៉ាស (*Honduras*) និងប្រទេសនីហ្គារ៉ាហ្គ័រ (*Nicaragua*) នាឆ្នាំ១៩០៨[69]។ វិវាទនៃរឿងក្តីនេះ គឺស្តីអំពីសុពលភាពនៃមជ្ឈត្តវិនិច្ឆ័យក្នុងការសម្រេចទៅលើព្រំដែនដីរវាងរដ្ឋទាំងពីរ ពោលគឺ យោងតាមសន្ធិសញ្ញាហ្គាម៉េស៍ប៊ូនីឡា (*Gámez-Bonilla Treaty*) រវាងរដ្ឋទាំងពីរបានព្រមព្រៀងនោះ បានចែងថាក្នុងករណីដែលកើតមាននូវជម្លោះដែនដីដែលមិនអាចដោះស្រាយបាន ត្រូវតែដាក់ជូនវេទិកាមជ្ឈត្តការដើម្បីកាត់សេចក្តី។ ចំណុចផ្តើមនៃវិវាទនោះ គឺដោយសារតែសេចក្តីសម្រេចមជ្ឈត្តការ គឺមានទំនោរទៅខាងរដ្ឋហុងឌូរ៉ាស ដែលធ្វើឱ្យខាងភាគី នីហ្គារ៉ាហ្គ័រ បន្តប្តឹងមកតុលាការយុត្តិធម៌អន្តរជាតិ ឱ្យពិនិត្យមើលសុពលភាពនៃសេចក្តីសម្រេចនោះ និងការតែងតាំងមជ្ឈត្តករមិនត្រឹមត្រូវដោយ ស្តេចអាល់ហ្វនសូនៃអេស្ប៉ាញ។ យ៉ាងណាមិញ តុលាការយុត្តិធម៌អន្តរជាតិ បានសម្រេចថា ប្រព័ន្ធដំណោះស្រាយវិវាទ តាមផ្លូវមជ្ឈត្តការ គឺជាការដោះស្រាយវិវាទដែលមាន លក្ខណៈចាប់បង្ខំ និងគ្មានផ្លូវតវ៉ា ហើយវាក៏ជាមូលហេតុដែលតុលាការជំទាស់នឹងភាគីនីហ្គារ៉ាហ្គ័រ ក្នុងការពិនិត្យពិច័យទៅលើការសម្រេចរបស់វេទិកាមជ្ឈត្តការ ឬធ្វើកោសល្យវិច័យទៅលើក្របខណ្ឌ ឬនីតិវិធីនៃការតែងតាំងមជ្ឈត្តករដោយស្តេចអេស្ប៉ាញ។[70] បន្ថែមពីលើនេះ តុលាការបានវិនិច្ឆ័យថា ភាគីនីហ្គារ៉ាហ្គ័រ មានកាតព្វកិច្ចក្នុងការផ្តល់នីត្យានុកូលភាព ក្នុងការអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនោះ ដោយបំពេញរាល់សេចក្តីទាមទារ ដែលមានចែងក្នុងមជ្ឈត្តវិនិច្ឆ័យនោះផងដែរ។[71]

ក្នុងការបង្ហាញនូវករណីសិក្សាខាងលើនេះ គឺមានគោលបំណងក្នុងការពង្រីកពង្រឹងនូវពុទ្ធិជាលក្ខណៈអន្តរជាតិទៅលើការអនុវត្តនៃមជ្ឈត្តវិនិច្ឆ័យដោយរដ្ឋ។ រដ្ឋទាំងឡាយ មានតួនាទីក្នុងការអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយអនុលោមតាមទៅសេចក្តីសម្រេចដែលបានចែងនោះ ហើយរដ្ឋពុំអាចលើកចោល ឬជំទាស់នូវការអនុវត្តនោះបានឡើយ ដោយនេះគឺជាកាតព្វកិច្ច និងទំនួលខុសត្រូវរបស់រដ្ឋ ដែលមានស្ថាប័នតុលាការជាអ្នកអនុវត្ត។ ករណីសិក្សាខាងលើបានបង្ហាញឱ្យឃើញថា នីតិវិធីមជ្ឈត្តការអាចត្រូវបានចាប់ផ្តើមឡើង ដោយសារការព្រមព្រៀងរវាងភាគីវិវាទក្នុងការដោះស្រាយវិវាទតាមយន្តការនេះ ហើយភាគីនៃវិវាទនេះផងដែរ ចាំបាច់ត្រូវតែទទួលស្គាល់នូវមជ្ឈត្តវិនិច្ឆ័យ និងអនុវត្តទៅតាមការសម្រេចនោះ ដោយហេតុថាមជ្ឈត្តវិនិច្ឆ័យជាសេចក្តីសម្រេចចុងក្រោយ និងមិនអាចធ្វើបណ្តឹងឧបាស្រ័យបាន។ ដូចក្នុងករណីខាងលើផងដែរ ទោះបីជា នីហ្គារ៉ាហ្គ័របានដាក់

[69] *រឿងក្តីស្តីពីមជ្ឈត្តវិនិច្ឆ័យដែលចេញដោយស្តេចនៃប្រទេសអេស្ប៉ាញ នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩០៦ (រវាង ហុងឌូរ៉ាស និងនីហ្គារ៉ាហ្គ័រ),* តុលាការយុត្តិធម៌អន្តរជាតិ, សេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩០៦, ទំព័រទី ២១៣។

[70] *រឿងក្តីស្តីពីមជ្ឈត្តវិនិច្ឆ័យដែលចេញដោយស្តេចនៃប្រទេសអេស្ប៉ាញ នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩០៦ (រវាង ហុងឌូរ៉ាស និងនីហ្គារ៉ាហ្គ័រ),* ទំព័រទី ២១៤។

[71] *រឿងក្តីស្តីពីមជ្ឈត្តវិនិច្ឆ័យដែលចេញដោយស្តេចនៃប្រទេសអេស្ប៉ាញ នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩០៦ (រវាង ហុងឌូរ៉ាស និងនីហ្គារ៉ាហ្គ័រ),* ទំព័រទី ២១៤។

បណ្ដឹងទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ ក្នុងការពិនិត្យមើលទៅលើសុពលភាពនៃមជ្ឈត្តវិនិច្ឆ័យ និងមូលដ្ឋាននៃការសម្រេចដោយមជ្ឈត្តករក្ដី ក៏តុលាការយុត្តិធម៌អន្តរជាតិពុំមានសមត្ថកិច្ចក្នុងការសើរើពិនិត្យមើលឡើងវិញនូវសេចក្ដីសម្រេចនោះដែរ ដែលជាលទ្ធផលតុលាការនៅតែបន្តទទួលស្គាល់នូវមជ្ឈត្តវិនិច្ឆ័យនោះដដែល។

ដូច្នេះ បើគ្រាលេកមកមើល ក្នុងបរិបទនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជាវិញ ក៏ពុំមានភាពខុសប្លែកគ្នាដែរ ដោយហេតុថាបើយោងទៅតាមច្បាប់ជាធរមាន ព្រមទាំងអនុសញ្ញាទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យមជ្ឈត្តការ គឺសុទ្ធតែទទួលស្គាល់នូវមជ្ឈត្តវិនិច្ឆ័យទាំងឡាយជាសេចក្ដីសម្រេចចុងក្រោយបំផុត ហើយភាគីនៃវិវាទ មានកាព្វកិច្ចក្នុងការបំពេញតាមការទាមទាររបស់ភាគីម្ខាងទៀតផងដែរ។ មួយវិញទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសាលាឧទ្ធរណ៍ ជាអង្គអនុវត្តមជ្ឈត្តវិនិច្ឆ័យ គឺត្រូវអនុវត្តសេចក្ដីសម្រេចមជ្ឈត្តការនោះ ទោះមានលក្ខណៈជាអន្តរជាតិក៏ដោយ ក៏សុពលភាពនៃមជ្ឈត្តវិនិច្ឆ័យនៅតែមានដដែល ហើយត្រូវអនុវត្តជាដាច់ខាត លើកលែងមានការចែងមិនឱ្យអនុវត្តដោយប្រការណាមួយដោយច្បាប់ជាធរមាន។

### ២.១.១.២. បុគ្គល

មុនឈានដល់ការបង្ហាញអំពីបុគ្គលដែលជាភាគីនៃវិវាទ ជាដំបូងគួរពិនិត្យមើលទៅលើបទដ្ឋានដែលកំណត់ថាតើអ្វីជាបុគ្គល ហើយថាតើច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់បុគ្គលជាប៉ុន្មានប្រភេទ។ បើយោងទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បុគ្គលដែលច្បាប់ទទួលស្គាល់គឺមានពីរប្រភេទ រួមមានរូបវន្តបុគ្គល និងនីតិបុគ្គល។[72] រូបវន្តបុគ្គល សម្ដៅដល់បុគ្គលគ្រប់រូបដែលមានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន[73] រីឯនីតិបុគ្គលវិញ គឺសម្ដៅទៅលើក្រុមបុគ្គលដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ តួយ៉ាងជា នីតិបុគ្គលសាជីវកម្ម ឬនីតិបុគ្គលមូលនិធិ[74]។ ក្នុងន័យទូលាយ រូបវន្តបុគ្គល គឺសម្ដៅដល់បុគ្គលគ្រប់រូបដែលរស់រានមានជីវិត ហើយប្រកបកិច្ចការងារប្រចាំថ្ងៃ រីឯនីតិបុគ្គល គឺសម្ដៅដល់ក្រុមហ៊ុន សហគ្រាស ឬអាជីវកម្មនានាដែលប្រកបកិច្ចការទៅតាមវិស័យនៃនីតិបុគ្គលនោះ។ យ៉ាងណាមិញ ក្នុងការពិភាក្សានឹងសង្កត់ធ្ងន់តែទៅលើ បុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹង វិស័យពាណិជ្ជកម្មតែប៉ុណ្ណោះ។ ស្របតាមការបង្ហាញជូនខាងលើនេះ គេអាចសំយោគបានថា បុគ្គលទាំងឡាយដោយមិនគិតថាជារូបវន្តបុគ្គល ឬនីតិបុគ្គលឡើយ ប៉ុន្តែប្រសិនបើបុគ្គលនោះប្រកបនូវសកម្មភាពពាណិជ្ជកម្ម ឬពាណិជ្ជកិច្ច នោះ វិវាទដែលកើតចេញពីបញ្ហាពាណិជ្ជកម្មទាំងឡាយ អាចត្រូវបានដោះស្រាយទៅតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្មបាន។ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ដោយ

---

[72] *ក្រមរដ្ឋប្បវេណី*, មាត្រា ៦ និងមាត្រា ៤៦។

[73] *ក្រមរដ្ឋប្បវេណី*, មាត្រា ៦។

[74] *ក្រមរដ្ឋប្បវេណី*, មាត្រា ៤៦។

ជ្រើសរើសនូវប្រព័ន្ធមជ្ឈត្តការមកដោះស្រាយវិវាទរបស់ខ្លួននោះ ចាំបាច់ត្រូវតែអនុលោមទៅតាមលក្ខខណ្ឌតម្រូវតាមវិធាន និងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីមានសមត្ថភាពក្នុងការដាក់វិវាទរបស់ខ្លួនឱ្យមជ្ឈត្តការដោះស្រាយជូន។ ចំពោះចំណុចនេះ ភាគីនៃវិវាទគួរកំណត់ចំណាំផងដែរថា ការជ្រើសរើសនូវប្រព័ន្ធមជ្ឈត្តការដើម្បីដោះស្រាយវិវាទ គឺត្រូវតែកើតចេញពីការព្រមព្រៀង ទាំងសងខាងជាលាយលក្ខណ៍អក្សរ តាមរយៈកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ឬបញ្ញត្តិនូវខចែងស្តីពី ការដោះស្រាយវិវាទរបស់ខ្លួនតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

### ២.១.២. កិច្ចព្រមព្រៀងមជ្ឈត្តកម្ម

ជាការពិតណាស់ ចំណុចចាប់ផ្តើមដំបូងបំផុតមុនឈានដល់ការបើកវេទិកាមជ្ឈត្តការ គឺវត្តមាននៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ដែលវាអាចស្តែងចេញឡើងភាគច្រើនក្រោមទម្រង់ជា ខចែង ក្នុងកិច្ចសន្យាពាណិជ្ជកម្ម។ កិច្ចព្រមព្រៀងមជ្ឈត្តកម្ម គឺជាការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាពាណិជ្ជកម្មថានឹងព្រមព្រៀងដោះស្រាយវិវាទកើតដែលចេញពីកិច្ចសន្យានោះ តាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅទីតាំងនៃមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មណាមួយ។ ដូចដែលបានបង្ហាញជូននូវ គម្រូខចែងអំពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្នុង *ឧបសម្ព័ន្ធ ២* នៃសារណានេះ គឺភាគីនៃវិវាទត្រូវតែមានបញ្ញត្តិចូលនូវខចែងនេះក្នុងកិច្ចសន្យារបស់ខ្លួន ទើបភាគីអាចដាក់វិវាទនោះឱ្យដោះស្រាយបាន។ បើធ្វើការពិនិត្យមើល ប្រការ ៧ កថាខណ្ឌទី១ នៃ *វិធាន ម.ជ.ម.ថ្មី* បានចែងថា៖ «ភាគីវិវាទដែលមានបំណងដាក់វិវាទរបស់ខ្លួនឱ្យដោះស្រាយតាមរយៈមជ្ឈត្តកម្ម ទាមទារចំពោះគូភាគីវិវាទម្ខាងទៀត ត្រូវបញ្ជូនទៅអគ្គលេខាធិការដ្ឋាន នូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ដែលត្រូវមានភ្ជាប់នូវ (ក) សេចក្តីថ្លែងដែលបញ្ជាក់ថា វិវាទត្រូវបានដាក់ឱ្យដោះស្រាយតាមមជ្ឈត្តកម្ម ឬ (ឃ) សេចក្តីយោងនៃខចែងស្តីពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកដែលយកមកប្រើ និងភ្ជាប់សំណៅចម្លងនៃខចែងស្តីពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកនោះ»[75]។ ប្រការនេះសបញ្ជាក់ឱ្យឃើញថា ដើម្បីឱ្យវិវាទដែលកើតឡើង អាចត្រូវបានដោះស្រាយដោយមជ្ឈត្តការគឺ គូភាគីត្រូវតែមានចែងនូវខចែងមជ្ឈត្តការក្នុងកិច្ចសន្យារបស់ខ្លួន ឬមាននូវការព្រមព្រៀងថានឹងដោះស្រាយវិវាទ តាមប្រព័ន្ធមជ្ឈត្តការ ក្នុងកិច្ចព្រមព្រៀងដោយឡែក។ យ៉ាងណាមិញ ជាបញ្ហាបន្ទាប់នោះគឺស្តែងចេញអំពី សុពលភាពនៃការព្រមព្រៀងនោះ (ចំណុច ២.១.២.១.) ពោលគឺ តើខចែងមជ្ឈត្តការនោះ ឬកិច្ចព្រមព្រៀងមជ្ឈត្តការនោះមានសុពលភាពក្នុងការអនុវត្តបាន ដោយរបៀបណា ឬតើមានលក្ខខណ្ឌតម្រូវតាមច្បាប់អ្វីខ្លះ ដើម្បីឱ្យការព្រមព្រៀងនោះមានសុពលភាព។

[75] *វិធាន ម.ជ.ម. ថ្មី*, ប្រការ ៧(១)(ក) និង ប្រការ ៧(១)(ឃ)។

### ២.១.២.១. សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម

សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម គឺសម្តៅដល់អានុភាពគតិយុត្តនៃកិច្ចព្រមព្រៀងចែងអំពីការដោះស្រាយវិវាទរវាងគូភាគីនៃកិច្ចសន្យាពាណិជ្ជកម្ម តាមរយៈប្រព័ន្ធមជ្ឈត្តការ ដែលក្នុងនោះ ទាមទារឱ្យមានភាពសមស្របទៅតាម លក្ខខណ្ឌតម្រូវ តាមបទបញ្ញត្តិនៃច្បាប់ជាធរមានពាក់ព័ន្ធនឹង មជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ លក្ខខណ្ឌដំបូងបំផុតនោះ គឺទាមទារឱ្យ កិច្ចព្រមព្រៀង ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ[76] ពីព្រោះការណ៍ដែលមិនបានចែងច្បាស់នូវការព្រមព្រៀងនេះ អាចបង្កបង្កើតជាបញ្ហាក្នុងការរារាំង ឱ្យរាំងស្ទះដល់ដំណើរការនៃមជ្ឈត្តកម្ម និងជាពិសេសនោះគឺមិនមាននូវទឡ្ហីករណ៍ក្នុងការបញ្ជាក់អំពីភាពច្បាស់លាស់ និងឆន្ទៈពិតប្រាកដរបស់គូភាគីក្នុងការដោះស្រាយវិវាទតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[77] ក្នុងបរិបទនៃ *ម.ជ.ម.* ជាដំណោះស្រាយដល់បញ្ហាដែលបានជម្រាបជូនខាងលើនេះ *ម.ជ.ម.* បានតាក់តែងឡើងនូវខចែងគម្រូ ឬគម្រូនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ដែលភាគីវិវាទត្រូវអនុវត្តតាម។ បន្ថែមពីលើនេះ *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* ក៏បានបញ្ជាក់ផងដែរថា កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរក្នុងបរិបទនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺសម្តៅដល់ការព្រមព្រៀងក្នុងឯកសារ តាមរយៈការចុះហត្ថលេខាដោយភាគីវិវាទ ឬមធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលអាចផ្តល់នូវកំណត់ត្រា អំពីការព្រមព្រៀងគ្នាបាន។[78] ជានិន្នាការថ្មីក្នុងបរិបទបដិវត្តន៍ឧស្សាហកម្ម ៤.០ នៃសង្គមឌីជីថល បាននាំមកនូវទំនើបកម្មនៃទំនាក់ទំនងរវាងបុគ្គលតាមប្រព័ន្ធអេឡិចត្រូនិច ហេតុដូចនេះហើយ ទើបបទដ្ឋានគតិយុត្ត បានពង្រីកនូវវិសាលភាពក្នុងការព្រមព្រៀងជាលាយលក្ខណ៍អក្សរនោះ រហូតដល់ ចាត់ទុកនូវការឆ្លើយឆ្លងគ្នាក្នុងប្រព័ន្ធទូរគមនាគន៍អេឡិចត្រូនិច ដែលមានកំណត់ត្រាច្បាស់លាស់ ជាកិច្ចព្រមព្រៀងលាយលក្ខណ៍អក្សរផងដែរ។

ដូចនេះ សរុបមកដើម្បីឱ្យកិច្ចព្រមព្រៀងមជ្ឈត្តការមានសុពលភាព គឺចាំបាច់ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានចែងបញ្ចូលទៅក្នុងកិច្ចសន្យាពាណិជ្ជកម្មរបស់គូភាគី ឬកិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែក ដែលបង្ហាញនូវឆន្ទៈរបស់រាល់គូភាគីនៃកិច្ចសន្យា ថាបាន ឬនឹងសម្រេចចិត្តក្នុងការបញ្ជូនវិវាទដែលកើតមាន ឬនឹងកើតមាននោះជូនមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីដោះស្រាយ។

### ២.១.២.២. មូលដ្ឋានសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តការ

យ៉ាងណាមិញ បញ្ហាដែលពាក់ព័ន្ធទៅនឹងការចាប់ផ្តើមរបស់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺពាក់ព័ន្ធទៅនឹងសមត្ថកិច្ចសម្ភារៈ ពោលគឺ តើវេទិកាមជ្ឈត្តការមានសមត្ថកិច្ចក្នុងការសម្រេចដោះស្រាយបញ្ហាដែលបានដាក់

[76] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៧។

[77] *សូមមើល សៀវភៅ មេធាវី ខៀវ មាលី*, ទំព័រ ១៤៦។

[78] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៧ កថាខណ្ឌទី ២។

ជូនដែរឬទេ ហើយថាតើវេទិកាមជ្ឈត្តការនោះ ត្រូវបានបង្កើតឡើងស្របតាមគោលការណ៍ដែលបានកំណត់ដោយ *វិធាននៃម.ជ.ម.ថ្មី* ដែរឬទេ។ គួបញ្ជាក់ផងដែរ បញ្ហាសមត្ថកិច្ច គឺជាមូលដ្ឋានមួយដ៏សំខាន់ ដល់នីត្យានុកូលភាពនៃការដោះស្រាយវិវាទ ដោយសារតែ *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* បានចែងយ៉ាងជាក់ច្បាស់ថា ច្បាប់នេះ គឺអនុវត្តតែទៅលើ វិវាទផ្នែកពាណិជ្ជកម្មតែប៉ុណ្ណោះ។[79] មួយវិញទៀត ដោយសារតែ *ម.ជ.ម.* ត្រូវបានបង្កើតឡើងដោយច្បាប់នេះ ដូចនេះវាបានសបញ្ជាក់ឱ្យឃើញថា *ម.ជ.ម.* មានសមត្ថកិច្ចដោះស្រាយវិវាទទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងវិវាទពាណិជ្ជកម្មតែប៉ុណ្ណោះ ចំណែកឯ វិវាទផ្សេងៗទៀតដែលមិនមានការពាក់ព័ន្ធទៅនឹងវិស័យពាណិជ្ជកម្មទេនោះ តួយ៉ាង វិវាទគ្រួសារ វិវាទរដ្ឋបាល ឬវិវាទពាក់ព័ន្ធទៅនឹងវិស័យព្រហ្មទណ្ឌ ឬគោលនយោបាយសាធារណៈ គឺមិនត្រូវបានដោះស្រាយដោយវេទិកាមជ្ឈត្តការនៃ *ម.ជ.ម.* នោះទេ។[80] មូលហេតុចម្បងនៃការបញ្ញត្តិបែបនេះ គឺដើម្បីធានាឱ្យបាននូវការសម្រេចក្តីដោយមជ្ឈត្តការបានយ៉ាងឆាប់រហ័ស ក្រោមរូបភាពមួយដែលវេទិកាមជ្ឈត្តការអាចសម្រេចថា តើខ្លួនមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទដែលបានដាក់ជូននោះដែរឬទេ និងជាពិសេសជាងនេះទៅទៀត គឺដើម្បីបញ្ចៀសឱ្យបាននូវចេតនាទុច្ចរិតរបស់គូភាគីក្នុងការពន្យាពេលដោះស្រាយវិវាទ។ ក្នុងន័យនេះ ប្រសិនបើវេទិកាមជ្ឈត្តការ មិនមាននូវបុរេសិទ្ធិក្នុងការជំទាស់នូវសមត្ថកិច្ចរបស់ខ្លួននោះទេ វាអាចនាំឱ្យមានការអូសបន្លាយនីតិវិធីកាន់តែវែងឆ្ងាយ និងទាញពេលវេលាកាន់តែយូរ ដែលអាចនាំឱ្យមានការខាតបង់ផលប្រយោជន៍របស់គូភាគី។ មិនតែប៉ុណ្ណោះ ការដាក់ឱ្យពិនិត្យនិងសម្រេចលើសមត្ថកិច្ចរបស់មជ្ឈត្តការមុនធ្វើការដោះស្រាយវិវាទនេះ ក៏វាបានផ្តល់នូវកាលានុវត្តន៍ភាព និងភាពស្មើគ្នាដល់គូភាគី ក្នុងការប្តឹងជំទាស់លើបញ្ហាសមត្ថកិច្ច ប្រសិនបើរកឃើញនូវការរំលោភបំពាននូវដែនសមត្ថកិច្ចតាមរយៈការធ្វើសកម្មភាព លើសពីវិសាលភាពនៃសិទ្ធិអំណាចរបស់វេទិកាមជ្ឈត្តការ ដែលគូភាគីបានកំណត់ក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្ម។ ម្យ៉ាងទៀត ជាគោលគំនិតរបស់គូភាគីក្នុងការសម្រេចយកប្រព័ន្ធមជ្ឈត្តការ គឺដើម្បីប្រើប្រាស់នូវយន្តការក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់មជ្ឈត្តការក្នុងការដោះស្រាយវិវាទឱ្យបានឆាប់រហ័ស និងមានអានុភាពចាប់បង្ខំដល់គូភាគីក្នុងការអនុវត្តផងដែរ។

ជាការលម្អិតបន្ថែម ចំពោះកថាខណ្ឌខាងលើ នីតិវិធីនៃការជំទាស់សមត្ថកិច្ចរបស់វេទិកាមជ្ឈត្តការ ត្រូវបានច្បាប់កំណត់ឱ្យតុលាការជាអ្នកសម្រេចនូវសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តការ តាមរយៈបណ្តឹងឧបាស្រ័យក្នុងនីតិវិធីមជ្ឈត្តកម្ម។[81] ការជំទាស់សមត្ថកិច្ចក៏អាចត្រូវបានធ្វើឡើងដោយភាគីនៃវិវាទផងដែរ។ ភាគីនៃវិវាទ ត្រូវតែលើកឡើង និងបង្ហាញភ្លាមៗ នៅពេលដែលជួបប្រទះនឹងបញ្ហាហួសក្របខណ្ឌនៃសមត្ថកិច្ចរបស់វេទិកា

[79] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១។

[80] *សូមមើល សៀវភៅ មេធាវី ខៀវ មាលី*, ទំព័រ ១៤៨។

[81] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៦។

មជ្ឈត្តកម្ម នាពេលធ្វើមជ្ឈត្តការ។[82] ការបង្ហាញនេះ ត្រូវមានទឡ្ហីករណ៍ ដែលបញ្ជាក់អំពីការប្រើប្រាស់សិទ្ធិអំណាចហួសវិសាលភាពដែលបានកំណត់ ហើយការបង្ហាញនេះផងដែរ ត្រូវតែធ្វើឡើងភ្លាមៗ បន្ទាប់ពីបានដឹងលឺ ឬជួបប្រទះនឹងបញ្ហានេះ ទោះបីជាមានការយឺតយ៉ាវក៏ដោយ ក៏ប៉ុន្តែ ភាពយឺតយ៉ាវរបស់ភាគីត្រូវតែមានភាពត្រឹមត្រូវ និងភ្ជាប់មកនូវទឡ្ហីករណ៍ដែលសមប្រកបផងដែរ។[83] ជាទូទៅ ភាគីមានរយៈពេល សាមសិប ថ្ងៃ ក្រោយពីបានទទួលសេចក្ដីជូនដំណឹងពីការសម្រេចសមត្ថកិច្ចរបស់មជ្ឈត្តការដោយតុលាការមានសមត្ថកិច្ច ដូយ៉ាង សាលាឧទ្ធរណ៍ តុលាការកំពូល ឬតុលាការពាណិជ្ជកម្ម។[84] គួរបញ្ជាក់ផងដែរថា សេចក្ដីសម្រេចលើសមត្ថកិច្ចរបស់មជ្ឈត្តការ គឺជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ដែលគូភាគីជាអ្នកដាក់សំណើនោះពុំអាចធ្វើបណ្ដឹងទាស់នឹងសេចក្ដីសម្រេចនេះបានឡើយ។[85]

ដូចនេះ សរុបមក វេទិកាមជ្ឈត្តការដែលមាន *ម.ជ.ម.* ជាអញ្ញត្តករ និងស្ថាប័នគ្រប់គ្រងនេះ គឺមានសិទ្ធិអំណាចធ្វើមជ្ឈត្តកម្មតែទៅលើវិវាទពាណិជ្ជកម្មតែប៉ុណ្ណោះ ហើយប្រសិនបើ ក្នុងករណីដែលវេទិកាមជ្ឈត្តការឃើញថាវិវាទនោះមិនពាក់ព័ន្ធនឹង ឬហួសពីសមត្ថកិច្ចរបស់ខ្លួន នោះវេទិកាមជ្ឈត្តការអាចបដិសេធក្នុងការធ្វើមជ្ឈត្តកម្មលើវិវាទនោះបាន ដោយទុកសិទ្ធិក្នុងការបដិសេធលើវិវាទដោយផ្នែក ឬទាំងស្រុង ចំពោះវិវាទដែលមិនពាក់ព័ន្ធ ឬហួសដែនសមត្ថកិច្ច ពោលគឺមិនពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ឬមិនត្រូវបានព្រមព្រៀងដោយគូភាគី។ បន្ថែមពីលើនេះ ក្នុងករណីភាគីនៃវិវាទរកឃើញថា វេទិកាមជ្ឈត្តការ មានការបំពេញតួនាទីក្នុងការធ្វើមជ្ឈត្តកម្មលើសពីសមត្ថកិច្ច ឬវិសាលភាពនៃវិវាទដែលបានកំណត់ដោយគូភាគី នោះគូភាគីដែលខាតបង់ប្រយោជន៍នោះ អាចធ្វើសំណើទៅកាន់តុលាការមានសមត្ថកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការសម្រេចលើសមត្ថកិច្ចមជ្ឈត្តការនោះបាន ក្នុងអំឡុងពេល សាមសិប ថ្ងៃ ក្រោយពីថ្ងៃបានដឹងលឺអំពីបញ្ហានោះ។

### ២.១.៣. ការតែងតាំងមជ្ឈត្តករ

ក្រោយការពិនិត្យទៅលើសុពលភាព និងភាពត្រឹមត្រូវរបស់កិច្ចព្រមព្រៀងមជ្ឈត្តកម្ម ជាមូលដ្ឋានផ្សេងទៀត ដែលភាគីវិវាទអាចសំអាងគឺ ការតែងតាំងមជ្ឈត្តករ ដើម្បីដោះស្រាយវិវាទរបស់ខ្លួន។ ក្នុងការតែងតាំងមជ្ឈត្តករនេះផងដែរ មានចំនួន បីចំណុច សំខាន់ៗ សម្រាប់យកមកពិនិត្យពិច័យ រួមមាន សមាសភាពនៃមជ្ឈត្តករ (២.១.៣.១) ការតែងតាំងមជ្ឈត្តករ (២.១.៣.២.) និងការប្ដឹងជំទាស់នឹងសមាសភាពមជ្ឈត្តករ (២.១.៣.៣.)។

[82] *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ២៤ (២)។

[83] *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ២៤។

[84] *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ២៤ (៣)។

[85] *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ២៤ (៣)។

### ២.១.៣.១. សមាសភាពនៃមជ្ឈត្តករ

ជាបឋម *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* បានចែងថា មជ្ឈត្តករ គឺជារូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬបរទេសដែលបានចុះបញ្ជីនៅ *ម.ជ.ម.* ហើយត្រូវបានតែងតាំងក្នុងវេទិកាមជ្ឈត្តការ។[86] ក្នុងចំណុចខាងក្រោម នឹងបន្តពិនិត្យមើលទៅលើ សមាសភាពនៃមជ្ឈត្តករដោយផ្តួចផ្តើមចេញពី ការសិក្សាទៅលើលក្ខណៈសម្បត្តិ (២.១.៣.១.១.) រួមទាំងការកំណត់នូវចំនួនមជ្ឈត្តកដោយភាគី ឬតាមគោលការណ៍នៃបទដ្ឋានគតិយុត្តជាធរមាន (២.១.៣.១.២.)។

#### ២.១.៣.១.១. លក្ខណៈសម្បត្តិរបស់មជ្ឈត្តករ

លក្ខណៈសម្បត្តិរបស់មជ្ឈត្តករដំបូងបំផុត គឺសម្តៅដល់សមាជិកភាពរបស់មជ្ឈត្តករនោះ នៅក្នុងមជ្ឈមណ្ឌលមជ្ឈត្តកម្មដែលមានការទទួលស្គាល់ និងបង្កើតឡើងដោយច្បាប់ជាធមាន ពោលគឺនៅ ព្រះរាជាណាចក្រកម្ពុជា មជ្ឈត្តករនោះត្រូវតែមានការចុះបញ្ជីជាសមាជិកនៅក្នុង*ម.ជ.ម.*។[87] ការចុះបញ្ជីនេះទៀតសោត គឺបានផ្តល់នូវកាលានុវត្តន៍ភាពទូលំទូលាយ ដល់ការស្នើសុំចុះបញ្ជីជាមជ្ឈត្តករនៅ *ម.ជ.ម.* ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលអាចស្នើសុំធ្វើជាសមាជិកបាន ដោយមានសមាសភាព ដូចតទៅ៖ សភាពាណិជ្ជកម្ម គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងបណ្តាសមាគមទាំងឡាយដែលមានសមាជិកប្រមូលផ្តុំជាពាណិជ្ជករ ឧស្សាហករ អាជីវករ ឬសេវាករ។[88] ចំពោះការស្នើសុំនូវសមាជិកភាពនេះ គឺនឹងត្រូវពិនិត្យ និងសម្រេចដោយ ក្រុមប្រឹក្សាប្រតិបត្តិនៃ *ម.ជ.ម.* មិនលើសពីប្រាំពីរនាក់។[89] យ៉ាងណាមិញ ក្នុងបរិបទនៃប្រព័ន្ធមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា បានកំណត់ថា បុគ្គលទាំងឡាយណាដែលមិនបានចុះបញ្ជីជាមួយ *ម.ជ.ម.* ឬបុគ្គលរូបណាដែលមិនបានបំពេញតួនាទី ឬចុះបញ្ជីជាមួយស្ថាប័នមជ្ឈត្តករផ្នែកពាណិជ្ជកម្មដែលទទួលស្គាល់ដោយ *ម.ជ.ម.* ទាំងក្នុងស្រុក ឬទាំងក្រៅស្រុក គឺមិនអាចត្រូវបានតែងតាំងជាមជ្ឈត្តករបាននោះទេ។[90] បន្ថែមពីលើលក្ខខណ្ឌសមាជិកភាពនៃមជ្ឈត្តករ គឺការកំណត់ទៅលើលក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ដោយភាគីនៃវិវាទអាចបញ្ជាក់ក្នុងខចែងនៃកិច្ចសន្យាពាណិជ្ជកម្មខ្លួនបានថា ភាគីនៃវិវាទទាមទារឱ្យ មជ្ឈត្តករដែលនឹងត្រូវតែងតាំងនោះចាំបាច់ត្រូវមានបទពិសោធន៍ និងចំណេះដឹងខាងវិស័យណាមួយនៃវិវាទនោះ ពោលគឺ ភាគីអាចទាមទារឱ្យមជ្ឈត្តករមានពុទ្ធិវិស័យសេវាដឹកជញ្ជូន វិស័យបច្ចេកវិទ្យា វិស័យពាក់ព័ន្ធទៅនឹងកម្មសិទ្ធិបញ្ញា ឬវិស័យពាណិជ្ជកម្ម ដូចជាការ

---

86 *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ២ និង មាត្រា ១១។

87 *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១១។

88 *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១២។

89 *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១២។

90 *វិធាន ម.ជ.ម. ថ្មី*, ប្រការ ២៦។

ទិញសិទ្ធិប្រកបអាជីវកម្ម (ហ្វ្រេនឆាយ)[91] ជាដើម។ គួរបញ្ជាក់ផងដែរថា ភាគីនៃវិវាទហាក់បីដូចជាមានសិទ្ធិសេរីភាពក្នុងការកំណត់លើកិច្ចការមួយចំនួនដូចជា ការតែងតាំងនូវមជ្ឈត្តករ និងសិទ្ធិសេរីភាពផ្សេងៗទៀតដែលនឹងបង្ហាញជូននៅចំណុចបន្តបន្ទាប់នេះ គឺដោយសារតែ មជ្ឈត្តកម្ម គឺជាសេវានៃការដោះស្រាយវិវាទតាមរយៈក្រៅប្រព័ន្ធតុលាការ ហេតុដូច្នេះហើយ វាចាំបាច់ត្រូវតែផ្តល់នូវសេរីភាពដល់ភាគី ក្នុងការកំណត់នូវបទដ្ឋានរបស់ខ្លួនដើម្បីដោះស្រាយវិវាទទាំងឡាយ ដែលកើតឡើងឱ្យស្របទៅតាមបរិបទមួយដែលភាគីទាំងសងខាងរំពឹងទុក។ ហើយទោះបីជាសេរីភាពទាំងឡាយ ត្រូវបានផ្តល់ដល់ភាគីក៏ពិតមែន ប៉ុន្តែសិទ្ធិសេរីភាពទាំងនោះ ទាមទារឱ្យអនុលោមទៅតាមបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធទៅនឹងមជ្ឈត្តកម្ម និងដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ និងលក្ខណៈជាតិផងដែរ។ មិនតែប៉ុណ្ណោះ ក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ ក៏បានបង្ហាញអំពីជម្រើសនៃវិធានមជ្ឈត្តកម្ម ដែលភាគីបានជ្រើសរើសនោះ ហើយវិធាននោះភាគីចាំបាច់ត្រូវតែ អនុវត្តតាមក្នុងនីតិវិធីនៃមជ្ឈត្តការទាំងមូលតែម្តង។ ជាទូទៅ វិធានមជ្ឈត្តកម្ម ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកដូចដែលបានជម្រាបជូនពីខាងដើម *ម.ជ.ម.* របស់កម្ពុជា បានបង្កើតនូវវិធានរបស់ខ្លួនគឺ *វិធាននៃ ម.ជ.ម.*[92] រីឯ*ម.ជ.ម* របស់ប្រទេសសិង្ហបុរី ក៏មាននូវវិធានផ្ទាល់ខ្លួន[93] ហើយដូចគ្នាដែរ ចំពោះ *ម.ជ.ម.* របស់នៃទីក្រុងហុងកុង[94] ក៏មានចែងនូវវិធានផ្ទាល់ខ្លួនសម្រាប់កិច្ចដំណើរការនៃនីតិវិធីមជ្ឈត្តការរបស់គេផងដែរ។

### ២.១.៣.១.២. ចំនួនមជ្ឈត្តករ

ជាទូទៅ ក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ គឺមានបញ្ញត្តិស្តីពីចំនួនមជ្ឈត្តករ ដែលភាគីត្រូវការ ដើម្បីដោះស្រាយវិវាទរបស់ខ្លួន។[95] ចំនួនមជ្ឈត្តករ ដែលត្រូវបានអនុញ្ញាតឱ្យភាគីនៃវិវាទ តែងតាំងនោះ គឺចាំបាច់ត្រូវតែមានចំនួនសេស ពោលគឺ មជ្ឈត្តករទោល ឬមជ្ឈត្តករ ចំនួនបីនាក់ ហើយក្នុងករណីណាដែលភាគីពុំបានកំណត់អំពីចំនួនមជ្ឈត្តករទេនោះ ច្បាប់បានតម្រូវឱ្យកំណត់យកចំនួនមជ្ឈត្តករចំនួន បី នាក់ តែម្តង។[96] ជាទូទៅ ក្នុងការ

[91] ប្រកាសស្តីពី ការកត់ត្រា កិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម, លេខ ០៣៦ ព.ណ.កសប.ប្រក, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០, ប្រការ ៤។ ហ្វ្រេនឆាយ គឺជាពាក្យកម្ចីពីភាសាបរទេសដែលគេតែងច្រើនប្រើជារឿយៗជាប្រចាំថ្ងៃ ដើម្បីសម្តៅដល់ការទិញលក់សិទ្ធិប្រកបអាជីវកម្ម។ ពាក្យនេះជាគឺមានសូរ និងអត្ថន័យដូចគ្នាទៅនឹងពាក្យ «Franchise» ជាភាសាអង់គ្លេស។

[92] *វិធាននៃ ម.ជ.ម. ថ្មី*។

[93] *វិធាននៃមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់សិង្ហបុរី*, ផ្សព្វផ្សាយដោយ *ម.ជ.ម* សិង្ហបុរី, [បានចូលមើលនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១], តំណ https://www.siac.org.sg/our-rules/rules/siac-rules-2016។

[94] *វិធាននៃមជ្ឈមណ្ឌលអន្តរជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ហុងកុង*, ផ្សព្វផ្សាយដោយ *ម.ជ.ម*ហុងកុង, [បានចូលមើលនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១], តំណ https://www.hkiac.org/arbitration/rules-practice-notes។

[95] *សូមមើល ឧបសម្ព័ន្ធ ២ ស្តីពីគម្រូខចែងអំពីមជ្ឈត្តការនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*។

[96] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៨។

អនុវត្តជាក់ស្តែង ចំនួនមជ្ឈត្តករ គឺអាស្រ័យទៅនឹងទំហំនៃវិវាទ ឬចំនួនទឹកប្រាក់ដែលកើតចេញពីវិវាទនោះ។ ប្រសិនបើជម្លោះមានទឹកប្រាក់ច្រើន រមែងតែងផ្តល់នូវភាពស្មុគស្មាញខ្លាំងដល់ការដោះស្រាយ ដូចនេះ ដើម្បីធានាបានថាការដោះស្រាយវិវាទអាចធ្វើទៅបានដោយឆាប់រហ័ស និងសមប្រកបនោះ គឺចាំបាច់ត្រូវមានចំនួនមជ្ឈត្តករច្រើន ចូលរួមសម្រេច និងដោះស្រាយ។ ដោយឡែកប្រសិនបើកម្មវត្ថុនៃបណ្តឹងមានទឹកប្រាក់តិច ជាទូទៅគឺពុំចាំបាច់មានការដោះស្រាយដោយមជ្ឈត្តករច្រើនរូបនោះទេ ពីព្រោះចំនួននៃមជ្ឈត្តករ រួមទាំងទំហំនៃវេទិកាមជ្ឈត្តកម្ម សុទ្ធសឹងតែគិតគូរជាចំណាយបន្ថែមដល់គូភាគីនៃវិវាទ។[97] យ៉ាងណាមិញ ទាំង *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* និងទាំង *វិធាននៃ ម.ជ.ម. ថ្មី* ក៏ពុំមានចែងច្បាស់លាស់អំពីការកំណត់នូវចំនួនមជ្ឈត្តករ តាមកម្រិតចំនួនទឹកប្រាក់ដែលជាកម្មវត្ថុនៃវិវាទឡើយ ហេតុដូចនេះ ភាគីនៃវិវាទនៅតែអាចសម្រេចបាននូវចំនួនមជ្ឈត្តករតាមការព្រមព្រៀង និងបំណងរបស់ខ្លួនបាន។

### ២.១.៣.២. នីតិវិធីនៃការតែងតាំងមជ្ឈត្តករ

លុះមកដល់ នីតិវិធីនៃការតែងតាំងមជ្ឈត្តករវិញ គឺច្បាប់បានប្រគល់សេរីភាពដល់គូភាគីក្នុងការជ្រើសរើសមជ្ឈត្តករ។ ក្នុងការតែងតាំងមជ្ឈត្តករ ត្រូវអនុវត្ត និងពិចារណាតាមប្រាំចំណុចសំខាន់ៗដែលមានចែងនៅក្នុង*ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*។[98] ចំណុចទីមួយ គឺភាគីមិនអាចបដិសេធចំពោះបុគ្គលណាក្នុងការធ្វើជាមជ្ឈត្តករ ដោយមូលហេតុសញ្ជាតិបាននោះទេ លើកលែងតែគូភាគីបានព្រមព្រៀងគ្នារួច ហើយចំណុចទីពីរ គឺភាគីអាចធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសចំនួនមជ្ឈត្តករបាន ដោយចាំបាច់ត្រូវមានចំនួនសេស ពោលគឺមួយរូប ឬបីរូប។[99] ចំណុចទីបី ក្នុងករណីដែលគូភាគីពុំបានព្រមព្រៀងគ្នាអំពីនីតិវិធីនៃការតែងតាំងមជ្ឈត្តករទេនោះ ចំពោះវេទិកាមជ្ឈត្តការដែលមានមជ្ឈត្តករចំនួនបីរូប គឺភាគីនៃវិវាទ ត្រូវជ្រើសរើសមជ្ឈត្តករម្នាក់មួយរូប ហើយមជ្ឈត្តករដែលត្រូវបានតែងតាំងនោះ ត្រូវបន្តតែងតាំងមជ្ឈត្តករទីបី ដើម្បីបង្គ្រប់ចំនួនមជ្ឈត្តករសរុប។[100] គួរបញ្ជាក់ផងដែរថា ចំពោះថេរវេលានៃការតែងតាំង គឺភាគីមានរយៈពេល សាមសិប ថ្ងៃ ក្រោយពេលទទួលបានដំណឹងអំពីការជ្រើសតាំងមជ្ឈត្តករដោយភាគីម្ខាងទៀត ដើម្បីតែងតាំងមជ្ឈត្តករមួយរូប ហើយដូចគ្នាដែរចំពោះមជ្ឈត្តករទាំងពីរដែលត្រូវបានតែងតាំងដោយភាគីនៃវិវាទនោះ មានរយៈពេល សាមសិប ថ្ងៃក្រោយការតែងតាំងនោះ ដើម្បីធ្វើការតែងតាំងមជ្ឈត្តករទីបី។[101] ក្នុងករណីដែល សាមសិប ថ្ងៃ ត្រូវបានកន្លងផុត ហើយភាគីមិនបាន

---

[97] *សូមមើល*ឧបសម្ព័ន្ធ ៣ ចំពោះ *តារាងតម្លៃនៃកម្រៃសេវារដ្ឋបាល និងកម្រៃសេវាវេទិកាមជ្ឈត្តការ*ដែលដកស្រង់ចេញពី*វិធានម.ជ.ម. ថ្មី*។

[98] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩។

[99] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩ (១) និងមាត្រា ១៩ (២)។

[100] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩ (៣)។

[101] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩ (៣)។

តែងតាំងមជ្ឈត្តករមួយ ឬមជ្ឈត្តករទាំងពីរមិនបានតែងតាំងមជ្ឈត្តករទីបី នោះតុលាការ ឬ *ម.ជ.ម.* ត្រូវតែតែងតាំងនូវសមាសភាពនៃមជ្ឈត្តករដែលខ្វះនោះឱ្យខានតែបាន តាមការស្នើសុំរបស់ភាគីនៃវិវាទណាមួយ។[102] ដោយឡែក ប្រសិនបើក្នុងករណីដែលវេទិកាមជ្ឈត្តការ ត្រូវការតែមជ្ឈត្តករតែមួយរូប ហើយភាគីពុំបានព្រមព្រៀងគ្នាទៅលើនីតិវិធីនៃការតែងតាំងទេ នោះតុលាការ ឬ*ម.ជ.ម.* ត្រូវតែធ្វើការតែងតាំងនូវមជ្ឈត្តករនោះតាមការស្នើសុំរបស់ភាគីណាមួយនៃវិវាទ។[103] ក្នុងការតែងតាំងមជ្ឈត្តករមួយរូបនេះផងដែរ តុលាការ ឬ*ម.ជ.ម.* ត្រូវពិនិត្យពិច័យលើលក្ខណៈសម្បត្តិនៃមជ្ឈត្តករនោះ ដើម្បីធានាឱ្យបាននូវឯករាជ្យភាព និងភាពមិនលម្អៀង ក្នុងការសម្រេចសេចក្តី។[104]

យ៉ាងណាមិញ ចំណុចទីបួននៃមាត្រាដដែល ក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាអំពីនីតិវិធីនៃការតែងតាំងមជ្ឈត្តករ ប៉ុន្តែភាគីនៃវិវាទណាមួយមិនបានអនុវត្តតាមការព្រមព្រៀងនោះ ឬភាគី ឬមជ្ឈត្តករពីររូប មិនអាចព្រមព្រៀងគ្នាបានតាមនីតិវិធីដែលបានព្រមព្រៀងគ្នានោះ ឬភាគីទីបី ដោយរាប់បញ្ចូលទាំងស្ថាប័នដែលពាក់ព័ន្ធ មិនអាចអនុវត្តនូវតួនាទីរបស់ខ្លួនបានតាមនីតិវិធីដែលបានព្រមព្រៀងទេនោះ ភាគីណាមួយអាចធ្វើការស្នើសុំទៅកាន់តុលាការ ឬ *ម.ជ.ម.* ដើម្បីចេញវិធានការចាំបាច់លើបញ្ហាទាំងនេះបាន។[105] បន្ថែមពីលើនេះ ក្នុងករណីនៃវេទិកាមជ្ឈត្តការដែលមានលក្ខណៈអន្តរជាតិវិញ ការជ្រើសតាំងមជ្ឈត្តករ ត្រូវតែពិនិត្យមើលនូវលទ្ធភាពក្នុងការតែងតាំងមជ្ឈត្តករដែលមានសញ្ជាតិខុសពីសញ្ជាតិនៃភាគីវិវាទ។[106]

### ២.១.៣.៣. ការប្តឹងជំទាស់នឹងសមាសភាពមជ្ឈត្តករ

មជ្ឈត្តករ ក្រោយដែលបានតែងតាំងរួច ក៏អាចត្រូវបានប្តឹងជំទាស់នឹងសមាសភាពនោះ ដោយមូលហេតុដែលកើតចេញពីការសង្ស័យទៅលើឯករាជ្យភាព និងអព្យាក្រឹត្យភាពរបស់មជ្ឈត្តករ រួមទាំង មូលហេតុដែលស្តែងចេញឡើងពីការមិនបានបំពេញលក្ខណៈសម្បត្តិរបស់មជ្ឈត្តករ តាមការព្រមព្រៀងរបស់ភាគីវិវាទនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ។[107] ឯករាជ្យភាព និងអព្យាក្រឹត្យភាព សម្តៅដល់ ការសម្រេចសេចក្តីរបស់មជ្ឈត្តករដោយភាពយុត្តិធម៌ សមហេតុសមផល មានសំអាងហេតុ មានសំអាងច្បាប់ត្រឹមត្រូវ មានចំណេះវិជ្ជា វិជ្ជាជីវៈត្រឹម

---

[102] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩ (៣)។

[103] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩ (៣)។

[104] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩ (៤)។

[105] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩ (៤)។

[106] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ១៩ (៥)។

[107] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ២០ និង មាត្រា ២១។ *សូមមើលបន្ថែម វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ២៨.១ ស្តីពីឯករាជ្យភាព និងអព្យាក្រឹត្យភាព។

ត្រូវ មិនស្ថិតនៅក្រោមការគាបសង្កត់ដោយភាគីណាមួយ ឬមានសេចក្តីភ័យខ្លាចចំពោះការសម្រេចក្តីដោយមូលហេតុណាមួយឡើយ។ ច្បាប់ បានប្រគល់កាតព្វកិច្ចជូនទៅដល់ មជ្ឈត្តករ ក្នុងការបង្ហាញនូវបញ្ហាទាំងឡាយនេះជូនដល់ភាគីវិវាទ ចាប់ពីពេលចាប់ផ្តើម នីតិវិធីមជ្ឈត្តការ រហូតដល់ការបញ្ចប់នីតិវិធីនោះ ដោយគ្មានការពន្យាពេលអ្វីឡើយ។[108] យោងតាមស្មារតី មាត្រា ២០ នៃ*ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* បានកំណត់បង្ហាញឱ្យជ្រាបថា មជ្ឈត្តករ តម្រូវឱ្យមានការរាយការណ៍ និងរក្សានូវឯករាជ្យភាព និងអព្យាក្រឹត្យភាពរបស់ខ្លួន មិនបំពេញតួនាទីជាអ្នកគាំទ្រ ឬជាទីប្រឹក្សារបស់ភាគីវិវាទណាមួយ ចាប់ពីពេលដែលខ្លួនត្រូវបានតែងតាំងជាមជ្ឈត្តករ រហូតដល់ការបញ្ចប់នូវនីតិវិធីទាំងឡាយនៃមជ្ឈត្តកម្ម។[109] ពោលគឺ រាល់បញ្ហាទាំងឡាយដែលនាំឱ្យប៉ះពាល់ដល់ឯករាជ្យភាព ឬអព្យាក្រឹត្យភាព ដោយរាប់បញ្ចូលទាំងទំនាស់ផលប្រយោជន៍ទាំងឡាយដែលអាចកើតមាននោះ ចាំបាច់ត្រូវតែរាយការណ៍ជាបន្ទាន់ដល់ភាគីនៃវិវាទ ដើម្បីមានចំណាត់ការលើបញ្ហានេះ។ យ៉ាងណាមិញ ភាគីមិនអាចប្តឹងជំទាស់នឹងមជ្ឈត្តករដែលខ្លួនបានតែងតាំង ដោយសំអាងលើមូលហេតុទាំងនេះបានឡើយ ក្នុងករណីដែលខ្លួនបានដឹងអំពីបញ្ហានេះមុនការតែងតាំងនោះ។ ក្នុងន័យសាមញ្ញ មានន័យថា ភាគីនៃវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តករ ដែលខ្លួនបានតែងតាំងនោះបាន តែនៅក្នុងករណីដែលភាគីវិវាទបានដឹងអំពីមូលហេតុដើម្បីជំទាស់នោះក្រោយការតែងតាំងតែប៉ុណ្ណោះ។[110]

នៅក្នុងចំណុចបន្តបន្ទាប់ សារណានេះនឹងពិនិត្យមើលលំអិតទៅលើ ការប្តឹងជំទាស់នឹងមជ្ឈត្តករដែលបានតែងតាំងរួច (២.១.៣.៣.១) និងការតែងតាំងមជ្ឈត្តករជំនួស (២.១.៣.៣.២)។

#### ២.១.៣.៣.១. ការប្តឹងជំទាស់នឹងមជ្ឈត្តករដែលបានតែងតាំងរួច

ការប្តឹងជំទាស់នឹងមជ្ឈត្តករដែលបានតែងតាំងរួច ត្រូវធ្វើឡើងបានតែក្នុងកាលៈទេសៈដែលមានការសង្ស័យសមហេតុសមផលចំពោះឯករាជ្យភាព ឬអព្យាក្រឹត្យភាពរបស់មជ្ឈត្តករ ឬក្នុងករណីដែលមជ្ឈត្តករពុំមានលក្ខណៈសម្បត្តិតាមការព្រមព្រៀងរបស់គូភាគី។ ក្នុងចំណុចនេះ នឹងធ្វើការពិនិត្យមើលទៅលើបែបបទ និងនីតិវិធីក្នុងការប្តឹងជំទាស់នឹងសមាសភាពមជ្ឈត្តករដែលបានតែងតាំងរួច។

ជាដំបូង នៅពេលដែលភាគីវិវាទ មានបំណងក្នុងការប្តឹងជំទាស់ *វិធាននៃ ម.ជ.ម. ថ្មី* តម្រូវឱ្យភាគីនៃវិវាទ ធ្វើការជូនដំណឹងអំពីការជំទាស់ ដោយភ្ជាប់មកជាមួយនូវ មូលហេតុនៃការជំទាស់ទៅ វេទិកាមជ្ឈត្តការ ឬភាគីវិវាទម្ខាងទៀត ឬអគ្គលេខាធិការដ្ឋាននៃ*ម.ជ.ម.* ក្នុងរយៈពេល ដប់ប្រាំ ថ្ងៃប្រតិទិន បន្ទាប់ពីភាគី

108 *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ២០ និង មាត្រា ២១។

109 *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ២០។ *សូមមើលបន្ថែម វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ២១.១ ស្តីពីឯករាជ្យភាព និងអព្យាក្រឹត្យភាព។

110 *សូមមើលបន្ថែម វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ២៨ ស្តីពីការជំទាស់ទៅនឹងមជ្ឈត្តករ។

នៃវិវាទបានជួបប្រទះនឹងករណីណាមួយដែលខ្លួនសង្ស័យ ស្របតាម *ប្រការ ២៨ នៃ វិធានម.ជ.ម. ថ្មី*។[111] ក្រោយការទទួលបាននូវសេចក្តីជូនដំណឹង អំពីការជំទាស់ទៅនឹងសមាសភាពនៃមជ្ឈត្តករនោះ មជ្ឈត្តករដែលត្រូវបានជំទាស់ ឬភាគីនៃវិវាទម្ខាងទៀត មានរយៈពេល ដប់ប្រាំថ្ងៃប្រតិទិនបន្តទៀត ដើម្បីធ្វើការបញ្ចេញយោបល់លើការជំទាស់នេះទៅ វេទិកាមជ្ឈត្តការ ឬភាគីម្ខាងទៀត ឬអគ្គលេខាធិកាដ្ឋាន នៃ*ម.ជ.ម.* នោះបាន ហើយការប្តឹងជំទាស់នេះ នឹងត្រូវបានយកមកពិនិត្យពិច័យ និងពិចារណាដោយ *គណៈកម្មាធិការតែងតាំង និងនីតិវិធី*[112] *នៃ ម.ជ.ម.*។[113] យ៉ាងណាមិញ ក្នុងករណី វេទិកាមជ្ឈត្តការ មានមជ្ឈត្តករលើសពីមួយរូប ការយល់ស្របទៅតាមភាគីម្ខាងទៀតចំពោះការជំទាស់អំពីសមាសភាពនៃមជ្ឈត្តករណាមួយនោះ គឺនាំឱ្យមជ្ឈត្តករដែលត្រូវបានប្តឹងជំទាស់នោះ ត្រូវដកខ្លួនចេញពីវេទិកាមជ្ឈត្តការតែម្តង។[114] ចំណែកឯ ក្នុងករណីវេទិកាមជ្ឈត្តការមានមជ្ឈត្តករទោលវិញ ប្រសិនបើការប្តឹងជំទាស់នោះ មិនត្រូវបានជំទាស់ដោយភាគីម្ខាងទៀត ឬមជ្ឈត្តករនោះផ្ទាល់នោះទេ គឺមជ្ឈត្តករនោះនឹងត្រូវជំនួសដោយមជ្ឈត្តករថ្មីមួយរូបទៀត។ យ៉ាងណាមិញ ចំពោះវេទិកាមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយរូប ឬមួយរូបក្តី កាលណាបើមជ្ឈត្តករនោះទទួលបានការជូនដំណឹង អំពីការប្តឹងជំទាស់ហើយ តែខ្លួនមានបំណងក្នុងការបដិសេធនឹងបណ្តឹងនោះ នោះមជ្ឈត្តករដែលត្រូវបានប្តឹងជំទាស់នោះ មានរយៈពេល ប្រាំពីរថ្ងៃប្រតិទិន ក្រោយការជូនដំណឹងដើម្បីធ្វើការឆ្លើយតប និងបដិសេធក្នុងការដកខ្លួនចេញពីវេទិកាមជ្ឈត្តការបាន។[115]

ដំណាក់កាលចុងក្រោយ គឺនៅពេលដែលអគ្គលេខាធិការដ្ឋាននៃ*ម.ជ.ម.* បានទទួលនូវការតវ៉ាអំពីការជំទាស់នេះ គណៈកម្មាធិការតែងតាំង និងនីតិវិធី មានពេល ដប់ប្រាំ ថ្ងៃប្រតិទិន ដើម្បីធ្វើការសម្រេចលើការប្តឹងជំទាស់អំពីសមាសភាពនៃមជ្ឈត្តករ ដែលបានធ្វើឡើងដោយភាគីវិវាទ។ តបតាមការសម្រេចលើការប្តឹងជំទាស់នេះ ប្រសិនបើគណៈកម្មាធិការយល់ស្របទៅនឹងបណ្តឹងនេះ មជ្ឈត្តករត្រូវបញ្ឈប់ ដោយមានប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចនោះ ប៉ុន្តែប្រសិនបើគណៈកម្មាធិការ យល់ឃើញថាការប្តឹងជំទាស់ មិនសមស្រប ហើយបដិសេធលើបណ្តឹងនោះ គឺនាំឱ្យ មជ្ឈត្តករ ដែលត្រូវបានប្តឹងនោះនៅបន្តបំពេញតួនាទីរបស់ខ្លួនជា

[111] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ២៨.២ ស្តីពី សេចក្តីជូនដំណឹងអំពីការជំទាស់ទៅនឹងមជ្ឈត្តករ ពេលវេលាកំណត់ និងកម្រៃសេវាជំទាស់។

[112] យោងតាម ប្រការ ១ នៃ *វិធាន ម.ជ.ម. ថ្មី* បានឱ្យនិយមន័យថា «គណៈកម្មាធិការតែងតាំង និងនីតិវិធី» គឺជាគណៈកម្មាធិការមួយរបស់ *ម.ជ.ម.* ដែលទទួលបន្ទុក និងមានអំណាចក្នុងការតែងតាំងមជ្ឈត្តករ រួមទាំងបំពេញកិច្ចការផ្សេងទៀតស្របតាមវិធាននេះ។

[113] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ២៨.៣ ស្តីពី យោបល់ចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ។

[114] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ២៨.៤ ស្តីពី យោបល់ចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ។

[115] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ២៨.៤ ស្តីពី ការដកខ្លួនរបស់មជ្ឈត្តករដែលត្រូវបានជំទាស់ និងការសម្រេចរបស់វេទិកាមជ្ឈត្តការ។

មជ្ឈត្តករនៃវិវាទនោះដដែល។[116] គួរបញ្ជាក់ផងដែរថា មិនមានការប្ដឹងឧបាស្រ័យអំពីបញ្ហានេះឡើយ ដូចនេះ សេចក្ដីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី គឺជាសេចក្ដីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា។[117] បន្ថែមពីលើនេះ ចំពោះការប្ដឹងជំទាស់នឹងសមាសភាពនៃមជ្ឈត្តករ ក៏ត្រូវបានកំណត់នូវកម្រៃសេវាចំពោះនីតិវិធីដែលពាក់ព័ន្ធទៅនឹងបណ្ដឹងនេះផងដែរ។[118]

**២.១.៣.៣.២. ការតែងតាំងមជ្ឈត្តករជំនួស**

បន្ទាប់ពីមជ្ឈត្តករ ត្រូវបានបញ្ឈប់នូវអាណត្តិរបស់ខ្លួនដោយសារការប្ដឹងជំទាស់ ឬមូលហេតុផ្សេងៗទៀតដែលស្របនឹងវិធាននេះ ឬមជ្ឈត្តករនោះទទួលមរណភាព ដកខ្លួន ឬលាលែងពីតំណែង នោះត្រូវមានការជំនួសដោយមជ្ឈត្តករដទៃទៀត។[119] ក្នុងការតែងតាមជ្ឈត្តករជំនួស គឺអាចត្រូវបានធ្វើឡើងដោយ*ម.ជ.ម.* ឬដោយភាគីវិវាទ។[120]

ការតែងតាំងមជ្ឈត្តករជំនួសដោយ *ម.ជ.ម.* គឺត្រូវធ្វើឡើង ក្រោយសំណើរបស់ភាគីវិវាទបានទៅដល់អគ្គលេខាធិការដ្ឋាន និងបន្ទាប់ពិបានទុកឱកាសឱ្យភាគីវិវាទ និងមជ្ឈត្តករនៃវេទិកាមជ្ឈត្តការបានផ្ដល់យោបល់រួច។ ប្រសិនបើក្នុងករណីដែល គណៈកម្មាធិការតែងតាំង និងនីតិវិធី យល់ឃើញថាការដែលទុកឱ្យភាគីវិវាទធ្វើការតែងតាំងមជ្ឈត្តករជំនួសនោះ អាចធ្វើឱ្យមានការរាំងស្ទះ ឬមានការពន្យាពេលដែលមិនចាំបាច់ នោះគណៈកម្មាធិការ អាចធ្វើការតែងតាំងជំនួសមុខឱ្យគូភាគីបាន។[121] ដោយឡែក ចំពោះការតែងតាំងមជ្ឈត្តករជំនួសដោយភាគីវិវាទ គឺត្រូវធ្វើឡើងស្របតាម *ប្រការ ២៥ នៃវិធាន ម.ជ.ម.ថ្មី* ដូចបានរៀបរាប់ជូននៅចំណុចខាងលើ។ គួរបញ្ជាក់ផងដែរអំពីថេរវេលានៃការតែងតាំងនោះ គឺត្រូវនឹង ដប់ប្រាំ ថ្ងៃប្រតិទិន ក្រោយភាគីវិវាទដែល

---

116 *វិធាននៃ ម.ជ.ម. ថ្មី,* ប្រការ ២៨.៥ ស្ដីពី សេចក្ដីសម្រេចរបស់ *ម.ជ.ម.* លើការជំទាស់ទៅនឹងមជ្ឈត្តករ។

117 *វិធាននៃ ម.ជ.ម. ថ្មី,* ប្រការ ២៨.៦ ស្ដីពី ការបិទផ្លូវតវ៉ា និងការជូនដំណឹង។

118 *សូមមើល* ឧបសម្ព័ន្ធ ១ នៃ *វិធាន ម.ជ.ម. ថ្មី* ស្ដីពីកម្រៃសេវាជំទាស់ ដែលមានចែងដូចតទៅៈ

> «៤. កម្រៃសេវាជំទាស់៖ នៅពេលដាក់សេចក្ដីជូនដំណឹងអំពីការជំទាស់ទៅនឹងមជ្ឈត្តករដូចមានចែងក្នុងប្រការ ២៨.២ (*សេចក្ដីជូនដំណឹងអំពីការជំទាស់ទៅនឹងមជ្ឈត្តករ ពេលវេលាកំណត់ និងកម្រៃសេវាជំទាស់*) ភាគីវិវាទនោះត្រូវបង់កម្រៃសេវាជំទាស់ចំនួន ៥០០ (ប្រាំរយ) ដុល្លាអាមេរិច ដោយមិនមានការបង់សងមកវិញឡើយ។»

119 *វិធាននៃ ម.ជ.ម. ថ្មី,* ប្រការ ៣០ ស្ដីពី ការដាក់មជ្ឈត្តករជំនួស និង ប្រការ ៣០.១ ស្ដីពី មូលហេតុនៃការដាក់ជំនួស។

120 *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម,* មាត្រា ១៩ និង មាត្រា ២៣។ *សូមមើលបន្ថែម វិធាននៃ ម.ជ.ម. ថ្មី,* ប្រការ ៣០ ស្ដីពី ការដាក់មជ្ឈត្តករជំនួស។

121 *វិធាននៃ ម.ជ.ម. ថ្មី,* ប្រការ ៣០.៣ ស្ដីពី ការតែងតាំងមជ្ឈត្តករជំនួសដោយ *ម.ជ.ម.*។

ត្រូវតែងតាំងមជ្ឈត្តករជំនួស ទទួលបានសេចក្តីជូនដំណឹងអំពីការដាក់មជ្ឈត្តករជំនួស ភាគីវិវាទត្រូវតែសម្រេចតែងតាំងនូវ មជ្ឈត្តករថ្មីមកជំនួសសមាសភាពមជ្ឈត្តករដែលត្រូវជំនួសឱ្យខានតែបាន។[122]

យ៉ាងណាមិញ ចំពោះករណីដែលនីតិវិធីបានបន្តរួចហើយ ប៉ុន្តែក៏កើតមាននូវបណ្តឹងជំទាស់នឹងសមាសភាពមជ្ឈត្តករ ឬត្រូវមានការតែងតាំងមជ្ឈត្តករជំនួសដោយប្រការណាមួយស្របតាមមូលហេតុនៃការដាក់ជំនួសនោះ គឺសវនាការដែលបានធ្វើហើយ ត្រូវតែធ្វើឡើងវិញសារជាថ្មី។ ក្នុងករណីដែលមានការជំនួសនូវមជ្ឈត្តករច្រើនរូប នោះវាអាស្រ័យទៅតាមឆន្ទានុសិទ្ធិរបស់វេទិកាមជ្ឈត្តការ និងការពិភាក្សាជាមួយភាគីវិវាទ ថានឹងបន្តសុពលភាពនៃនីតិវិធីដដែល ឬធ្វើឡើងសារជាថ្មី។ មួយវិញទៀត ជាកំណត់សម្គាល់សំខាន់នោះគឺ ប្រសិនបើវេទិកាមជ្ឈត្តការបានចេញនូ វមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន ឬមជ្ឈត្តវិនិច្ឆ័យដោយផ្នែក រួចរាល់ហើយនោះ សវនាការទាំងឡាយដែលពាក់ព័ន្ធទៅនឹងមជ្ឈត្តវិនិច្ឆ័យដែលបានចេញរួចហើយនោះ គឺមិនត្រូវធ្វើឡើងសារជាថ្មីនោះទេ ដោយបន្តនូវសុពលភាពនៃមជ្ឈត្តវិនិច្ឆ័យនោះដដែល។[123]

## ២.២. នីតិវិធីនៃការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

ក្រោយពីបានទទួលជ្រាបអំពីមូលដ្ឋាននៃការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យហើយ ជាកិច្ចបន្ទាប់ នឹងពិនិត្យមើលទៅនីតិវិធីក្នុងការប្តឹងជំទាស់ ក្រោមរូបភាពជាការអនុវត្តជាក់ស្តែងវិញម្តង។ ជាទូទៅ ក្នុងការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ភាគីនៃវិវាទចាំបាច់ត្រូវតែធ្វើការប្តឹងតាមផ្លូវតុលាការ ក្រោមទម្រង់ជាបណ្តឹងបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យ។[124] ដើម្បីជ្រាបច្បាស់អំពីនីតិវិធីនៃការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ដំបូងត្រូវយល់នូវយុត្តិកម្មក្នុងការធ្វើបណ្តឹងជំទាស់ដោយភាគីវិវាទ (២.២.១.) និងតួនាទីរបស់តុលាការក្នុងនីតិវិធីនៃការប្តឹងជំទាស់ (២.២.២.) នេះផងដែរ។

### ២.២.១. យុត្តិកម្មក្នុងការធ្វើបណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដោយភាគីវិវាទ

បន្ទាប់ពីបានជ្រាបច្បាស់នូវមូលដ្ឋានគតិយុត្តនៃការប្តឹងជំទាស់ នឹងមជ្ឈត្តវិនិច្ឆ័យនៅក្នុង*ចំណុច ២.១* ខាងលើរួចហើយ ប្រាកដជាមាននូវពុទ្ធិមូលដ្ឋានអំពីមូលហេតុដែលច្បាប់បានផ្តល់សិទ្ធិជូនទៅដល់ភាគីនៃវិវាទដើម្បីឱ្យជំទាស់នឹងសេចក្តីសម្រេចនោះ ពោលគឺតើមូលហេតុនីមួយៗនោះមានឬសគល់យ៉ាងដូចម្តេចខ្លះ ហើយតើគូភាគីអាចធ្វើការសំអាងលើមូលហេតុនីមួយៗនោះដោយរបៀបណាខ្លះបានទៀតផង។ ដូចនេះ ក្នុង *ចំណុច ២.២.ក.* នឹងបន្តមើលក្នុងបរិបទនៃការអនុវត្តជាក់ស្តែងអំពីការប្តឹងជំទាស់នេះ។

---

[122] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ៣០.២ ស្តីពី ការតែងតាំងមជ្ឈត្តករជំនួសដោយភាគីវិវាទ។

[123] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ៣០.៤ ស្តីពី លទ្ធផលនៃការដាក់មជ្ឈត្តករជំនួស។

[124] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៤៤។

យុត្តិកម្មក្នុងការធ្វើបណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ សម្តៅដល់មូលដ្ឋានគតិយុត្តដែលច្បាប់ជាធរមានបានបញ្ញត្តិនូវបទដ្ឋាននានា សម្រាប់ផ្តល់ជាមូលដ្ឋានឱ្យភាគីនៃវិវាទ អាចមានសមត្ថភាពតាមផ្លូវច្បាប់ដើម្បីជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ដែលត្រូវបានសម្រេចដោយវេទិកាមជ្ឈត្តការរួច។ ក្នុងន័យទូលាយ គឺចង់សម្តៅទៅដល់មូលហេតុនានាដែលច្បាប់បានកំណត់ ហើយដែលភាគីនៃវិវាទអាចធ្វើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យបាន។ ក្នុងនោះមានមូលហេតុចំនួនបួន ដូចដែលបានបកស្រាយយ៉ាងលំអិតនៅខាងដើម (ចំណុច ២.១.) រួចហើយដែលភាគីអាចអះអាងបាន ដើម្បីធ្វើការប្តឹងជំទាស់ទៅកាន់តុលាការ។ គួរបញ្ជាក់សារជាថ្មីផងដែរថា ភាគីនៃវិវាទក្រោយបានទទួលនូវមជ្ឈត្តវិនិច្ឆ័យ ចេញដោយវេទិកាមជ្ឈត្តការរួច អាចដាក់ពាក្យសុំបដិសេធ ក្រោមទម្រង់ជាបណ្តឹងបដិសេធបានមកកាន់តុលាការ។[125] ការដាក់ពាក្យសុំបដិសេធនេះ ត្រូវមានទឡ្ហីករណ៍ច្បាស់លាស់ និងត្រឹមត្រូវ ដើម្បីអាចប្រើប្រាស់ជាភស្តុតាងក្នុងការជំទាស់នេះបាន។ ភាគីនៃវិវាទដែលមានបំណងក្នុងការប្តឹងជំទាស់ អាចលើកឡើងនូវមូលហេតុទាំងបួននោះបានរួមមាន៖ (១) ភាគីមួយនៃកិច្ចព្រមព្រៀង បានបោះបង់សិទ្ធិមួយចំនួនតាមផ្លូវច្បាប់ ឬកិច្ចព្រមព្រៀងនោះពុំអាចយកជាការបាន ដោយហេតុថាពុំបានគោរពតាមបទបញ្ញត្តិណាមួយដែលបានចែងក្នុងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ឬ (២) ភាគីនោះមិនបានទទួលដំណឹងត្រឹមត្រូវអំពីការតែងតាំងមជ្ឈត្តករ ឬដំណើរការមជ្ឈត្តការ ឬការបង្ហាញនូវអង្គហេតុរបស់ខ្លួនពុំមានប្រសិទ្ធភាព ឬ (៣) មជ្ឈត្តវិនិច្ឆ័យ ពុំបានឆ្លើយតប ឬគោរពទៅតាមលក្ខខណ្ឌដែលគូភាគីនៃវិវាទបានព្រមព្រៀងគ្នា ឬ (៤) ការបង្កើតវេទិកាតាមមជ្ឈត្តកម្ម មិនបានធ្វើឡើងឱ្យស្របនឹងកិច្ចព្រមព្រៀងរបស់គូភាគីនៃវិវាទ។[126] ចំពោះមូលហេតុទីមួយ វាមានភាពពាក់ព័ន្ធទៅនឹងសមត្ថភាពនៃបុគ្គល រួមទាំងសុពលភាពនៃកិច្ចព្រមព្រៀង ដែលភាគីបានធ្វើឡើងតែមិនបានអនុលោមទៅតាមច្បាប់ និងវិធាននានាដែលពាក់ព័ន្ធនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅក្នុង

---

[125] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៤៤ (២)។

[126] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៤៤ (២)។ *សូមមើលបន្ថែម ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, កថាខណ្ឌទី៤២, ទំព័រទី ២៣។ កថាខណ្ឌទី៤២ នៃ*ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*មានចែងជាភាសាអង់គ្លេសដូចតទៅ៖

> […] An arbitral award may be set aside by the court [..] if:
> (a) the party making the application furnishes proof that:
> (i) a party to the arbitration […] was under some incapacity; or the said agreement is not valid under the law to which the parties have subjected it or, failing any indication thereon, under the law of this State; or
> (ii) the party making the application was not given proper notice of the appointment of an arbitrator or of the arbitral proceedings or was otherwise unable to present his case; or
> (iii) the award deals with a dispute […] not falling within the terms of the submission to arbitration, or contains decisions on matters beyond the scope of the submission to arbitration […] if the decisions on matters submitted to arbitration can be separated from those not so submitted, only that part of the award which contains decisions on matters not submitted to arbitration may be set aside; or
> (iv) the composition of the arbitral tribunal or the arbitral procedure was not in accordance with the agreement of the parties, unless such agreement was in conflict with a provision of this Law from which the parties cannot derogate, or, failing such agreement, was not in accordance with this Law […]

ព្រះរាជាណាចក្រកម្ពុជា។ ដូចនេះ ប្រសិនភាគីរកឃើញថាកិច្ចព្រមព្រៀងនោះមានភាពមិនប្រក្រតីលើចំណុចណាមួយនោះ ក្រោយមជ្ឈត្តវិនិច្ឆ័យបានសម្រេច ហើយនោះភាគីអាចដាក់បណ្ដឹងបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យបាន។ យ៉ាងណាមិញ ចំពោះចំណុចនេះ វាហាក់បីដូចជាមានអត្ថន័យមិនសូវច្បាស់លាស់ទៅលើថាតើហេតុអ្វីបានកិច្ចព្រមព្រៀងមួយដែលមិនអាចយកជាការបាន បែរជាត្រូវបានវេទិកាមជ្ឈត្តការយកមកសម្រេចសេចក្ដីនោះ។ ចំពោះបញ្ហានេះ គឺមិនមានការបកស្រាយអ្វីឱ្យបានក្បោះក្បាយនោះទេ ប៉ុន្តែយោងទៅតាមស្មារតីនៃ *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* រួមទាំង *ច្បាប់គម្រូមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* គឺបង្ហាញឱ្យឃើញថា ច្បាប់នៅបន្តផ្ដល់ឱកាសឱ្យទៅភាគីក្នុងការធ្វើបណ្ដឹងជំទាស់លើមជ្ឈត្តវិនិច្ឆ័យ ទោះបីជាសេចក្ដីសម្រេចនោះបានចេញហើយក៏ដោយ ប៉ុន្តែសុពលភាពនៃកិច្ចព្រមព្រៀង គឺនៅតែបន្តជាបញ្ហាមួយដែលភាគីអាចជីកកកាយ រែកញែករកមើលចំណុចមិនត្រឹមត្រូវបាន។ ជារួមមក ការចែងបែបនេះ គឺដើម្បីផ្ដល់សិទ្ធិដល់ភាគីវិវាទក្នុងការប្ដឹងមកកាន់តុលាការឱ្យពិនិត្យទៅលើបញ្ហានេះ ពីព្រោះ វេទិកាមជ្ឈត្តការ គឺជាការដោះស្រាយវិវាទតាមក្រៅប្រព័ន្ធតុលាការ ហើយក៏ទោះបីជាភាគីជាអ្នកសម្រេច និងព្រមព្រៀងគ្នាដោះស្រាយតាមប្រព័ន្ធនោះក៏ដោយ ក៏ច្បាប់នៅតែបន្តផ្ដល់នូវសិទ្ធិជូនទៅដល់ភាគី ដើម្បីឱ្យស្ថាប័នតុលាការ ដែលជាស្ថាប័នឯករាជ្យរបស់រដ្ឋ ធានារក្សាឱ្យបាននូវភាពយុត្តិធម៌ដល់បុគ្គលទាំងឡាយដែលត្រូវបានច្បាប់ទទួលស្គាល់ លុះដល់ទីបញ្ចប់។

**២.២.២. តួនាទីរបស់តុលាការក្នុងនីតិវិធីនៃការប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ**

យោងតាម *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* បានចែងថា សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចក្នុងការចេញសេចក្ដីសម្រេចលើការប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ដោយបន្តមាន តុលាការកំពូលជាសាលាជំនុំជម្រះក្ដីចុងក្រោយ ចំពោះករណីដែលភាគីវិវាទមានបំណង ក្នុងការធ្វើបណ្ដឹងឧបាស្រ័យជំទាស់នឹងសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍។[127] ចំពោះថេរវេលាដែលភាគីវិវាទអាចមានសមត្ថភាពក្នុងការធ្វើបណ្ដឹងឧបាស្រ័យនោះគឺ រយៈពេល ដប់ប្រាំ ថ្ងៃ ក្រោយទទួលបាននូវសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍។[128] ជាទូទៅ ភាគីនៃវិវាទ ប្រសិនបើបញ្ចប់នីតិវិធីត្រឹមវេទិកាមជ្ឈត្តការនោះ គឺពុំអាចធ្វើការប្ដឹងបែបនេះបានទេ នៅក្នុងកម្រិតមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយសារតែ មជ្ឈត្តវិនិច្ឆ័យ គឺជាសេចក្ដីសម្រេចចុងក្រោយដែលបិទផ្លូវតវ៉ា។ ប៉ុន្តែ ដោយសារតែ យន្តការនេះត្រូវបានច្បាប់ជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្ដល់សិទ្ធិដល់គូភាគីវិវាទក្នុងការធ្វើបណ្ដឹងជំទាស់ ដើម្បីបដិសេធនឹង មជ្ឈត្តវិនិច្ឆ័យមកកាន់ស្ថាប័នតុលាការ ទើបសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តការ អាចត្រូវបានយកមកពិនិត្យ និងវិនិច្ឆ័យឡើងវិញ ដោយតុលាការមានសមត្ថកិច្ច។ គួរបញ្ជាក់ផងដែរថា ការធ្វើបណ្ដឹងជំទាស់នេះ គឺមិនមែនជាការធ្វើបណ្ដឹងមួយដោយស្រេចតែបំណងរបស់ភាគីវិវាទ ដោយគ្មាន

[127] *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៤២ និង មាត្រា ៤៣។

[128] *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៤៣។

មូលហេតុ ឬភស្តុតាងត្រឹមត្រូវ ឬដើម្បីពន្យាពេលនៃការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះទេ។ ការពិនិត្យមើលទៅលើបណ្តឹងជំទាស់នេះ លុះត្រាណាតែ ភាគីវិវាទមានភស្តុតាងដាក់បន្ទុក ដូចមានចែងក្នុង *មាត្រា ៤៤ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*។[129] បន្ថែមពីលើនេះ ការពិនិត្យមើល មជ្ឈត្តវិនិច្ឆ័យនេះផងដែរ តុលាការពុំមានសិទ្ធិធ្វើការពិនិត្យមើលទៅលើ សេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តការ ទាំងស្រុងនោះទេ គឺពិនិត្យមើលតែត្រឹមក្របខណ្ឌ ឬមូលដ្ឋានដែលបានផ្តល់ជូនដល់ភាគីវិវាទក្នុងការធ្វើបណ្តឹងជំទាស់នេះ។ មូលហេតុដែលតុលាការ ពុំអាចពិនិត្យមើលមជ្ឈត្តវិនិច្ឆ័យទាំងស្រុងបាន ដោយសារតែ វេទិកាមជ្ឈត្តការ គឺជាវេទិកានៃការដោះស្រាយវិវាទដែលមានចរិតលក្ខណៈឯកជន ការពារការសម្ងាត់ទាំងឡាយរបស់គូភាគីវិវាទ ពោលគឺភាគីនៃវិវាទ បើពុំមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរនោះទេ គឺមានកាតព្វកិច្ចរក្សាសម្ងាត់ និងមិនត្រូវបង្ហាញនូវអង្គហេតុដែលពាក់ព័ន្ធទៅតតិយជន ឬបុគ្គលដទៃ ដោយគ្មានការអនុញ្ញាត ឬការព្រមព្រៀងពីភាគីម្ខាងទៀតឡើយ។[130] ប៉ុន្តែជាអញ្ញាត្រកម្មចំពោះប្រការនេះ *វិធាន ម.ជ.ម. ថ្មី* បានអនុញ្ញាតឱ្យភាគីវិវាទបង្ហាញនូវអង្គហេតុ ឬព័ត៌មានដែលពាក់ព័ន្ធ និងសំខាន់ៗ ទៅកាន់អង្គតុលាការមានសមត្ថកិច្ចបាន ក្នុងករណីដែលភាគីដាក់ពាក្យបណ្តឹងទៅកាន់តុលាការមានសមត្ថកិច្ច ដើម្បីធ្វើបណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ។[131] លើសពីនេះទៅទៀត ក្នុងករណីដែលមាន ដីកាបង្គាប់ ឬដីកាកោះរបស់តុលាការមានសមត្ថកិច្ច ភាគីនៃវិវាទចាំបាច់ជាដាច់ខាត ក្នុងការបង្ហាញនូវអង្គហេតុ ឬព័ត៌មានទាំងឡាយ តបតាមដីការបស់តុលាការមានសមត្ថកិច្ច។[132]

បើធ្វើការគ្រលេកមកមើល តួនាទីរបស់តុលាការក្រោយទទួលបាននូវ ពាក្យបណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យពីភាគីវិវាទហើយនោះគឺ សាលាឧទ្ធរណ៍ ឬតុលាការកំពូល មានតួនាទីសំខាន់ៗមួយចំនួន ដើម្បីធានានូវសេវាយុត្តិធម៌ជូនដល់គូភាគី។ ក្នុងនោះ បន្ថែមពីលើភស្តុតាងដែលភាគីបានដាក់មកតុលាការ ដើម្បីប្តឹងជំទាស់ (*ចំណុច ២.២.១.*) រួមមាន ការបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករ កាលណាបើ សាលាឧទ្ធរណ៍ និងតុលាការកំពូល យល់ឃើញថា កម្មវត្ថុនៃវិវាទ មិនអាចត្រូវបានដោះស្រាយដោយវេទិកាមជ្ឈត្តការបាន តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬមជ្ឈត្តវិនិច្ឆ័យនោះមានខ្លឹមសារ ផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រម្ពុជា។[133] យោងតាមស្មារតីនៃបញ្ញត្តិមាត្រានេះ គឺច្បាប់បានតម្រូវឱ្យតុលាការដាច់ខាត ត្រូវតែបដិសេធចោលនឹងមជ្ឈត្តវិនិច្ឆ័យ ដែលតុលាការយល់ឃើញថាកម្មវត្ថុនៃវិវាទ មិនមែនជាសមត្ថកិច្ចរបស់មជ្ឈត្តការផ្នែក

[129] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៤៥។

[130] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ៦៦ ស្តីពី ការសម្ងាត់។

[131] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ៦៦.៣ ស្តីពីការសម្ងាត់ និងការមិនបង្ហាញអង្គហេតុ។

[132] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ៦៦.៣ (ខ) ស្តីពីការសម្ងាត់ និងការមិនបង្ហាញអង្គហេតុ។

[133] *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម*, មាត្រា ៤៤ (ខ)។

ពាណិជ្ជកម្ម ឬសេចក្ដីសម្រេចដែលចេញ ដោយមជ្ឈត្តករនោះមានភាពផ្ទុយទៅនឹងគោលនយោបាយសាធារណៈរបស់ជាតិ។

### ២.២.២.១. កម្មវត្ថុនៃវិវាទ

ជាការសំខាន់ណាស់ ដែលតុលាការ ត្រូវតែបដិសេធ កាលបើរកឃើញថាកម្មវត្ថុនៃវិវាទ មិនមែនជាសមត្ថកិច្ចរបស់មជ្ឈត្តការផ្នែកពាណិជ្ជកម្មដូច្នោះ ពីព្រោះ ក្នុងករណីដែល វេទិកាមជ្ឈត្តការ ធ្វើការសម្រេចសេចក្ដីទៅលើវិវាទ លើសពីវិសាលភាពនៃអំណាចរបស់ខ្លួន ដែលត្រូវបានប្រគល់ឱ្យដោយច្បាប់ នោះអំពើនៃការរំលោភបំពាននៃដែនសមត្ថកិច្ចរបស់ខ្លួន គឺជាការរំលោភបំពានទៅលើច្បាប់ដែលមានជាធរមានដូចគ្នា ព្រមទាំងផ្ដល់នូវផលប៉ះពាល់ទៅដល់ ផលប្រយោជន៍របស់គូភាគីនៃវិវាទ ថែមទៀតផង។ ជាឧទាហរណ៍ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺមានសិទ្ធិអំណាច ធ្វើមជ្ឈត្តកម្មតែទៅលើវិវាទពាណិជ្ជកម្ម តែប៉ុណ្ណោះ ដូចនេះក្នុងករណីដែលមានការដោះស្រាយវិវាទក្រៅពីសមត្ថកិច្ចរបស់ខ្លួន ដូចជាវិវាទគ្រួសារ វិវាទរដ្ឋបាល ឬវិវាទទាំងឡាយដែលមិនមែនជាវិវាទពាណិជ្ជកម្ម នោះតុលាការមានសិទ្ធិអំណាច ក្នុងការបដិសេធចោលនូវ មជ្ឈត្តវិនិច្ឆ័យដែលបានចេញរួចនោះ។ បន្ថែមពីលើនេះ តុលាការអាចធ្វើការពិនិត្យមើលទៅលើកិច្ចព្រមព្រៀងមជ្ឈត្តការ ថាតើភាគីបានព្រមព្រៀងឱ្យដោះស្រាយវិវាទត្រង់ចំណុចណា ឬគ្រប់វិវាទដែលកើតចេញពីពាណិជ្ជកិច្ចរវាងភាគីទាំងពីរ។ មួយវិញទៀត មុនឈានដល់ការវិនិច្ឆ័យលើចំណុចនេះ តុលាការនឹងត្រូវពិនិត្យមើលផងដែរ ចំពោះការបោះបង់សិទ្ធិ ក្នុងការធ្វើបណ្ដឹងជំទាស់ទៅកាន់វេទិកាមជ្ឈត្តការ ក្នុងករណីមានការរំលោភបំពានសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តការនោះ។

ក្នុង *វិធាននៃ ម.ជ.ម. ថ្មី* បានបញ្ញត្តិនូវវិធានស្ដីពីការបោះបង់សិទ្ធិផងដែរ ដោយក្នុងប្រការនេះ គឺមានចែងអំពីករណីដែលភាគីនៃវិវាទបានដឹងថាបញ្ញត្តិផ្សេងៗដែលគ្រប់គ្រងមជ្ឈត្តការ ឬតម្រូវការណាមួយក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ ឬវិធានរបស់មជ្ឈត្តការ មិនត្រូវបានគោរព និងអនុលោមតាម ប៉ុន្តែភាគីមិនធ្វើការប្ដឹងតវ៉ាក្នុងពេលវេលាដែលបានកំណត់ (ជាទូទៅ គិតរាប់ពី សាមសិប ថ្ងៃក្រោយបានដឹង ឬជួបប្រទះនឹងបញ្ហានេះ)[134] នឹងត្រូវបានចាត់ទុកថាបានបោះបង់សិទ្ធិជំទាស់របស់ខ្លួន។[135] ក្នុងចំណុចនេះ ការបោះបង់សិទ្ធិតវ៉ា គឺជាសិទ្ធិសេរីភាពរបស់គូភាគីក្នុងការមិនធ្វើបណ្ដឹងតវ៉ា ប៉ុន្តែ *ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* នៅតែបន្តផ្ដល់សិទ្ធិសេរីភាពក្នុងការធ្វើបណ្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើមាន ភស្តុតាងបញ្ជាក់អំពីករណីដែលកម្មវត្ថុនៃវិវាទ មិនអាចត្រូវបានដោះស្រាយដោយមជ្ឈត្តការបាន។ យ៉ាងណាមិញ ចំពោះធាតុអត្តនោម័តរបស់ភាគីក្នុងចំណុចនេះ ក៏ជាកត្តាមួយដ៏សំខាន់សម្រាប់តុលាការក្នុងការវិនិច្ឆ័យទៅលើបណ្ដឹងជំទាស់នេះផងដែរ ពីព្រោះថា ប្រសិនបើ ភាគីមិនព្រមធ្វើបណ្ដឹងតវ៉ាក្នុងពេលមជ្ឈត្តការនោះ តើអវត្តមាននៃបណ្ដឹងនោះមានបុព្វហេតុ ឬ

[134] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ៥៣ ស្ដីពីការកែតម្រូវ ការបំភ្លឺលម្អិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម។

[135] *វិធាននៃ ម.ជ.ម. ថ្មី*, ប្រការ ៦៨ ស្ដីពីការបោះបង់សិទ្ធិ។

មូលហេតុអ្វី ឬមួយការធ្វើបណ្ដឹងតវ៉ានោះបានធ្វើហើយ ប៉ុន្តែវេទិកាមជ្ឈត្តការ ឬស្ថាប័ន*ម.ជ.ម.* មិនបានចាត់វិធានការណ៍ត្រឹមត្រូវ ដើម្បីឆ្លើយតប និងដោះស្រាយជូនភាគីវិវាទ។

**២.២.២.២. នយោបាយសាធារណៈ**

ក្នុងបរិបទមួយទៀត ដែលតុលាការរកឃើញនូវការសម្រេចសេចក្ដីរបស់មជ្ឈត្តការ ផ្ទុយទៅនឹងនយោបាយសាធារណៈរបស់ជាតិនោះ តុលាការ ក៏មានសិទ្ធិក្នុងការបដិសេធចោលនូវមជ្ឈត្តវិនិច្ឆ័យនោះបានផងដែរ។ គួរបញ្ជាក់ផងដែរថា ភាពផ្ទុយទៅនឹងនយោបាយសាធារណៈរបស់ជាតិ គឺចាត់ទុកបានជាភាពចម្រូងចម្រាស ផ្ទុយទៅនឹង គោលការណ៍មូលដ្ឋាននៃប្រព័ន្ធយុត្តិធម៌នៃប្រទេសដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវអនុវត្ត។[136] ជាការអនុវត្តជាក់ស្ដែងគឺវាពិតជាមានផលពិបាកយ៉ាងខ្លាំង ក្នុងការកំណត់ថាតើបញ្ហាណាខ្លះដែលផ្ទុយទៅនឹងនយោបាយសាធារណៈ ហើយនិយមន័យនៃនយោបាយសាធារណៈនេះទៀតសោត ក៏មានការប្រែប្រួលពីបរិបទគតិយុត្តនៃជាតិមួយទៅបរិបទគតិយុត្តនៃជាតិមួយទៀតដែរ។ យ៉ាងណាមិញ ប្រសិនបើធ្វើការសំយោគជារួមថា ភាពផ្ទុយទៅនឹងនយោបាយសាធារណៈនោះ សម្ដៅដល់ត្រឹមកម្រិតណានោះ គឺជាទូទៅវាមានភាពទាក់ទងទៅនឹង អនីត្យានុកូលភាពនៃសេចក្ដីសម្រេចដោយមូលហេតុរំលោភបំពានទៅនឹងច្បាប់ជាធរមាននៃជាតិមួយ ឬវាអាចបង្កឱ្យមានភាពភ្ញាក់ផ្អើលដល់សតិសម្បជញ្ញៈរបស់បុគ្គលទូទៅ ដែលនាំឱ្យកើតក្ដីផើងឆ្ងល់ ឬវាបានឬនឹងផ្ដល់ផលប៉ះពាល់យ៉ាងជាក់ច្បាស់ទៅនឹងទំនៀមទម្លាប់ល្អរបស់សង្គម ឬមួយវាជាការរំលោភបំពានទៅលើផ្នត់គំនិតជាមូលដ្ឋានអំពីសីលធម៌ និងយុត្តិធម៌។[137] ក្នុងការមើលលំអិតទៅលើបញ្ហានៃនយោបាយសាធារណៈ វាអាចត្រូវបានបែងចែកជាពីរទិដ្ឋភាព គួយ៉ាងទិដ្ឋភាពនៃនីតិវិធី និងទិដ្ឋភាពនៃសារធាតុសំខាន់ៗពាក់ព័ន្ធ។[138] ទិដ្ឋភាពនៃនីតិវិធីដែលអាចប៉ះពាល់ ឬផ្ទុយនឹងនយោបាយសាធារណៈ គឺអាចស្ដែង

---

[136] គណៈកម្មាការអង្គការសហប្រជាជាតិទទួលបន្ទុកលើនីតិអន្តរជាតិពាណិជ្ជកម្ម, *របាយការណ៍របស់គណៈកម្មាធិការទទួលបន្ទុកលើការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស,* លេខ UN Doc.E/២៧០៤ និង E/AC.៤២/៤/Rev.១។

[137] *សូមមើល* អត្ថបទរបស់ Nicholas Poon ស្ដីអំពី ការកំណត់តុល្យភាពរវាងនយោបាយសាធារណៈ និងច្បាប់នៃមជ្ឈត្តការ ក្នុងមជ្ឈត្តការអន្តរជាតិផ្នែកពាណិជ្ជកម្ម *(Striking a Balance Betwee Public Policy and Arbitration Policy in International Commercial Arbitration)*, Singapore Journal of Legal Studies (២០១២), ទំព័រទី១៨៤។ (តទៅនេះហៅថា «*អត្ថបទរបស់Poon*»)

[138] មហាសន្និបាតនៃអង្គការសហប្រជាជាតិ, *របាយការណ៍របស់គណៈកម្មាការអង្គការសហប្រជាជាតិទទួលបន្ទុកលើនីតិអន្តរជាតិពាណិជ្ជកម្ម នាសម័យប្រជុំលើកទី១៨*, លេខ ១៧ (A/៤០/១៧), កថាខណ្ឌទី២៩៧។ (តទៅនេះហៅថា «*របាយការណ៍ អ.ស.ប. លេខ ១៧* (A/៤០/១៧)»)

កថាខណ្ឌទី២៩៨ នៃរបាយការណ៍នេះមានចែងជាភាសាអង់គ្លេសដូចទៅ៖

> 297. […] It was understood that the term "public policy", which was used in the 1958 New York Convention […] covered fundamental principle of law and justice in substantive as well as procedural respects. Thus, instances such as corruption, bribery, or fraud and similar serious case would constitute a ground for setting aside. […]

ចេញឡើងតាមរយៈ អំពើពុករលួយ អំពើស៊ីសំណូក ឬអំពើភូតភរកុហក ដែលកើតមានឡើងនៅក្នុងនីតិវិធីមជ្ឈត្តការ ហើយក្នុងករណីបែបនេះគឺវាអាចជាមូលដ្ឋាន ក្នុងការជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ដោយមូលហេតុផ្ទុយនឹងនយោបាយសាធារណៈផងដែរ។[139] ចំណែកឯ ទិដ្ឋភាពជាសារធាតុសំខាន់នៃនយោបាយសាធារណៈវិញ រួមមានការជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដោយសារមូលហេតុមួយចំនួនដូចជា ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ ដែលអនុវត្តនូវកិច្ចព្រមព្រៀងនោះនឹងនាំឱ្យមានការរំលោភបំពានទៅលើច្បាប់របស់ប្រទេសដែលត្រូវអនុវត្តនោះ ឬកិច្ចព្រមព្រៀងដែលពេលអនុវត្តទៅធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ជាតិជាដើម។ តបតាមការបង្ហាញជូនខាងលើនេះ បញ្ហាដែលពាក់ព័ន្ធទៅនឹង នយោបាយសាធារណៈ ហាក់បីដូចជាមានការទាក់ទងខ្លាំងជាលក្ខណៈអន្តរជាតិ ពោលគឺ តុលាការ ចាំបាច់ត្រូវតែធ្វើការពិចារណាបន្ថែមទៅលើធាតុផ្សំបរទេស ក្នុងការកំណត់ថាតើនយោបាយសាធារណៈត្រូវបានរំលោភបំពាន ឬយ៉ាងណានោះ។ ប៉ុន្តែទោះជា នយោបាយសាធារណៈ ត្រូវបានគេទទួលស្គាល់ថាមានលក្ខណៈជាអន្តរជាតិក៏ដោយនោះ ក៏ប៉ុន្តែមូលដ្ឋាននៃនយោបាយសាធារណៈដែលត្រូវយកមកវិនិច្ឆ័យនោះ គឺត្រូវចាប់ផ្តើមចេញពីជាតិជាដាច់ខាត ដោយសារតែចៅក្រមនៃរដ្ឋមួយគឺជាអ្នកសម្រេចទៅលើការជំទាស់នេះ។[140]

សរុបមក កិច្ចព្រមព្រៀងមជ្ឈត្តការ គឺជាការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាក្នុងការដោះស្រាយវិវាទក្រៅតុលាការ ប៉ុន្តែទោះបីជាការដោះស្រាយនោះស្ថិតនៅក្រៅប្រព័ន្ធតុលាការក៏ដោយ ក៏បញ្ហាដែលពាក់ព័ន្ធទៅនឹងនយោបាយសាធារណៈ អាចត្រូវបានមើលរំលងនោះទេ។ មួយវិញទៀត ការរែកញែកទៅលើនយោបាយសាធារណៈនេះ ក៏ត្រូវមានតុល្យភាពជាមួយនឹងការអនុវត្តច្បាប់ ឬវិធានរបស់មជ្ឈត្តការផងដែរ ដោយមិនកំណត់ថា រាល់នយោបាយសាធារណៈ គឺសុទ្ធសឹងតែត្រូវបានយកមកធ្វើជាមូលដ្ឋានក្នុងការជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះទេ។ លើសពីនេះទៅទៀត ការជំទាស់ដោយឈរលើមូលដ្ឋាននេះ វាអាស្រ័យទៅនឹងនយោបាយសាធារណៈណាមួយជាក់លាក់ រួមទាំង ត្រូវតែមានការថ្លឹងថ្លែងឱ្យបានល្អិតល្អន់ចំពោះផលប្រយោជន៍របស់ភាគីវិវាទផងដែរ៕[141]

---

[139] *របាយការណ៍ អ.ស.ប. លេខ ១៧* (A/៤០/១៧), កថាខណ្ឌទី២៩៨។

[140] លោក Albert Jan van den Berg, *The New York Arbitration Convention of 1958*, T.M.C Asser Institute: The Hague, ១៩៨១, ទំព័រទី ៣៦០។ ក្នុងទំព័រនេះ លោក Van den Berg បានលើកឡើងជាភាសាអង់គ្លេសថា៖

> « It should be pointed out that even if public policy is acknowledge to be 'international', its basis is 'national' as it can be sanctioned only by a national judge. »

[141] *អត្ថបទរបស់ Poon*, ទំព័រ ១៩០។ *សូមមើលបន្ថែម* លេខសម្គាល់ក្រោមអក្សរទី៨៥ ក្នុង *អត្ថបទរបស់ Poon* ដែលបានលើកឡើងនូវការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសសិង្ហបុរី តួយ៉ាងក្នុងរឿងក្តី *Poh Soon Kiat v. Desert Palace Inc* នៅក្នុងឆ្នាំ២០១០ លេខ S.L.R. ១១២៩ (C.A.)។ តុលាការសិង្ហបុរី បានបដិសេធក្នុងការអនុវត្តនូវកិច្ចសន្យាទាក់ទងនឹងល្បែងស៊ីសង ដោយមូលដ្ឋាននៃការជំទាស់នេះ គឺវាមានភាពផ្ទុយទៅនឹងនយោបាយសាធារណៈ ពោលគឺក្នុងការដែលមិនបដិសេធនូវមជ្ឈត្តវិនិច្ឆ័យ ដែលផ្តើមចេញពីកិច្ចសន្យាល្បែងនេះទេ គឺវានឹងបង្កឱ្យមានការភ្ញាក់ផ្អើលដល់សាធារណៈជន និងបង្កើតជាផ្នត់គំនិតមួយមិនសមប្រកបដែលប៉ះពាល់ដល់សីលធម៌សង្គម។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវបានយ៉ាងលម្អិត និងក្បោះក្បាយ បាននាំឱ្យមានការសន្និដ្ឋានបានទៅលើការស្រាវជ្រាវនេះដូចទៅ៖

ចំពោះរបបគតិយុត្តិនៃវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជាបញ្ហាគួរឱ្យកត់សម្គាល់បទដ្ឋានគតិយុត្តិរបស់ *ម.ជ.ម.* ជាច្រើនពុំទាន់ធ្វើវិសោធនកម្ម ដូចនឹងរបបគតិយុត្តដែលមាននៅបណ្តារដ្ឋដទៃដែលបាន និងកំពុងលើកស្ទួយនូវយន្តការនៃការដោះស្រាយវិវាទតាមប្រព័ន្ធមជ្ឈត្តការនេះ។ ជាក់ស្តែង នៅក្នុងប្រទេសសិង្ហបុរី ទីក្រុងហុងកុង និងរដ្ឋមួយចំនួនទៀត បានធ្វើការកែប្រែនូវបញ្ញត្តិនៃបទដ្ឋានគតិយុត្តរបស់ខ្លួន ឱ្យមានការឆ្លើយតបទៅនឹងការអនុវត្តជាក់ស្តែងក្នុងការដោះស្រាយវិវាទ។ បច្ចុប្បន្នមានតែ វិធានរបស់*ម.ជ.ម.* ទេដែលបានធ្វើវិសោធនកម្ម ដោយរួមបញ្ចូលនូវយន្តការនៃការដោះស្រាយវិវាទថ្មី ដូចជានីតិវិធីពន្លឿន និងមជ្ឈត្តករបន្ទាន់។[142] នេះសរបញ្ជាក់ឱ្យឃើញថាមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជាបាននិងកំពុងមានការគាំទ្រ និងរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយតួលេខបានបង្ហាញឱ្យដឹងថាថ្មីៗនេះមានវិវាទប្រមាណ ម្ភៃប្រាំ ករណី ដែលមានទឹកប្រាក់សរុបចំនួនស្មើ ចិតសិបបីលានដុល្លាអាមេរិច ដែលបាននិងងកំពុងត្រូវបានដោះស្រាយដោយ*ម.ជ.ម.*។[143]

ចំណែកឯ ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យវិញ បទបញ្ញត្តិដែលពាក់ព័ន្ធមានតិចតួចនៅឡើយ ដែលទាមទារឱ្យមានការពន្យល់ និងបកស្រាយបន្ថែមជាច្រើនទៀត។ ជាក់ស្តែង ក្នុងការស្រាវជ្រាវ មាននូវចំណុចស្មុគស្មាញមួយចំនួន ដែលទាក់ទងទៅនឹងការប្តឹងជំទាស់នេះ ដូចជាតួនាទីរបស់តុលាការក្នុងការជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ក្នុងករណីមានភាពផ្ទុយទៅនឹងនយោបាយសាធារណៈ។ ជាបញ្ហា គឺមិនមានបទដ្ឋានណាក្នុងការកំណត់នយោបាយសាធារណៈនោះទេ ជាពិសេសបើភាគីមានសញ្ជាតិផ្សេងពីគ្នា វានឹងអាចបង្កើតបានជាឱកាសដល់ភាគីក្នុងការប្តឹងទាស់ ដើម្បីពន្យាពេលនៃការអនុវត្ត ឬគេចវេសពីការបំពេញកាតព្វកិច្ចដោយយកនយោបាយសាធារណៈមកធ្វើជាឃែលការពារប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ។ ជាពិសេស ភាគីវិវាទចាំបាច់ត្រូវយល់ដឹងអំពីសិទ្ធិក្នុងការប្តឹងជំទាស់ ទាមទារឱ្យតុលាការបដិសេធនូវមជ្ឈត្តវិនិច្ឆ័យ ក្នុងករណីរកឃើញមានមូលដ្ឋានក្នុងការជំទាស់ ដោយទុកឆន្ទានុសិទ្ធក្នុងការសម្រេចវិនិច្ឆ័យសេចក្តីដោយតុលាការមានសមត្ថកិច្ច៕

[142] *វិធាននៃ ម.ជ.ម. ថ្មី*, បុព្វកថា, ទំព័រទី២ និងទំព័រទី៣។

[143] សិក្ខាសិលាតាមប្រព័ន្ធអនឡាញ ស្តីពីទិដ្ឋភាពទូទៅនៃវិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ឆ្នាំ ២០២១ រៀបចំដោយ ម.ជ.ម. នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២១ ដែលមាន លោកមជ្ឈត្តការ ប៊ុន យូឌី ប្រធាននៃ ម.ជ.ម. ធ្វើបទឧទ្ទេសនាមនៅក្នុងសិក្ខាសិលាអនឡាញនេះ។ ទិន្នន័យនេះត្រូវបានបង្ហាញជូនដល់សិក្ខាកាម ក្នុងបទបង្ហាញរបស់ លោកមជ្ឈត្តករ ប៊ុន យូឌី ដែលមានលេខរៀងទំព័រទី៧។ *សូមមើលបន្ថែម* គេហទំព័រផ្លូវការរបស់*ម.ជ.ម.* ដែលមានតំណ៖ https://ncac.org.kh/statistics/។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានបញ្ចប់នូវការស្រាវជ្រាវ និងតាក់តែងនូវអត្ថបទសារណា ក្រោមប្រធានបទ «*នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្នុងការប្តឹងទាស់នឹងមជ្ឈត្តវិនិច្ឆ័យនៅព្រះរាជាណាចក្រកម្ពុជា*» នេះហើយ យើងអាចធ្វើការសង្កេតបានថា មជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា បាននិងកំពុងមានការគាំទ្រ និងជ្រើសរើសជាយន្តការនៃការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម ដោយភាគីវិវាទជាច្រើន។ ក្នុងការអនុវត្តជាក់ស្តែង ភាគីតែងកំណត់យកយន្តការនេះក្នុងការដោះស្រាយវិវាទ ដូចនេះដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ភាគីវិវាទ *ម.ជ.ម.* ជាមួយគ្នានឹងស្ថាប័នដែលពាក់ព័ន្ធ ចាំបាច់ត្រូវតែបន្តស្វះស្វែងក្នុងការស្រាវជ្រាវរកយន្តការថ្មីៗ នីតិវិធីល្អៗ និងបទបញ្ញត្តិសំខាន់ៗ ដើម្បីបញ្ចូលបន្ថែមទៅក្នុងបទដ្ឋានគតិយុត្តនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ជាងនេះទៅទៀត ដោយសារវិស័យនេះ មានសញ្ញាណមកពីប្រភពបរទេសច្រើន ប៉ុន្តែជាបញ្ហាចោទនោះគឺឯកសារជាច្រើន មានជាភាសាបរទេស ដែលវាបង្កបានជាផលវិបាកដល់ការសិក្សាស្រាវជ្រាវ និងតាមដានផងដែរ។

ហេតុដូចនេះជាអនុសាសន៍ គឺចាំបាច់ត្រូវតែមានឯកសារជាភាសាជាតិឱ្យបានច្រើន ដោយរាប់បញ្ចូលទាំងលិខិតបទដ្ឋានគតិយុត្ត សេចក្តីពន្យល់ និងអត្ថបទស្រាវជ្រាវជាដើម។ លទ្ធផលដែលនឹងទទួលបានតាមការជម្រុញឱ្យមានឯកសារជាភាសាជាតិឱ្យបានច្រើននេះ នឹងបន្តញាំងឱ្យវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជាមានការរីកសុះសាយ អភិវឌ្ឍន៍បានឆាប់រហ័ស និងត្រូវបានទទួលស្គាល់ជាច្រើនបន្ថែមទៀតទាំងក្នុងមជ្ឈដ្ឋានជាតិ និងមជ្ឈដ្ឋានអន្តរជាតិថែមទៀតផង។

លើសពីនេះទៅទៀត ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវអំពីប្រធានបទដែលមានលក្ខណៈឯកជន ហើយដែលពាក់ព័ន្ធនឹងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មមួយរូប យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជានឹងបន្តលើកស្ទួយវិស័យឯកជន ស្របតាមផែនការយុទ្ធសាស្ត្រចតុកោណរបស់ជាតិ រួមទាំងបន្តជម្រុញ និងលើកកម្ពស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការឱ្យបានច្រើន ដើម្បីបំពេញសេចក្តីត្រូវការ និងផ្តល់ជាវេទិកាក្នុងការដោះស្រាយវិវាទជូនដល់វិនិយោគិន ឬពាណិជ្ជករទាំងឡាយដែលប្រកបពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយ ក្នុងនាមជាយុវជនមួយរូប ជាទំពាំងស្នងឬស្សីដល់ជាតិមួយរូប យើងខ្ញុំសង្ឃឹម ជឿទុកចិត្ត និងរំពឹងយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជា និងមន្ត្រីគ្រប់ស្រទាប់ជាន់ថ្នាក់ រួមទាំងប្រជាពលរដ្ឋខ្មែរទាំងមូល នឹងបន្តពង្រីក និងពង្រឹងវិស័យច្បាប់ ទាំងក្នុងមែកធាងសាធារណៈ ទាំងក្នុងមែកធាងឯកជន ឱ្យបន្តដំណើរឆ្ពោះទៅមុខដោយភាពជោគជ័យ ភាពរុងរឿង ភាពទាន់សម័យ និងភាពដែលអាចអនុវត្តបានជាប្រយោជន៍រួមនៃជាតិទាំងមូលថែមទៀតផង៕

# ឯកសារយោង

# បញ្ជីឯកសារយោង

## ក. អនុសញ្ញាអន្តរជាតិ

១. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ឆ្នាំ២០១៥។

## ខ. របាយការណ៍នៃកិច្ចប្រជុំមហាសន្និបាតរបស់អង្គការសហប្រជាជាតិ និងឯកសារនានារបស់អង្គការសហប្រជាជាតិ

២. គណៈកម្មាការអង្គការសហប្រជាជាតិទទួលបន្ទុកលើនីតិអន្តរជាតិពាណិជ្ជកម្ម, *របាយការណ៍របស់គណៈកម្មាធិការទទួលបន្ទុកលើការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស,* លេខ UN Doc.E/២៧០៤ និង E/AC.៤២/៤/Rev.១។

៣. មហាសន្និបាតនៃអង្គការសហប្រជាជាតិ, *របាយការណ៍របស់គណៈកម្មាការអង្គការសហប្រជាជាតិទទួលបន្ទុកលើនីតិអន្តរជាតិពាណិជ្ជកម្ម នាសម័យប្រជុំលើកទី១៨*, លេខ ១៧ (A/៤០/១៧)។

៤. ច្បាប់គម្រូនៃគណៈកម្មការអង្គការសហប្រជាជាតិ ទទួលបន្ទុកនីតិអន្តរជាតិពាណិជ្ជកម្ម ស្តីអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម «ច្បាប់គម្រូនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម» ប្រកាសឱ្យប្រើនៅ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៨៥។

## គ. យុត្តិសាស្ត្រអន្តរជាតិ

៥. *រឿងក្តីស្តីពីមជ្ឈត្តវិនិច្ឆ័យដែលចេញដោយស្តេចនៃប្រទេសអេស្ប៉ាញ នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩០៦ (រវាង ហុងឌូរ៉ាស និងនីហ្គារ៉ាហ្គ័រ)*, តុលាការយុត្តិធម៌អន្តរជាតិ, សេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩០៦។

## ឃ. លិខិតបទដ្ឋានគតិយុត្តជាតិ

៦. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/១២០៧/០៣០, ប្រកាសឱ្យប្រើនៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧។

៧. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៧០៦/០២១, ប្រកាសឱ្យប្រើនៅថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១១។

៨. ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នស/រកម/០៥០៦/០១ ប្រកាសនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០០៦។

៩. ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់ នឹងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តកាបរទេស, នស/រកម/០៧០១/១០, ប្រកាសឱ្យប្រើនៅ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១។

១០. អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៥២ នៃអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម លេខ ១៨២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០។

១១. អនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម លេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។

១២. វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤។

១៣. វិធានស្តីពីមជ្ឈត្តការ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

**ខ. សៀវភៅ**

១៤. មេធាវី ខៀវ មាលី, ទិដ្ឋភាពគតិយុត្ត ផ្នែកពាណិជ្ជកម្ម និងការវិនិយោគ នៅកម្ពុជា, ការិយាល័យ មេធាវី សុក ស៊ីថាន់ណា និងសហការី, ឆ្នាំ ២០១៨។

១៥. មេធាវី ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍, ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖ ប្រទេសកម្ពុជា, គណៈមេធាវីអាមេរិច, ទីក្រុងញូវយក, ឆ្នាំ ២០១០។

១៦. លោក Albert Jan van den Berg, *The New York Arbitration Convention of 1958*, T.M.C Asser Institute: The Hague, ឆ្នាំ ១៩៨១។

**ច. អត្ថបទស្រាវជ្រាវ**

១៧. អត្ថបទ លោកចៅក្រម Sepúlveda-Amor និងលោកស្រី Lawry-White ស្តីអំពី ទំនួលខុសត្រូវ របស់រដ្ឋ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ (*State repsonsibility and the enforcement of arbitral award*), Oxford University Press (២០១៦)។

១៨. អត្ថបទរបស់ Nicholas Poon ស្តីអំពី ការកំណត់តុល្យភាពរវាងនយោបាយសាធារណៈ និងច្បាប់ នៃមជ្ឈត្តការ ក្នុងមជ្ឈត្តការអន្តរជាតិផ្នែកពាណិជ្ជកម្ម *(Striking a Balance Betwee Public Policy and Arbitration Policy in International Commercial Arbitration)*, Singapore Journal of Legal Studies (២០១២)។

**ឆ. គេហទំព័រផ្លូវការ**

**១៩.** *វិធានស្ដីពីមជ្ឈត្តការ*, ផ្សព្វផ្សាយដោយ *ម.ជ.ម.* កម្ពុជា, [បានចូលមើលនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១], តំណ៖ https://ncac.org.kh/statistics/។

**២០.** *វិធាននៃមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់សិង្ហបុរី*, ផ្សព្វផ្សាយដោយ *ម.ជ.ម* សិង្ហបុរី, [បានចូលមើលនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១], តំណ៖ https://www.siac.org.sg/our-rules/rules/siac-rules-2016។

**២១.** *វិធាននៃមជ្ឈមណ្ឌលអន្តរជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ហុងកុង*, ផ្សព្វផ្សាយដោយ *ម.ជ.ម* ហុងកុង, [បានចូលមើលនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១] តំណ៖ https://www.siac.org.sg/our-rules/rules/siac-rules-2016។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១៖ អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ឧបសម្ព័ន្ធ ២៖ គម្រូខចែងចាស់ និងគម្រូខចែងថ្មីអំពីមជ្ឈត្តការ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ឧបសម្ព័ន្ធ ៣៖ តារាងកម្រៃសេវារបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

# ឧបសម្ព័ន្ធ ១

# អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម


២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៤ អនក្រ.បក

4334

14 08 9

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម**

ថតចម្លង

នាយកដ្ឋាន.រដ្ឋបាល.

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩

១

*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម។*

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលសរសេរកាត់ថា **ម.ជ.ម.** ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

### ជំពូកទី២

### តួនាទីនិងភារកិច្ច

**មាត្រា២.-**

**ម.ជ.ម.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ÷

- ជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ការបណ្តុះបណ្តាលនិងហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្តនិងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈ ជាមជ្ឈត្តករ ដើម្បីធានាឱ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់
- កំណត់ពីលក្ខណសម្បត្តិនៃបុគ្គល ដែលមានបំណងចូលជាសមាជិក **ម.ជ.ម.**
- ផ្តល់សេវាដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ
- រៀបចំសន្និសីទថ្នាក់ជាតិនិងអន្តរជាតិ ក្នុងគោលដៅជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- រៀបចំ ចូលរួមសិក្ខាសាលានិងវគ្គសិក្សា លើប្រធានបទទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ប្រមូល បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធ សៀវភៅនិងឯកសារ សោតទស្សន៍ឬហ្វូណូក្រាម ដែលទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- គ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិ **ម.ជ.ម.**
- រៀបចំបណ្ណាល័យនិងបន្ទប់ផ្សេងៗ សម្រាប់បម្រើសេវាទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ចុះកិច្ចព្រមព្រៀងនានាដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់មហាសន្និបាត **ម.ជ.ម.** ។



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

## ជំពូកទី៣

## រចនាសម្ព័ន្ធ

## ផ្នែកទី១

## មហាសន្និបាត

**មាត្រា៣.-**

សិទ្ធិអំណាចកំពូលរបស់ **ម.ជ.ម.** គឺមហាសន្និបាត។

មហាសន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើងតាមកាលបរិច្ឆេទ ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ឬសមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ អាចស្នើសុំបើកមហាសន្និបាតវិសាមញ្ញបានដោយមានភ្ជាប់មកជាមួយ នូវរបៀបវារៈក្នុងរយៈពេលយ៉ាងតិច១៥ (ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំ។ មហាសន្និបាតវិសាមញ្ញនេះត្រូវពិចារណាតែបញ្ហាណាដែលមិនបានលើកឡើង ឬដោះស្រាយនៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ដែលបានធ្វើឡើងរួចហើយតែប៉ុណ្ណោះ។

**មាត្រា៤.-**

មហាសន្និបាតប្រចាំឆ្នាំពិនិត្យនិងអនុម័តលើបញ្ហាជាអាទិ៍÷

- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ម.**
- ការបោះឆ្នោតជ្រើសតាំងនិងដកហូតសមាជិកក្រុមប្រឹក្សាប្រតិបត្តិ
- បទបញ្ជាផ្ទៃក្នុងនិងវិធាន ដែលទាក់ទងនឹងការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម
- ការកែប្រែនូវបទប្បញ្ញត្តិនានា ដែលទាក់ទងដល់ដំណើរការរបស់ **ម.ជ.ម.**
- បែបបទហិរញ្ញវត្ថុនិងរដ្ឋបាល សម្រាប់ការគ្រប់គ្រងដំណើរការរបស់ **ម.ជ.ម.**
- នីតិវិធីសម្រាប់ការចុះបញ្ជីមជ្ឈត្តករ
- លក្ខណសម្បត្តិបន្ថែមសម្រាប់ឱ្យធ្វើជាមជ្ឈត្តករនៅ **ម.ជ.ម.**
- ក្រមសីលធម៌សម្រាប់មជ្ឈត្តករ។

**មាត្រា៥.-**

ការជូនដំណឹងពីមហាសន្និបាតប្រចាំឆ្នាំ ត្រូវធ្វើឡើងយ៉ាងតិច ៣០ (សាមសិប)ថ្ងៃ មុនថ្ងៃប្រជុំ។ ការជូនដំណឹងនេះត្រូវបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែងប្រជុំ និងរបៀបវារៈ។



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

**មាត្រា៦.-**

មហាសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមាន២/៣ (ពីរភាគបី) នៃសមាជិកទាំងអស់គិតទាំងសមាជិកផ្ទេរសិទ្ធិ ហើយបញ្ហានានាដែលលើកមកពិភាក្សា ត្រូវសម្រេចដោយសំឡេងភាគច្រើនដាច់ខាត ។

ក្នុងករណីមិនមានកូរ៉ុមដើម្បីដំណើរការមហាសន្និបាត កិច្ចប្រជុំនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃ ហើយកូរ៉ុមសម្រាប់កិច្ចប្រជុំលើកទីពីរនេះគឺ ១/២ (មួយភាគពីរ) នៃសមាជិកទាំងអស់ គិតទាំងសមាជិកផ្ទេរសិទ្ធិ ។

ក្នុងករណីដែលកិច្ចប្រជុំលើកទីពីរពុំមានកូរ៉ុម មហាសន្និបាតនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃទៀត ហើយប្រសិនបើនៅតែគ្មានកូរ៉ុមនៅក្នុងកិច្ចប្រជុំនេះទៀត ចំនួនអ្នកចូលរួមក្នុងកិច្ចប្រជុំដែលត្រូវពន្យាពេលជាលើកទីពីរនោះត្រូវចាត់ទុកថាជាកូរ៉ុមដើម្បីចាប់ផ្តើមមហាសន្និបាត ។

ការបោះឆ្នោតតាមរយៈសិទ្ធិប្រទានត្រូវបានអនុញ្ញាតប៉ុន្តែសមាជិកម្នាក់អាចទទួលបានសិទ្ធិប្រទានតែមួយប៉ុណ្ណោះ ។ សិទ្ធិប្រទានត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះក្នុងកំណត់ហេតុប្រជុំ ។

**មាត្រា៧.-**

មហាសន្និបាតវិសាមញ្ញ ត្រូវបានកោះប្រជុំដោយប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងតាមពេលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ។

ប្រសិនបើប្រធានក្រុមប្រឹក្សាប្រតិបត្តិ មិនបានកោះប្រជុំមហាសន្និបាតវិសាមញ្ញ ក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីបានទទួលសំណើជាលាយលក្ខណ៍អក្សរទេនោះ សមាជិកដែលស្នើសុំឱ្យមានមហាសន្និបាតវិសាមញ្ញ អាចបើកមហាសន្និបាតវិសាមញ្ញតាមរយៈការជូនដំណឹងទៅសមាជិកទាំងអស់ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃជាមុន ដោយរៀបរាប់អំពីបញ្ហាដែលត្រូវពិភាក្សា ហើយត្រូវបិទផ្សាយរបៀបវារៈរបស់ខ្លួន នៅលើក្តារព័ត៌មានក្នុងបរិវេណ **ម.ជ.ម.** ។

## ផ្នែកទី២
## ក្រុមប្រឹក្សាប្រតិបត្តិ

**មាត្រា៨.-**

**ម.ជ.ម.** គ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិ ដែលត្រូវជួបប្រជុំទៀងរាល់ខែ ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវមានសមាជិកមិនលើសពី ៧ (ប្រាំពីរ) រូបឡើយ ។

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិរួមមាន ៖

- ប្រធានមួយរូប
- អនុប្រធានមួយរូប



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកាផ្ទេកពាណិជ្ជកម្ម។*

- ហេរញ្ញិកមួយរូប
- សមាជិកមួយចំនួន ។

**មាត្រា៩.–**

ក្រុមប្រឹក្សាប្រតិបត្តិគ្រប់គ្រងនិងសម្រេចការងារប្រចាំថ្ងៃ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិមានអានុភាពអនុវត្ត លើកលែងតែសេចក្តីសម្រេចនោះ ត្រូវបានបដិសេធដោយមហាសន្និបាត ។

**មាត្រា១០.–**

ក្រុមប្រឹក្សាប្រតិបត្តិបំពេញតួនាទីផ្សេងៗទៀតមានជាអាទិ៍ ៖

- ជ្រើសរើសបុគ្គលិកឱ្យបម្រើការងារជាអគ្គលេខាធិការរបស់ **ម.ជ.ម.**
- កំណត់ចំនួនបុគ្គលិក និយោជិត លក្ខខណ្ឌការងារ ប្រាក់បៀវត្ស កម្រៃសេវា ឬលក្ខខណ្ឌដទៃទៀត
- បញ្ឈប់ការងារនិងដាក់វិន័យលើបុគ្គលិក ដោយផ្អែកតាមកិច្ចសន្យាការងារ ។

**មាត្រា១១.–**

ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **ម.ជ.ម.** ជូនមហាសន្និបាតប្រចាំឆ្នាំ ។

**មាត្រា១២.–**

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតជ្រើសតាំងនៅក្នុងមហាសន្និបាតនៃ **ម.ជ.ម.** ។

សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិ ៣ (បី)ឆ្នាំ ហើយសមាជិកទាំងអស់អាចធ្វើជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិមិនលើសពី ២(ពីរ) អាណត្តិឡើយ ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិទាំងអស់អាចត្រូវបានបោះឆ្នោតសម្រាប់ ២ (ពីរ) អាណត្តិជាប់គ្នា លើកលែងតែមុខតំណែងជាហេរញ្ញិកដែលមិនអាចត្រូវបានជ្រើសរើស ២(ពីរ) អាណត្តិជាប់គ្នា ។

**មាត្រា១៣.–**

ប្រធាន អនុប្រធាន និងហេរញ្ញិក ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយឡែកពីគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សាប្រតិបត្តិដោយក្រុមប្រឹក្សាប្រតិបត្តិ ។

**មាត្រា១៤.–**

ប្រធានក្រុមប្រឹក្សាប្រតិបត្តិត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន ។ ការបោះឆ្នោតជ្រើសរើសប្រធានត្រូវធ្វើជា ២ (ពីរ)ជុំ ប្រសិនបើជុំទី១ គ្មានបេក្ខជនណាទទួលសំឡេងគាំទ្រភាគច្រើនដាច់ខាតទេ ។ ការបោះឆ្នោតនៃជុំទីពីរ គឺយកតែបេក្ខជនពីររូបដែលមានសំឡេងឆ្នោតច្រើន[illegible]ឈ្មោះមកឱ្យឈរឈ្មោះ ។



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការផ្អែកពាណិជ្ជកម្ម។*

ដោយឡែកអនុប្រធាននិងហេរញ្ញិក ត្រូវបោះឆ្នោតជ្រើសរើសដោយយកតាមសំឡេងភាគច្រើនធម្មតា ក្នុងករណីមានសំឡេងស្មើគ្នា ត្រូវយកអ្នកមានអាយុច្រើនជាងគេ។

សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានសញ្ជាតិខ្មែរ។ ដោយឡែក ប្រធាន និង ហេរញ្ញិក ត្រូវមានសញ្ជាតិខ្មែរ។

ប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់ **ម.ជ.ម.**។

អនុប្រធាន ត្រូវជួយការងាររបស់ប្រធាន ហើយជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន។

ហេរញ្ញិក ត្រូវគ្រប់គ្រងមូលនិធិ ប្រមូលចំណូលនិងចាត់ចែងចំណាយក្នុងនាម **ម.ជ.ម.** ហើយត្រូវមានគណនីចរន្ត និងត្រូវទទួលខុសត្រូវពីភាពត្រឹមត្រូវនៃគណនីទាំងនោះ។

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវជួយការងារ **ម.ជ.ម.**និងបំពេញភារកិច្ច ដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

**មាត្រា១៥.-**

ក្នុងករណីតំណែងប្រធាន អនុប្រធាន ឬហេរញ្ញិក របស់ក្រុមប្រឹក្សាប្រតិបត្តិនៃ **ម.ជ.ម.** នៅទំនេរដោយសារការលាលែងពីមុខតំណែង ក្រុមប្រឹក្សាប្រតិបត្តិត្រូវបោះឆ្នោតជ្រើសរើសសមាជិករបស់ខ្លួនម្នាក់ទៀតឱ្យចូលកាន់មុខតំណែងដែលនៅទំនេរនោះនៅក្នុងកិច្ចប្រជុំបន្ទាប់ ឬនៅឯកិច្ចប្រជុំណាមួយដ៏ខ្លី បន្ទាប់ពីការលាលែងនោះ។

**មាត្រា១៦.-**

សមាជិកគ្រប់រូបរបស់ **ម.ជ.ម.** ទោះរូបវន្តបុគ្គលក្តី អ្នកតំណាងផ្ទេរសិទ្ធិដែលទទួលបានការចាត់តាំងពីសភាពាណិជ្ជកម្មរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីត្រូសហគ្រាស គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករក្តី មានសិទ្ធិឈរឈ្មោះឱ្យមហាសន្និបាតបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ លុះត្រាតែបានចុះឈ្មោះ ជាមជ្ឈត្តករក្នុងបញ្ជីនៃ **ម.ជ.ម.**។

**មាត្រា១៧.-**

ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលត្រូវបានកំណត់ សម្រាប់មហាសន្និបាតប្រចាំឆ្នាំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើការកំណត់ និងផ្សព្វផ្សាយនូវ ÷

- កាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន
- កាលបរិច្ឆេទបោះឆ្នោត ដែលមិនត្រូវតិចជាង៣ (បី) សប្តាហ៍ បន្ទាប់ពីកាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន
- ទីកន្លែងដែលមានភាពងាយស្រួលក្នុងបរិវេណ **ម.ជ.ម.** ឬកន្លែងផ្សេងទៀតសម្រាប់រៀបចំការបោះឆ្នោតជាសម្ងាត់។



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការផ្នែកពាណិជ្ជកម្ម។*

**មាត្រា១៨.-**

ការបោះឆ្នោតជ្រើសរើសសមាជិកទាំងអស់ ឬសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតជាសម្ងាត់ ដោយសមាជិកមួយរូបមានសំឡេងឆ្នោតមួយសំឡេង ក្នុងមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញ ដោយអនុលោមតាមវិធានកំណត់ដោយមហាសន្និបាត។

ក្រុមប្រឹក្សាប្រតិបត្តិថ្មីដែលទើបកើតឡើងក្រោយពីមានការបោះឆ្នោតត្រូវចូលកាន់មុខតំណែងនៅក្រោយពេលមហាសន្និបាតប្រចាំឆ្នាំ។

**មាត្រា១៩.-**

មជ្ឈត្តករដែលឈរឈ្មោះបោះឆ្នោត ជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ÷

- សមាជិក **ម.ជ.ម.** ពីររូបអាចស្នើតែងតាំងសមាជិក **ម.ជ.ម.** បានតែម្នាក់ប៉ុណ្ណោះធ្វើជាបេក្ខជន
- សំណើតែងតាំងបេក្ខជនត្រូវមានការយល់ព្រមពីសាមីខ្លួនផ្ទាល់
- សំណើតែងតាំងត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា។

**មាត្រា២០.-**

បើសិនបេក្ខជនឈរឈ្មោះមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតរើស សម្រាប់ធ្វើជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ការជ្រើសរើសត្រូវពន្យាររយៈពេល១៥(ដប់ប្រាំ)ថ្ងៃទៀត។ ក្រោយរយៈពេលពន្យារ ១៥(ដប់ប្រាំ) ថ្ងៃ ប្រសិនបើបេក្ខជននៅតែមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតជ្រើសរើស បេក្ខជនទាំងនោះត្រូវចាត់ទុកថាជាប់ឆ្នោតដោយស្វ័យប្រវត្តិ។ ក្នុងករណីដែលបេក្ខជនឈរឈ្មោះមិនគ្រប់ចំនួន មហាសន្និបាតអាចតែងតាំងបេក្ខជនបន្ថែមតាមនីតិវិធីដដែល។ ក្នុងករណីដែលបេក្ខជនមានចំនួនលើសពីចំនួនតំណែង ដែលត្រូវជ្រើសរើស មហាសន្និបាតត្រូវធ្វើការបោះឆ្នោត។

**មាត្រា២១.-**

សមាជិកក្រុមប្រឹក្សាប្រតិបត្តិត្រូវបាត់បង់មុខតំណែងក្នុងករណីដូចខាងក្រោម ÷

- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយ និងសតិស្មារតី មិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានផ្តន្ទាទោសពីបទល្មើសមជ្ឈិម ឬឧក្រិដ្ឋណាមួយ
- អវត្តមានពីកិច្ចប្រជុំ ៣ (បី)ដង ជាប់ៗគ្នាដោយគ្មានមូលហេតុ
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធនដោយតុលាការ
- សុំលាលែងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ
- លែងជាសមាជិករបស់ **ម.ជ.ម.**
- លែងជាតំណាងចាត់តាំងរបស់អង្គការសមាជិក



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

- ទទួលមរណភាព។

**មាត្រា២២.-**

ក្រៅពីការប្រជុំប្រចាំខែ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ អាចកោះប្រជុំក្រុមប្រឹក្សាប្រតិបត្តិពេលណាក៏បាន ដោយជូនដំណឹងទៅកាន់សមាជិកក្រុមប្រឹក្សាប្រតិបត្តិ រយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាមុន។ យ៉ាងហោចណាស់ត្រូវមានសមាជិក ២/៣ (ពីរភាគបី) វត្តមាន ដើម្បីឱ្យដំណើរការប្រជុំមានសុពលភាព។

បញ្ហានានាដែលត្រូវបានលើកឡើងមកពិភាក្សា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ ត្រូវសម្រេចដោយសំឡេងភាគច្រើន ហើយក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

**មាត្រា២៣.-**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាប្រតិបត្តិបាត់បង់សមាជិកភាពរបស់ខ្លួន ប្រធាន **ម.ជ.ម.** ត្រូវកោះប្រជុំសន្និបាតវិសាមញ្ញ ដើម្បីធ្វើការជ្រើសរើសសមាជិកបង្គ្រប់។ អាណត្តិរបស់សមាជិកជំនួសនេះជាអាណត្តិរបស់សមាជិក ដែលបានបាត់បង់សមាជិកភាព។

**មាត្រា២៤.-**

ក្រុមប្រឹក្សាប្រតិបត្តិ អាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានា ដែលមានសមាសភាពសមាជិកក្រុមប្រឹក្សាប្រតិបត្តិមួយរូប ឬច្រើនរូបដឹកនាំការងារ។ ការរៀបចំគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានាត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ម.**។

## ផ្នែកទី៣

## អគ្គលេខាធិការដ្ឋាន

**មាត្រា២៥.-**

អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដែលត្រូវជ្រើសរើសដោយក្រុមប្រឹក្សាប្រតិបត្តិ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា២៦.-**

អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** មានតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សាប្រតិបត្តិ និងមានភារកិច្ចដូចខាងក្រោម ÷

- គ្រប់គ្រងលើការងារនិងសកម្មភាពប្រចាំថ្ងៃរបស់ **ម.ជ.ម.**
- អនុវត្តគោលនយោបាយដែលក្រុមប្រឹក្សាប្រតិបត្តិដាក់ចេញ
- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ មហាសន្និបាត និងកិច្ចប្រជុំផ្សេងទៀត



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

- រក្សាឯកសារ
- ប្រមូលព័ត៌មានដែលពាក់ព័ន្ធនិងសកម្មភាពមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលអាចមានប្រយោជន៍ដល់សមាជិករបស់ **ម.ជ.ម.**
- ផ្តួចផ្តើមគំនិតលើកិច្ចការថ្មីៗ និងរៀបចំសកម្មភាព និងគម្រោងនានាដែលជួយទ្រទ្រង់តួនាទីរបស់ **ម.ជ.ម.**
- ផ្តល់សេវាផ្នែកលេខាធិការដល់សមាជិក ដោយយកកម្រៃសេវាស្របតាមលក្ខខណ្ឌ ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ
- ទ្រទ្រង់ផ្នែកបោះពុម្ពនានារបស់ **ម.ជ.ម.** រួមទាំងកាន់កាប់គេហទំព័ររបស់ **ម.ជ.ម.**
- រៀបចំការបណ្តុះបណ្តាល
- បំពេញភារកិច្ចផ្សេងៗដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

**មាត្រា២៧.-**

**ម.ជ.ម.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។

## ផ្នែកទី៤
## សមាជិកនៃ ម.ជ.ម.

**មាត្រា២៨.-**

បុគ្គលទាំងឡាយដែលចង់ក្លាយជាសមាជិកនៃ **ម.ជ.ម.** ត្រូវចុះបញ្ជីជាមជ្ឈត្តករនៅ **ម.ជ.ម.**។

រាល់ពាក្យសុំចុះឈ្មោះទាំងអស់ ត្រូវដាក់ជូនទៅក្រុមប្រឹក្សាប្រតិបត្តិរបស់ **ម.ជ.ម.** ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារផ្សេងៗ តាមការតម្រូវរបស់ក្រុមប្រឹក្សាប្រតិបត្តិ និងបង់ភាគទានតាមការកំណត់របស់ **ម.ជ.ម.**។

**មាត្រា២៩.-**

រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស អាចដាក់ពាក្យសុំធ្វើជាមជ្ឈត្តករជាមួយ **ម.ជ.ម.** បាន បើសិនជារូបវន្តបុគ្គលនោះ មានលក្ខណសម្បត្តិដូចខាងក្រោម ÷

- មានអាយុចាប់ពី ៣០ (សាមសិប) ឆ្នាំឡើង
- មានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ក្រោយពីបានបញ្ចប់ការសិក្សានៅតាមសកលវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និង
- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាមួយ **ម.ជ.ម.** ឬ [illegible]



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

- មជ្ឈមណ្ឌលនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិនានា ដែលទទួលស្គាល់ដោយ **ម.ជ.ម.** ។

ប្រសិនបើពុំមានលក្ខណសម្បត្តិដូចខាងលើទេ រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេសនោះត្រូវជាបុគ្គលដែលធ្លាប់ធ្វើជា ÷

- សមាជិកនៃស្ថាប័នវិជ្ជាជីវៈផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលទទួលស្គាល់ដោយ **ម.ជ.ម.** ឬ
- មជ្ឈត្តករ ឬអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី៣ (បី) ដង ឡើងទៅ ឬបានសរសេរសេចក្តីបង្គាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចំនួនយ៉ាងតិច៣ (បី) ក្នុងពេលដែលបុគ្គលនោះធ្វើជាមជ្ឈត្តករ ។

ទោះបីដូចមានចែងខាងលើក៏ដោយ និងក្រោយពីមានការយល់ព្រមពីមហាសន្និបាត ក្រុមប្រឹក្សាប្រតិបត្តិអាចកំណត់នូវលក្ខណវិនិច្ឆ័យបន្ថែមផ្សេងទៀត ដែលខ្លួនគិតថា សមស្រប និងមានប្រយោជន៍ដល់ **ម.ជ.ម.** ។

**មាត្រា៣០.–**

មជ្ឈត្តករ ÷

- មិនត្រូវស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋណាមួយ ។

**មាត្រា៣១.–**

**ម.ជ.ម.** ត្រូវរៀបចំបញ្ជីឈ្មោះសមាជិករបស់ខ្លួន ដែលមានចុះព័ត៌មានដូចខាងក្រោម ÷

- ឈ្មោះនិងអាសយដ្ឋាន
- កាលបរិច្ឆេទនៃការចុះបញ្ជី
- លក្ខណសម្បត្តិនិង
- ព័ត៌មានចាំបាច់ដទៃទៀត ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ។

**មាត្រា៣២.–**

ក្រុមប្រឹក្សាប្រតិបត្តិត្រូវបដិសេធការចុះបញ្ជីឱ្យបេក្ខជនណាមួយ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមមាត្រា២៩ និង៣០ នៃអនុក្រឹត្យនេះ ។

**មាត្រា៣៣.–**

វិញ្ញាបនបត្រចុះបញ្ជី ត្រូវសុំបន្តជារៀងរាល់ឆ្នាំតាមរយៈការបង់ភាគទានប្រចាំឆ្នាំ ។

រៀងរាល់ឆ្នាំ **ម.ជ.ម.** ត្រូវប្រកាសជាសាធារណៈ នូវឈ្មោះរបស់មជ្ឈត្តករដែលបានចុះបញ្ជី



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

សមាជិក **ម.ជ.ម.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ នូវរាល់ការផ្លាស់ប្តូរអាសយដ្ឋានវិជ្ជាជីវៈ ឬ អាសយដ្ឋានផ្ទាល់ខ្លួន ក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃផ្លាស់ប្តូរនោះ ។

**មាត្រា៣៤.–**

សភាពាណិជ្ជកម្មរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាស គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចតែងតាំងបុគ្គលមួយរូបធ្វើជាតំណាង និងបោះឆ្នោតក្នុងមហាសន្និបាតនានារបស់ **ម.ជ.ម.** ។ ក្នុងករណីលាលែង ឬឈប់ធ្វើការជាមួយអង្គការដែលខ្លួនជាតំណាង បុគ្គលរូបនោះលែងមានសិទ្ធិជាអ្នកតំណាងរបស់អង្គការសមាជិកនោះដោយស្វ័យប្រវត្តិ ។ ក្រុមប្រឹក្សាប្រតិបត្តិមានសិទ្ធិបដិសេធអ្នកតំណាង ដែលតែងតាំងដោយអង្គការសមាជិកណាមួយ ប្រសិនបើពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ ។

**មាត្រា៣៥.–**

សមាជិក **ម.ជ.ម.** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោមនេះ ÷

- មិនបានបន្តចុះបញ្ជីជាមជ្ឈត្តករជាមួយ **ម.ជ.ម.** តាមការកំណត់
- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយនិងសតិស្មារតី ដែលមិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធន ឬត្រូវដាក់ឱ្យជម្រះបញ្ជី
- សុំលាលែងជាលាយលក្ខណ៍អក្សរទៅកាន់ **ម.ជ.ម.**
- ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ
- បានរំលោភលើក្រមសីលធម៌របស់មជ្ឈត្តករនិងបទបញ្ជាផ្ទៃក្នុង
- ទទួលមរណភាព
- ខកខានមិនបានបង់ភាគទានតាមការកំណត់

ការបាត់បង់សមាជិកភាពនេះត្រូវសម្រេចដោយក្រុមប្រឹក្សាប្រតិបត្តិ ។

**មាត្រា៣៦.–**

ការដកហូតសមាជិកភាពរបស់សមាជិកណាម្នាក់ អាចធ្វើទៅបាន លុះត្រាតែសមាជិកនោះ ត្រូវបានផ្តល់ឱកាសដើម្បីធ្វើការដោះសារជាលាយលក្ខណ៍អក្សរតែមិនបានដោះសារតាមពេលវេលាកំណត់ ។ ក្នុងករណីដែលក្រុមប្រឹក្សាប្រតិបត្តិសម្រេចដកហូតសមាជិកភាពពី **ម.ជ.ម.** ក្រុមប្រឹក្សាត្រូវផ្តល់ហេតុផលជាលាយលក្ខណ៍អក្សរ ។ ក្នុងករណីដែលសាមីខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ សមាជិកនោះមានសិទ្ធិប្តឹងទៅ



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

**មាត្រា៣៧.‒**

សមាជិក **ម.ជ.ម.** ត្រូវទទួលក្នុងរយៈពេល ២ (ពីរ) ឆ្នាំម្តងយ៉ាងតិចនូវការបណ្តុះបណ្តាលបន្ត ដែលរៀបចំដោយ **ម.ជ.ម.** ឬរៀបចំដោយស្ថាប័នជាតិ និងអន្តរជាតិដែលទទួលស្គាល់ដោយ **ម.ជ.ម.**។

នៅក្នុងការចុះបញ្ជីបន្តជាមជ្ឈត្តករនៅ **ម.ជ.ម.** ក្រុមប្រឹក្សាប្រតិបត្តិអាចបដិសេធការចុះបញ្ជីរបស់សមាជិកណាម្នាក់បាន ក្នុងករណីដែលសមាជិកនោះខកខានមិនបានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត។

**មាត្រា៣៨.‒**

នៅក្នុងកាលៈទេសៈពិសេសដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ក្រុមប្រឹក្សាប្រតិបត្តិ អាចចុះបញ្ជីបន្តសម្រាប់មជ្ឈត្តករណាម្នាក់បាន ទោះបីមជ្ឈត្តករនោះខកខានមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៣៧ ខាងលើ។

## ផ្នែកទី៥

## សវនកម្ម

**មាត្រា៣៩.‒**

ក្រុមហ៊ុនសវនកម្មដែលទទួលបានការអនុម័តយល់ព្រមពីមហាសន្និបាត ត្រូវបានជ្រើសតាំងជាសវនកររបស់ **ម.ជ.ម.** សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ ហើយអាចត្រូវបានជ្រើសតាំងសារជាថ្មីទៀតបាន។

**មាត្រា៤០.‒**

សវនករមានតួនាទីនិងភារកិច្ច ដូចខាងក្រោម ÷

- ធ្វើសវនកម្មប្រចាំឆ្នាំ និងបង្ហាញរបាយការណ៍សវនកម្មរបស់ខ្លួន ក្នុងមហាសន្និបាតប្រចាំឆ្នាំ
- ធ្វើសវនកម្មតាមការស្នើសុំរបស់ប្រធាន **ម.ជ.ម.** សម្រាប់រយៈពេលណាមួយក៏បាន និងនៅគ្រប់ពេលវេលានៅក្នុងអំឡុងពេលនៃកិច្ចសន្យា ហើយត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាប្រតិបត្តិ។

សមាជិកនិងបុគ្គលិកគ្រប់រូបរបស់ **ម.ជ.ម.** មានកាតព្វកិច្ចផ្តល់ព័ត៌មាន និងសេចក្តីពន្យល់នានាដែលតម្រូវដោយសវនករ។

## ផ្នែកទី៦

## សាខារបស់ម.ជ.ម.

**មាត្រា៤១.‒**

**ម.ជ.ម.** អាចបង្កើតសាខារបស់ខ្លួនបាននៅតាមខេត្តនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ [illegible] និងការប្រព្រឹត្តទៅរបស់សាខានីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ម.ជ.ម.**។



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា៤២.-**

ប្រភពធនធានរបស់ **ម.ជ.ម.** បានមកពី ÷

- ភាគទានរបស់សមាជិក
- អំណោយនិងវិភាគទានពីប្រភពផ្សេងៗ
- កម្រៃសេវាផ្នែករដ្ឋបាលរបស់ **ម.ជ.ម.** ។

**មាត្រា៤៣.-**

សមាជិកត្រូវបង់ភាគទានប្រចាំឆ្នាំ តាមការកំណត់របស់មហាសន្និបាតដែលស្នើដោយក្រុមប្រឹក្សាប្រតិបត្តិ ។

ភាគទានប្រចាំឆ្នាំត្រូវបង់ជាមុន ក្នុងអំលុងខែទីមួយរៀងរាល់ឆ្នាំ។ ប្រសិនបើសមាជិកណាម្នាក់ មានភាពយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ ឬវិភាគទានដទៃទៀត ហើយហេរញ្ញិកត្រូវក្រើនរំលឹកជាបន្ទាន់ដល់សមាជិកនោះ ។

ប្រសិនបើសមាជិកណាម្នាក់ មានការយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ លើសពី ៣ (បី)ខែ ចាប់ពីខែទីពីរ សមាជិកនោះត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយស្វ័យប្រវត្តិ ។

រាល់មូលនិធិបន្ថែមនានាដែលតម្រូវដោយ **ម.ជ.ម.** សម្រាប់គោលបំណងពិសេសណាមួយអាចប្រមូលពីបណ្ដាសមាជិកបាន លុះត្រាតែមានសំឡេងយល់ព្រមពីមហាសន្និបាតរបស់សមាជិកលើសពី៥០ (ហាសិប) ភាគរយ នៃសមាជិកដែលមានវត្តមានក្នុងមហាសន្និបាត ។

**មាត្រា៤៤.-**

បុគ្គលិករបស់ **ម.ជ.ម.** និងសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ទទួលបានការធានារ៉ាប់រងពី **ម.ជ.ម.** ចំពោះរាល់ការបង់ថ្លៃចំណាយ និងការខាតបង់នានាក្នុងការបំពេញដ៏ត្រឹមត្រូវនូវភារកិច្ចរបស់ខ្លួន ។

## ជំពូកទី៥
## ការជ្រើសរើសមជ្ឈត្តករដំបូង

**មាត្រា៤៥.-**

ក្រសួងពាណិជ្ជកម្មត្រូវបង្កើតគណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូងមួយ ដែលមានសមាជិកមិនលើសពី ១២ (ដប់ពីរ)រូប ។

គណៈកម្មការនេះត្រូវដឹកនាំដោយតំណាងក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន ដូចខាងក្រោម ÷



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សហព័ន្ធនិយោជក
- សភាពាណិជ្ជកម្មកម្ពុជា
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- សភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា
- សមាគមរោងចក្រកាត់ដេរកម្ពុជា
- សភាមុខរបរនិងមីក្រូសហគ្រាស
- បុគ្គលដទៃទៀតដែលក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌យល់ថា សមស្រប ។

**មាត្រា៤៦.-**

ក្រសួងពាណិជ្ជកម្មត្រូវចេញប្រកាសតែងតាំងសមាសភាពគណៈកម្មការរៀបចំនិងជ្រើសរើសមជ្ឈត្តករដំបូង ។ សមាជិកម្នាក់ៗត្រូវចូលរួមដោយផ្ទាល់ ក្នុងរាល់ការប្រជុំរបស់គណៈកម្មការតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា៤៧.-**

គណៈកម្មការរៀបចំ និងជ្រើសរើសនោះត្រូវរៀបចំធ្វើការជ្រើសរើសចេញពីពាក្យស្នើសុំរបស់បេក្ខជនដំបូង ដែលមានចំនួនមិនលើសពី ៦០ ( ហុកសិប ) រូប ដើម្បីឱ្យចុះឈ្មោះជាមជ្ឈត្តករដំបូងនៃ **ម.ជ.ម.** ។

**មាត្រា៤៨.-**

សេចក្តីជូនដំណឹងផ្សេងៗរបស់គណៈកម្មការត្រូវធ្វើឡើងតាមរយៈបណ្តាញសារព័ត៌មាន និងផ្ញើជូន អង្គការ ក្រសួង ស្ថាប័នទាំងអស់ និងបុគ្គលពាក់ព័ន្ធនានាដោយផ្ទាល់ ។

**មាត្រា៤៩.-**

អ្នកដាក់ពាក្យទាំងអស់ត្រូវផ្តល់ព័ត៌មានលម្អិតផ្ទាល់ខ្លួន និងព័ត៌មានអំពីលក្ខណសម្បត្តិរបស់ខ្លួនដូចបានកំណត់នៅក្នុងអនុក្រឹត្យនេះ និងតាមការកំណត់របស់គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង ។

គណៈកម្មការត្រូវធ្វើការប្រជុំតាមការចាំបាច់ ដើម្បីធ្វើការពិនិត្យលើពាក្យសុំ និងកំណត់ពីបេក្ខជន ដែលត្រូវជ្រើសរើស មិនតិចជាង ៥០ ( ហាសិប ) រូប ។



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

**មាត្រា៥០.-**

ការប្រជុំរបស់គណៈកម្មការអាចប្រព្រឹត្តទៅបាន លុះត្រាតែមានកូរ៉ុមលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិក។ សេចក្ដីសម្រេចរបស់គណៈកម្មការរៀបចំ និងជ្រើសរើសត្រូវធ្វើឡើងដោយសំឡេងភាគច្រើន នៃសមាជិកដែលមានវត្តមាន និងបោះឆ្នោតនៅក្នុងកិច្ចប្រជុំ។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងខាងប្រធានមានឧត្តមានុភាព។

**មាត្រា៥១.-**

ឈ្មោះរបស់បុគ្គលដែលត្រូវបានជ្រើសរើសជាសមាជិកដំបូង ត្រូវបិទផ្សាយក្នុងរយៈពេល១៤ (ដប់បួន)ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចចុងក្រោយ ហើយបុគ្គលដែលជាប់ឈ្មោះទាំងនោះត្រូវឆ្លងកាត់វគ្គបណ្ដុះបណ្ដាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម។

**មាត្រា៥២.-**

បុគ្គលដែលត្រូវបានជ្រើសរើសដំបូង មិនតិចជាង៥០ (ហាសិប) រូប ត្រូវដាក់ពាក្យសុំធ្វើជាមជ្ឈត្តករនៅ **ម.ជ.ម.** ក្រោយពីបានបញ្ចប់វគ្គបណ្ដុះបណ្ដាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

**មាត្រា៥៣.-**

ក្រសួងពាណិជ្ជកម្មត្រូវទទួលខុសត្រូវ ក្នុងការរៀបចំបង្កើតការិយាល័យចុះបញ្ជីមជ្ឈត្តករជាលើកដំបូង និងត្រូវគ្រប់គ្រងការិយាល័យនេះរហូតដល់ពេលដែល **ម.ជ.ម.** ដំណើរការងារដំបូងរបស់ខ្លួន ហើយមានការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា៥៤.-**

ក្រោយពីសមាជិក **ម.ជ.ម.** ត្រូវបានជ្រើសរើសនិងក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតរួចមក ក្រសួងពាណិជ្ជកម្មត្រូវសហការជាមួយ **ម.ជ.ម.** ក្នុងការផ្ទេរបញ្ជីឈ្មោះមជ្ឈត្តករទៅឱ្យអ្នកកាន់បញ្ជីរបស់ **ម.ជ.ម.** រួមទាំងមូលនិធិ និងទ្រព្យនានា ដែលជាកម្មសិទ្ធិ ឬក្លាយជាកម្មសិទ្ធិរបស់ **ម.ជ.ម.**។

ភារកិច្ចគណៈកម្មការត្រូវបញ្ចប់ នៅពេលក្រុមប្រឹក្សាប្រតិបត្តិ **ម.ជ.ម.** ចូលកាន់ការងារ។



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។*

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៥៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



*ដកស្រង់ចេញពី អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្អែកពាណិជ្ជកម្ម។*

# ឧបសម្ព័ន្ធ ២

# គម្រូចែងចាស់ និងគម្រូចែងថ្មីអំពីមជ្ឈត្តការ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែក ពាណិជ្ជកម្ម

## គម្រូខចែងអំពីមជ្ឈត្តការរបស់ ម.ជ.ម.

រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការ នៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្ដីពីមជ្ឈត្តការ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធាន ម.ជ.ម.) ដែលមានសុពលភាពអនុវត្ត នៅពេលចាប់ផ្ដើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធាន ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន__________*នាក់។
(*ចំនួនមជ្ឈត្តករត្រូវកំណត់ ជាចំនួនសេស)

ភាសានៃមជ្ឈត្តការគឺ ________________ ។

ច្បាប់ដែលត្រូវយកមកអនុវត្តកិច្ចសន្យានេះត្រូវស្ថិតក្រោមបញ្ញត្តិច្បាប់
នៃ______________**។
(**បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ)

*ដកស្រង់ចេញពី គេហទំព័រផ្លូវការរបស់ ម.ជ.ម.។*

តំណ៖ https://ncac.org.kh/model-clause/#model-khmer

# គម្រូខចែងអំពីមជ្ឍត្តការរបស់ម.ជ.ម. (ថ្មី) តាមវិធានមជ្ឍត្តការរបស់ម.ជ.ម. ឆ្នាំ២០២១

ឧបសម្ព័ន្ធ ២

## គំរូខចែងរបស់ ម.ជ.ម.

**ខចែងស្តីពីមជ្ឈត្តការ**

រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីមជ្ឈត្តការ ម.ជ.ម.) ដែលមានសុពលភាពអនុវត្តនៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

ទីកន្លែងធ្វើមជ្ឈត្តការគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។*
វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន___________**រូប។
ភាសានៃមជ្ឈត្តការគឺ ________________ ។

**ខចែងស្តីពីច្បាប់គ្រប់គ្រងកិច្ចសន្យា**

ច្បាប់ដែលត្រូវយកមកអនុវត្តលើកិច្ចសន្យានេះគឺច្បាប់នៃ________________***។

* គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើស នៃទីកន្លែងធ្វើមជ្ឈត្តការរបស់ខ្លួន។ ប្រសិនបើគូភាគីវិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើមជ្ឈត្តការផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីវិវាទត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស]")។

** ចំនួនមជ្ឈត្តករត្រូវកំណត់ជាចំនួនសេស។

*** បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ។



*ដកស្រង់ចេញពី ឧបសម្ព័ន្ធ ២ នៃវិធានមជ្ឍត្តការរបស់ម.ជ.ម. ឆ្នាំ២០២១*

# ឧបសម្ព័ន្ធ ៣

# តារាងកម្រៃសេវារបស់ មជ្ឈមណ្ឌលជាតិនៃ
# មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## ឧបសម្ព័ន្ធ ១

# តារាងកម្រៃសេវារបស់ ម.ជ.ម.

(សូមមើលជំពូកទី ៧ *(កម្រៃសេវា)* នៃវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម.)

*១.* *កម្រៃសេវាចុះបញ្ជីសំណុំរឿង*

១.១ នៅពេលដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬបណ្តឹងតប ភាគីប្តឹងទាមទារ ឬភាគីប្តឹងទាមទារនៃបណ្តឹងតបនោះត្រូវបង់រៀងៗខ្លួននូវកម្រៃសេវាចុះបញ្ជីសំណុំរឿងចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក សម្រាប់ការចុះបញ្ជីការទាមទារ ឬបណ្តឹងតបនោះ។

១.២ ប្រសិនបើភាគីប្តឹងទាមទារ ឬភាគីប្តឹងទាមទារនៃបណ្តឹងតប ខកខានក្នុងការបង់កម្រៃសេវាចុះបញ្ជី ម.ជ.ម. នឹងមិនចាប់ដំណើរការមជ្ឈត្តការដោះស្រាយការទាមទារ ឬបណ្តឹងតបនោះនោះទេ។

១.៣ កម្រៃសេវាចុះបញ្ជីសំណុំរឿងមិនអាចត្រូវបានបង់សងវិញទេ។

*២.* *កម្រៃសេវាសំណើសុំឱ្យមានការចូលរួមពីតតិយជន*

២.១ នៅពេលដាក់សំណើសុំឱ្យមានការចូលរួមពីតតិយជនក្រោមប្រការ ៣៥.៥ *(ការចូលរួមពីតតិយជន)* ភាគីដែលដាក់សំណើនោះត្រូវបង់នូវកម្រៃសេវាសំណើសុំឱ្យមានការចូលរួមពីតតិយជនចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក។

២.២ ប្រសិនបើភាគីដែលដាក់សំណើនោះខកខានក្នុងការបង់កម្រៃសេវាសំណើសុំឱ្យមានការចូលរួមពីតតិយជន សំណើសុំឱ្យមានការចូលរួមពីតតិយជននោះមិនត្រូវបានលើកយកមកពិចារណាក្នុងដំណើរការមជ្ឈត្តការឡើយ។

២.៣ កម្រៃសេវាសំណើសុំឱ្យមានការចូលរួមពីតតិយជនមិនអាចត្រូវបានបង់សងវិញទេ។



*ដកស្រង់ចេញពី ឧបសម្ព័ន្ធ ១ នៃវិធានមជ្ឈត្តការរបស់ម.ជ.ម. ឆ្នាំ២០២១*

## ៣. *កម្រៃសេវាតែងតាំងមជ្ឈត្តករ*

៣.១ ភាគីវិវាទត្រូវបង់កម្រៃសេវាចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក សម្រាប់ការតែងតាំងមជ្ឈត្តករមួយរូបដែលធ្វើឡើងដោយ ម.ជ.ម. តាមរយៈ គណៈកម្មាធិការតែងតាំង និងនីតិវិធី នៅពេលដែលភាគីវិវាទ ឬគូភាគីវិវាទ ខកខានក្នុងការតែងតាំងមជ្ឈត្តករ ឬមជ្ឈត្តករដែលគូភាគីវិវាទបានតែងតាំង ខកខានក្នុងការតែងតាំងប្រធានវេទិកាមជ្ឈត្តកម្ម ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ហើយ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវបានស្នើ ឬតម្រូវឱ្យធ្វើការតែងតាំងមជ្ឈត្តករ។

៣.២ កម្រៃសេវាតែងតាំងមជ្ឈត្តករ ត្រូវអនុវត្តចំពោះសំណុំរឿងដែលចាត់ចែងដោយ ម.ជ.ម. ឬក្នុងសំណុំរឿងពិសេស ដែលទាមទារឱ្យគណៈកម្មាធិការតែងតាំង និងនីតិវិធី តែងតាំងមជ្ឈត្តករស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ឬក្នុងករណីដែលសំណើសុំឱ្យមានការតែងតាំងមជ្ឈត្តករត្រូវបានបញ្ជូនទៅអគ្គលេខាធិការដ្ឋាន។

៣.៣ កម្រៃសេវាតែងតាំងមជ្ឈត្តករនេះមិនត្រូវអនុវត្តលើការតែងតាំងមជ្ឈត្តករជំនួសណាមួយឡើយ ក្នុងករណីដែលមជ្ឈត្តករត្រូវបានជំនួសដូចមានចែងក្នុងប្រការ ៣០ *(ការដាក់មជ្ឈត្តករជំនួស)* ត្រូវបានតែងតាំងដោយគណៈកម្មាធិការតែងតាំង និងនីតិវិធី។

៣.៤ សម្រាប់សំណុំរឿងពិសេស កម្រៃសេវាតែងតាំងមជ្ឈត្តករត្រូវផ្ទេរចូលគណនីដែលកំណត់ដោយ ម.ជ.ម. មុនពេលចាប់ផ្តើមការតែងតាំង។

៣.៥ កម្រៃសេវាតែងតាំងមជ្ឈត្តករមិនអាចត្រូវបានបង់សងវិញឡើយ។

## ៤.- *កម្រៃសេវាជំទាស់*

៤.១ នៅពេលដាក់សេចក្តីជូនដំណឹងអំពីការជំទាស់ទៅនឹងមជ្ឈត្តករដូចមានចែងក្នុងប្រការ ២៨.២ *(សេចក្តីជូនដំណឹងអំពីការជំទាស់ទៅនឹងមជ្ឈត្តករ ពេលវេលាកំណត់ និងកម្រៃសេវាជំទាស់)* ភាគីវិវាទនោះត្រូវបង់នូវកម្រៃសេវាជំទាស់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក។

៤.២ កម្រៃសេវាជំទាស់មិនអាចត្រូវបានបង់សងវិញឡើយ។

## ៥. *កម្រៃសេវារដ្ឋបាល*

៥.១ កម្រៃសេវារដ្ឋបាលត្រូវយោងតាមកម្រិតនៃកម្រៃសេវា ដែលប្រែប្រួលទៅតាមតម្លៃកម្មវត្ថុនៃវិវាទ និងត្រូវកំណត់ស្របតាមតារាងខាងក្រោម។

៥.២ តម្លៃកម្មវត្ថុនៃវិវាទ គឺជាតម្លៃកម្មវត្ថុនៃរាល់ការទាមទារ និងបណ្តឹងតបទាំងអស់។ ការដោះសាតាមការកាត់កងត្រូវបានបញ្ចូលសម្រាប់ការគណនាតម្លៃកម្មវត្ថុនៃវិវាទ និងកម្រៃសេវារដ្ឋបាល ប្រសិនបើការដោះសាតាមការកាត់កងនោះបណ្តាលឱ្យវេទិកាមជ្ឈត្តកម្មមានបន្ទុកការងារបន្ថែមទៀត។



*ដកស្រង់ចេញពី ឧបសម្ព័ន្ធ ១ នៃវិធានមជ្ឈត្តការរបស់ម.ជ.ម. ឆ្នាំ២០២១*

## កម្រៃសេវារដ្ឋបាលរបស់*ម.ជ.ម.*

**កម្រៃសេវារដ្ឋបាល** (គិតជាដុល្លារអាមេរិក)

| កម្លៃកម្មវត្ថុនៃវិវាទ | | | | | កម្រៃសេវារដ្ឋបាល | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | ៥០.០០០ | | | = | ៧៥០ | | | | |
| ចាប់ពី | ៥០.០០១ | ដល់ | ១០០.០០០ | = | ១.៥០០ | + | ០,៨០% | នៃចំនួនដែលលើសពី | ៥០.០០០ |
| ចាប់ពី | ១០០.០០១ | ដល់ | ៥០០.០០០ | = | ១.៩០០ | + | ០,៧០% | នៃចំនួនដែលលើសពី | ១០០.០០០ |
| ចាប់ពី | ៥០០.០០១ | ដល់ | ១.០០០.០០០ | = | ៤.៧០០ | + | ០,៥០ % | នៃចំនួនដែលលើសពី | ៥០០.០០០ |
| ចាប់ពី | ១.០០០.០០១ | ដល់ | ៣.០០០.០០០ | = | ៧.២០០ | + | ០,២០% | នៃចំនួនដែលលើសពី | ១.០០០.០០០ |
| ចាប់ពី | ៣.០០០.០០១ | ដល់ | ៥.០០០.០០០ | = | ១១.២០០ | + | ០,១២% | នៃចំនួនដែលលើសពី | ៣.០០០.០០០ |
| ចាប់ពី | ៥.០០០.០០១ | ដល់ | ១០.០០០.០០០ | = | ១៣.៦០០ | + | ០,០៨% | នៃចំនួនដែលលើសពី | ៥.០០០.០០០ |
| ចាប់ពី | ១០.០០០.០០១ | ដល់ | ៥០.០០០.០០០ | = | ១៧.៦០០ | + | ០,០៤% | នៃចំនួនដែលលើសពី | ១០.០០០.០០០ |
| លើសពី | ៥០.០០០.០០០ | | | = | ៣៣.៦០០ | | | | |



*ដកស្រង់ចេញពី ឧបសម្ព័ន្ធ ១ នៃវិធានមជ្ឈត្តការរបស់ម.ជ.ម. ឆ្នាំ២០២១*

៥.៣ កម្រៃសេវារដ្ឋបាលនៃសំណុំរឿងនីមួយៗ អាចនឹងត្រូវបានកែប្រែដោយអគ្គលេខាធិការដ្ឋាន ដោយពិចារណាទៅលើកាលៈទេសៈពិសេសណាមួយ ដែលអគ្គលេខាធិការដ្ឋានយល់ឃើញថា សមហេតុផលក្នុងការបន្ថយ ឬដំឡើងកម្រៃសេវារដ្ឋបាល ដែលមានកំណត់នៅក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម.។ កាលៈទេសៈពិសេស រួមមានជាអាទិ៍ បរិមាណការងារដែល ម.ជ.ម. ត្រូវបំពេញមានតិចតួចដោយសារតែការបញ្ចប់ដំណើរការមជ្ឈត្តការមុនកាលកំណត់ ឬសេវាកម្មផ្សេងៗ ដែល ម.ជ.ម. ត្រូវផ្តល់បន្ថែម។ ការដំឡើងកម្រៃសេវារដ្ឋបាលមិនត្រូវលើសពី ៣០% (សាមសិបភាគរយ) នៃកម្រៃសេវារដ្ឋបាលដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. នោះទេ។

## ៦. កម្រៃសេវាវេទិកាមជ្ឈត្តកម្ម

៦.១ កម្រៃសេវាវេទិកាមជ្ឈត្តកម្មត្រូវយោងតាមកម្រិតនៃកម្រៃសេវាដែលប្រែប្រួលទៅតាមតម្លៃកម្មវត្ថុនៃវិវាទ និងត្រូវកំណត់ស្របតាមតារាងខាងក្រោម។

៦.២ តម្លៃកម្មវត្ថុនៃវិវាទ គឺជាតម្លៃនៃរាល់ការទាមទារ និងបណ្តឹងតបទាំងអស់។ ការដោះសាតាមការកាត់កងត្រូវបានបញ្ចូលសម្រាប់ការគណនាតម្លៃកម្មវត្ថុនៃវិវាទ និងកម្រៃសេវាវេទិកាមជ្ឈត្តកម្ម ប្រសិនបើការកាត់កងតាមការដោះសានោះបណ្តាលឱ្យវេទិកាមជ្ឈត្តកម្មមានបន្ទុកការងារបន្ថែមទៀត។

៦.៣ កម្រៃសេវាវេទិកាមជ្ឈត្តកម្មនៃសំណុំរឿងនីមួយៗ ត្រូវបានអគ្គលេខាធិការដ្ឋានកែប្រែដោយពិចារណាទៅលើកាលៈទេសៈពិសេសណាមួយ ដែលអគ្គលេខាធិការដ្ឋានយល់ឃើញថា សមហេតុផលក្នុងការបន្ថយ ឬដំឡើងកម្រៃសេវាវេទិកាមជ្ឈត្តកម្ម ដែលមានកំណត់នៅក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម.។ កាលៈទេសៈពិសេស រួមមានជាអាទិ៍ បរិមាណការងារដែលវេទិកាមជ្ឈត្តកម្មត្រូវបំពេញមានតិចតួចដោយសារតែការបញ្ចប់ដំណើរការមជ្ឈត្តការមុនកាលកំណត់ ឬមានការងារបន្ថែម ដែលវេទិកាមជ្ឈត្តកម្មត្រូវបំពេញពាក់ព័ន្ធនឹងសំណើជាបន្តបន្ទាប់នានាសម្រាប់វិធានការបណ្តោះអាសន្ន ការជំទាស់ទៅនឹងមជ្ឈត្តករ ឬទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម។ ការដំឡើងកម្រៃសេវាវេទិកាមជ្ឈត្តកម្មមិនត្រូវលើសពី ៣០% (សាមសិបភាគរយ) នៃកម្រៃសេវាវេទិកាមជ្ឈត្តកម្មដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. ឡើយ។



*ដកស្រង់ចេញពី ឧបសម្ព័ន្ធ ១ នៃវិធានមជ្ឈត្តការរបស់ម.ជ.ម. ឆ្នាំ២០២១*

## កម្រៃសេវាវេទិកាមជ្ឈត្តកម្ម របស់ *ម.ជ.ម.*

**កម្រៃសេវាវេទិកាមជ្ឈត្តកម្ម** (គិតជាដុល្លារអាមេរិក)

| តម្លៃកម្មវត្ថុនៃវិវាទ | | | | | កម្រៃសេវាវេទិកាមជ្ឈត្តកម្ម (សម្រាប់មជ្ឈត្តករមួយរូប) | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | ៥0.000 | | | = | ១.000 | | | | |
| ចាប់ពី | ៥0.00១ | ដល់ | ១00.000 | = | ២.៧៥0 | + | ២% | នៃចំនួនដែលលើសពី | ៥0.000 |
| ចាប់ពី | ១00.00១ | ដល់ | ៥00.000 | = | ៣.៧៥0 | + | ១,៧0% | នៃចំនួនដែលលើសពី | ១00.000 |
| ចាប់ពី | ៥00.00១ | ដល់ | ១.000.000 | = | ១0.៥៥0 | + | ១,៥0% | នៃចំនួនដែលលើសពី | ៥00.000 |
| ចាប់ពី | ១.000.00១ | ដល់ | ៣.000.000 | = | ១៨.0៥0 | + | 0,៧៥% | នៃចំនួនដែលលើសពី | ១.000.000 |
| ចាប់ពី | ៣.000.00១ | ដល់ | ៥.000.000 | = | ៣៣.0៥0 | + | 0,៥0% | នៃចំនួនដែលលើសពី | ៣.000.000 |
| ចាប់ពី | ៥.000.00១ | ដល់ | ១0.000.000 | = | ៤៣.0៥0 | + | 0,៣0% | នៃចំនួនដែលលើសពី | ៥.000.000 |
| ចាប់ពី | ១0.000.00១ | ដល់ | ៥0.000.000 | = | ៥៨.0៥0 | + | 0,១៥% | នៃចំនួនដែលលើសពី | ១0.000.000 |
| លើសពី | ៥0.000.000 | | | = | ១១៨.0៥0 | | 0,0៧៥% | នៃចំនួនដែលលើសពី | ៥0.000.000 |



*ដកស្រង់ចេញពី ឧបសម្ព័ន្ធ ១ នៃវិធានមជ្ឈត្តការរបស់ម.ជ.ម. ឆ្នាំ២០២១*

## *៧. កម្រៃសេវានៃការស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់*

៧.១ កម្រៃស្នើសុំសម្រាប់សំណើសុំឱ្យតែងតាំងមជ្ឈត្តករបន្ទាន់ (រួមបញ្ចូលទាំងកម្រៃសេវាតែងតាំង និងកម្រៃសេវារដ្ឋបាលនានាដោយអគ្គលេខាធិការដ្ឋានសម្រាប់វិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់) មកគណៈកម្មាធិការតែងតាំង និងនីតិវិធី ក្រោមជំពូក ៣ *(មជ្ឈត្តករបន្ទាន់)* មានចំនួន ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក និងត្រូវបង់គ្រប់ចំនួននៅពេលដាក់សំណើសុំឱ្យតែងតាំងមជ្ឈត្តករបន្ទាន់មកគណៈកម្មាធិការតែងតាំង និងនីតិវិធី។

៧.២ កម្រៃស្នើសុំមិនអាចត្រូវបានបង់សងវិញឡើយ ហើយក៏មិនមែនជាចំណែកមួយនៃកម្រៃសេវារដ្ឋបាលដែលមានកំណត់ក្នុងចំណុច ៥ (*កម្រៃសេវារដ្ឋបាល*)។

៧.៣ កម្រៃសេវាមជ្ឈត្តករបន្ទាន់មានចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក និងត្រូវបង់គ្រប់ចំនួននៅពេលដាក់សំណើសុំឱ្យតែងតាំងមជ្ឈត្តករបន្ទាន់មកគណៈកម្មាធិការតែងតាំង និងនីតិវិធី។

## *៨. កាលបរិច្ឆេទសុពលភាព*

៨.១ តារាងកម្រៃសេវារបស់ ម.ជ.ម. នេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់ ម.ជ.ម. នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

៨.២ តារាងកម្រៃសេវារបស់ ម.ជ.ម. នេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ តទៅ។

**សម្គាល់៖** កម្រៃសេវាដូចមានកំណត់ខាងលើមិនរាប់បញ្ចូលការចំណាយផ្សេងៗរបស់ ម.ជ.ម. វេទិកាមជ្ឈត្តកម្ម និងមជ្ឈត្តករបន្ទាន់ ក៏ដូចជាអាករលើតំលៃបន្ថែមលើកម្រៃសេវារដ្ឋបាលរបស់ ម.ជ.ម. និងពន្ធកាត់ទុកលើសេវារបស់មជ្ឈត្តករឡើយ។ មុនពេលបង្កើតវេទិកាមជ្ឈត្តកម្ម គូភាគីវិវាទអាចព្រមព្រៀងផ្សេងពីនេះលើកម្រៃសេវាវេទិកាមជ្ឈត្តកម្ម ប្រសិនបើវេទិកាមជ្ឈត្តកម្មឯកភាពចំពោះកម្រៃសេវាដែលព្រមព្រៀងនោះ។

ថ្ងៃអាទិត្យ ១៥ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១
**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**
**ប្រធាន**

NATIONAL COMMERCIAL ARBITRATION CENTRE

**ប៊ុន យូឌី**



*ដកស្រង់ចេញពី ឧបសម្ព័ន្ធ ១ នៃវិធានមជ្ឈត្តការរបស់ម.ជ.ម. ឆ្នាំ២០២១*